ក្រសួងអប់រំ យុវជន និង កីឡា

១០០ លំហាត់គណិតវិទ្យាអូឡាំពិច

100 problems in mathematical olympiad

ភាគទី១

APMO IMO



សម្រាប់ៈត្រៀមប្រឡងសិស្សពូកែនិងអាហារូបករណ៍

រៀបរៀងដោយៈ ផុន សុកាល់

និស្សិតវិស្វករនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

១០០លំហាត់គណិតវិទ្យាអូឡាំពិច

រៀបរៀងដោយៈ

ផុន សុកាល់

និស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(សាលាតិចណូ)

រួមមានៈ

៙ លំហាត់គណិតវិទ្យាអូឡាំពិចតាមបណ្តាប្រទេសជុំវិញពិតពលោក

៙ លំហាត់គណិតវិទ្យាអូឡាំពិចអន្តរជាតិដូចជា IMO APMO PUTNAM ...

សម្រាប់ៈ

→ ត្រៀមប្រឡងសិស្សពូកែថ្នាក់ខេត្ត/រាជធានី និង ថ្នាក់ទូទាំងប្រទេស

→ ត្រៀមប្រឡងអាហារូបករណ៍ក្នុងស្រុក ក្រៅស្រុក

ភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

អារម្ភកថា

ដោយមើលឃើញពីកង្វះខាតនៃឯកសារគណិតវិទ្យាអូឡាំពិចទើបជម្រុញចិត្តរូបខ្ញុំបាទឲ្យខិតខំរៀបរៀងជាសៀវភៅមួយក្បាលនេះឡើងដើម្បីទុកជាឯកសារសម្រាប់សិស្សានុសិស្ស សិក្សាស្រាវជ្រាវ ។

លំហាត់ក្នុងសៀវភៅនេះស្ទើរតែទាំងអស់សុទ្ធតែបកប្រែកែសម្រួលពីភាសាបរទេសទៅជាភាសាជាតិយើងដើម្បីសម្រួលដល់អ្នកសិក្សា ងាយស្រួលស្វែងយល់ ដែលក្នុងនោះលំហាត់មួយចំនួនត្រូវបានដកស្រង់ចេញពីសៀវភៅគណិតវិទ្យាអូឡាំពិចបរទេសល្បីៗហើយលំហាត់មួយចំនួនទៀតដកស្រង់ចេញពីអ៊ីនធឺណិតតាមរយៈវេបសាយគណិតវិទ្យាសំខាន់ៗ ។ លំហាត់ទាំងនោះភាគច្រើនជាលំហាត់ធ្លាប់ចេញប្រឡងគណិតវិទ្យាអូឡាំពិចនៅតាមបណ្តាប្រទេសជុំវិញពិភពលោកដូចជា សហរដ្ឋអាមេរិច ប្រទេសរូស្ស៊ី អង់គ្លេស កាណាដា អូស្ត្រាលី ឥណ្ឌា រ៉ូមេនី ប្រេស៊ីល ចិន កូរ៉េ ម៉ុងហ្គោលី សិង្ហបុរី ភីលីពីន ឥណ្ឌូនេស៊ី វៀតណាម ជាដើម ។ សល់ពីនោះជាលំហាត់មាននៅក្នុងការប្រឡងគណិតវិទ្យាអូឡាំពិចលក្ខណៈអន្តរជាតិរួមមាន: IMO APMO PUTNAM ... ។

ចំនុចពិសេសនៃសៀវភៅនេះគឺលំហាត់នីមួយៗសុទ្ធតែប្រដាប់ដោយដំណោះស្រាយយ៉ាងក្បោះក្បាយ ងាយយល់ ហើយប្រកបដោយគន្លឹះប្លែកៗដើម្បីទុកជាទុនក្នុងការត្រៀមខ្លួនប្រឡងសិស្សពូកែគណិតវិទ្យាថ្នាក់ជាតិ ក៏ដូចជាថ្នាក់អន្តរជាតិ ។

ជាទីអវសាន្ត ទោះបីជារូបខ្ញុំបាទខិតខំពិនិត្យពិច័យយ៉ាងណា ក៏ដោយក៏កំហុសឆ្គងច្បាស់ជាកើតមានជាអចេតនាជាក់ជាពុំខាន ។ ហេតុនេះ ខ្ញុំសង្ឃឹមថាមិត្តអ្នកសិក្សា នឹងយល់ហើយជួយកែតម្រូវ ។ ខ្ញុំបាទនឹងទន្ទឹងរង់ចាំពាក្យរិះគន់ក្នុងន័យស្ថាបនា ។

សូមជូនពរឲ្យមិត្តអ្នកសិក្សា ជួបតែសេចក្តីសុខ និង ទទួលជោគជ័យគ្រប់ភារកិច្ច ។

ភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ ២០១៤

អ្នករៀបរៀង

ផុន សុកល់

និស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(សាលាតិចណូ)

Tel: 097 6 950 937

E-mail: sokolphon@gmail.com

លំហាត់ទី១

គេឲ្យ x^3+ax^2+bx+c មានឫសបីជាចំនួនពិតខុសៗ ប៉ុន្តែ

$\left(x^2+x+2001\right)^3+a\left(x^2+x+2001\right)^2+b\left(x^2+x+2001\right)+c$

គ្មានឫសជាចំនួនពិតទេ ។ ចូរស្រាយបញ្ជាក់ថា:

$2001^3+a2001^2+b2001+c>\frac{1}{64}$ ។

(Russian Mathematical Olympiad 2001)

ដំណោះស្រាយ

តាង $f(x)=x^2+x+2001=(x+\frac{1}{2})^2+2001-\frac{1}{4}\geq 2001-\frac{1}{4}$

តាមបម្រាប់: $\left(f(x)\right)^3+a\left(f(x)\right)^2+bf(x)+c$ គ្មានឫសជាចំនួនពិត

នោះបើ x^3+ax^2+bx+c មានឫសជាចំនួនពិតលុះត្រាតែឫសទាំងនោះ

សុទ្ធតែមានតម្លៃ $<2001-\frac{1}{4}$ ។

តាង p,q,r ជាឫសទាំងបីនៃ x^3+ax^2+bx+c នោះមានន័យថា:

$p,q,r<2001-\frac{1}{4}\Rightarrow 2001-p>\frac{1}{4}, 2001-q>\frac{1}{4}$ និង

$2001-r>\frac{1}{4}$

$\Rightarrow (2001-p)(2001-q)(2001-r)>\frac{1}{64}$

$$\Leftrightarrow 2001^3-(p+q+r)2001^2+(pq+qr+rp)2001$$
$$-pqr>\frac{1}{64} \qquad (*)$$

តែដោយ p,q,r ជាឫសទាំងបីនៃ x^3+ax^2+bx+c នោះតាមទ្រឹស្តីបទវ្យែត

យើងបាន:

$$\begin{cases} p+q+r=-a \\ pq+qr+rp=b \\ pqr=-c \end{cases}$$

តាម (*) យើងបាន: $2001^3+a2001^2+b2001+c>\frac{1}{64}$

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់ ។

<u>លំហាត់ទី២</u>

តាង a,b,c,d ជាចំនួនគត់វិជ្ជមានដែលផ្ទៀងផ្ទាត់ ៖ $a>b>c>d$ និង $(a+b-c+d)|(ac+bd)$ ។

ចូរស្រាយបញ្ជាក់ថា: ចំពោះគ្រប់ចំនួនគត់វិជ្ជមាន m និង ចំនួនគត់សេស n នោះ $a^nb^m+c^md^n$ មិនមែនជាចំនួនបឋមទេ ។

(Mongolia ,Team Selection Test 2008)

<u>ដំណោះស្រាយ</u>

យើងមាន: $(a+b-c+d)|(ac+bd)$

នោះ $(a+b-c+d)|(ac+bd)+(a+b-c+d)a$

$\Leftrightarrow a+b-c+d|(a+b)(a+d) \qquad (*)$

នាំឲ្យ មាន $k\in\mathbb{N}$ ដែល $(a+b)(a+d)=k(a+b-c+d)$

សន្មតថា: $\gcd(a+d,a+b-c+d)=1$ នោះតាម $(*)$ យើងបាន:

$a+b-c+d|a+b$ នាំឲ្យ $a+b=l(a+b-c+d)$ ដែល $l\in\mathbb{N}$

បើ $l=1$ នោះ: $a+b=a+b-c+d \Leftrightarrow c=d$ មិនពិត ព្រោះ $c>d$

បើ $l\geq 2$ នោះ: $a+b\geq 2(a+b-c+d)$

$\Leftrightarrow 2c-2d\geq a+b>2c \Leftrightarrow -2d>0$ មិនពិត

នាំឲ្យការសន្មតថា: $\gcd(a+d, a+b-c+d)=1$ មិនពិត

នេះបញ្ជាក់ថា: $\gcd(a+d, a+b-c+d)=q>1$ ។

ម្យ៉ាងទៀត: $q|a+d$ និង $q|a+b-c+d \Rightarrow q|b-c$ នោះយើងបាន:

$a \equiv -d \pmod{q}$ និង $b \equiv c \pmod{q}$

$\Rightarrow a^n \equiv -d^n$ (ព្រោះ n ជា ចំនួនគត់សេស) និង $b^m \equiv c^m \pmod{q}$

$\Rightarrow a^n b^m \equiv -c^m d^n \pmod{q} \Leftrightarrow a^n b^m + c^m d^n \equiv 0 \pmod{q}$

មានន័យថា: $a^n b^m + c^m d^n$ ជាពហុគុណនៃ $q>1$ ។

ដូចនេះ $a^n b^m + c^m d^n$ មិនមែនជាចំនួនបឋមទេ ។

លំហាត់ទី៣

ចូរស្រាយបញ្ជាក់ថា បើ x និង y ជាចំនួនគត់វិជ្ជមានដែល: x^2+y^2-x ចែកដាច់នឹង $2xy$ នោះ x ត្រូវតែជាការេប្រាកដ ។

(British Mathematical Olympiad 1991)

ដំណោះស្រាយ

ដោយ x^2+y^2-x ចែកដាច់នឹង $2xy$ នោះមានចំនួនគត់វិជ្ជមាន k មួយដែល:

$x^2+y^2-x=2xyk \Leftrightarrow y^2-2xyk+x^2-x=0$

ដើម្បីឲ្យសមីការខាងលើនេះមានឫសជាចំនួនគត់វិជ្ជមានលុះត្រាតែ:

$\Delta=(-2xk)^2-4(x^2-x)=4x\left(x(k^2-1)+1\right)$ ជាការេប្រាកដ

$\Leftrightarrow x\left(x(k^2-1)+1\right)$ ជាការេប្រាកដ

តែដោយ $-(k^2-1)x+\left(x(k^2-1)+1\right)=1$ នោះតាមទ្រឹស្តីបទ *Bezout*

គេបាន: x និង $x(k^2-1)+1$ ជាចំនួនបឋមរវាងគ្នា

$\Rightarrow x$ និង $x(k^2-1)+1$ ត្រូវតែជាការេប្រាកដទាំងពីរ ។

ដូចនេះ x ជាការេប្រាកដ ។

លំហាត់ទី៤

គេឲ្យម៉ាទ្រីសនៃចំនួនពិតមិនអវិជ្ជមានមួយដែលមានលំដាប់ $(m\times n)$ ហើយ ជួរដេកនីមួយៗ និងជួររឈរនីមួយៗ មានយ៉ាងតិចធាតុវិជ្ជមានមួយ ។ ម្យ៉ាងទៀត បើជួរដេកមួយ និង ជួរឈរមួយប្រសព្វគ្នាត្រង់ធាតុជាចំនួនវិជ្ជមាន នោះផលបូកធាតុរបស់ពួកវាទាំងពីរ គឺ ស្មើគ្នា ។ ចូរស្រាយបញ្ជាក់ថា: $m=n$ ។

(Canadian Mathematical Olympiad 2006)

ដំណោះស្រាយ

តាង a_{ij} ជាធាតុស្ថិតនៅក្នុងជួរដេកទី i និង ជួរឈរទី j ហើយ តាង $S=\{(i,j):a_{ij}>0\}$ ។

ឧបមាថា r_i ជាផលបូកធាតុទាំងអស់ក្នុងជួរដេកទី i និង c_j ជាផលបូកធាតុក្នុងជួរឈរទី j នោះ $r_i=c_j$ ពេលណាដែល $(i,j)\in S$ ។

យើងបាន: $\sum\left\{\dfrac{a_{ij}}{r_i}:(i,j)\in S\right\}=\sum\left\{\dfrac{a_{ij}}{c_j}:(i,j)\in S\right\}$

ដោយ:

$$\sum\left\{\frac{a_{ij}}{r_i}:(i,j)\in S\right\}=\sum\left\{\frac{a_{ij}}{r_i}:1\le i\le m,1\le j\le n\right\}$$
$$=\sum_{i=1}^{m}\left(\frac{1}{r_i}\sum_{j=1}^{n}a_{ij}\right)=\sum_{i=1}^{m}\left(\frac{1}{r_i}\right)r_i=\sum_{i=1}^{m}1=m$$

ហើយ:

$$\sum\left\{\frac{a_{ij}}{c_j}:(i,j)\in S\right\}=\sum\left\{\frac{a_{ij}}{c_j}:1\le i\le m,1\le j\le n\right\}$$
$$=\sum_{j=1}^{n}\left(\frac{1}{c_j}\sum_{j=1}^{m}a_{ij}\right)=\sum_{j=1}^{n}\left(\frac{1}{c_j}\right)c_j=\sum_{j=1}^{n}1=n$$

ដូចនេះ $m=n$ ។

<u>លំហាត់ទី៨</u>

អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ មួយផ្ទៀងផ្ទាត់លក្ខខណ្ឌ៖ $f\left(f\left(f(0)\right)\right)=0$ និង $\left|f(a)-f(b)\right|\le|a-b|$ ចំពោះ $a,b\in\mathbb{R}$ ។

ស្រាយបញ្ជាក់ថា $f(0)=0$ ។

(Mongolia Mathematical Olympiad 2000)

<u>ដំណោះស្រាយ</u>

ចំពោះ $a,b\in\mathbb{R}$, យើងមាន: $\left|f(a)-f(b)\right|\le|a-b|$ នោះយើងបាន:

$$\left|f(0)\right|=\left|f(0)-0\right|\ge\left|f\left(f(0)\right)-f(0)\right|$$
$$\ge\left|f\left(f\left(f(0)\right)\right)-f\left(f(0)\right)\right|=\left|f\left(f(0)\right)\right| \quad (1)$$

ហើយ: $\left|f\left(f(0)\right)\right|=\left|f\left(f(0)\right)-0\right|\ge\left|f\left(f\left(f(0)\right)\right)-f(0)\right|$
$$=\left|f(0)\right| \qquad (2)$$

តាម (1) និង (2) ទាញបាន: $\left|f(0)\right|=\left|f\left(f(0)\right)\right|$

នាំឲ្យ $f(0)=\pm f\left(f(0)\right)$

$*$បើ $f(0)=f\left(f(0)\right)\Rightarrow f(0)=f\left(f(0)\right)=f\left(f\left(f(0)\right)\right)=0$

$*$បើ $f(0)=-f\left(f(0)\right)$

$\Rightarrow \left|f(0)\right|=\left|f(0)-0\right|\ge\left|f\left(f(0)\right)-f(0)\right|=2\left|f(0)\right|$

$\Rightarrow\left|f(0)\right|\le 0\Rightarrow f(0)=0$ ។

សរុបទាំងពីរករណី , ដូចនេះ $f(0)=0$ ។

<u>លំហាត់ទី៦</u>

គេឲ្យ (a_n) ជាស្វ៊ីតនៃចំនួនពិតដែលផ្ទៀងផ្ទាត់: $|a_{k+m}-a_k-a_m|\leq 1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន k និង m ។ ចូរស្រាយបញ្ជាក់ថា: ចំពោះគ្រប់ចំនួនគត់វិជ្ជមាន p និង q នោះគេបាន វិសមភាព:

$$\left|\frac{a_p}{p}-\frac{a_q}{q}\right|<\frac{1}{p}+\frac{1}{q}$$ ។

(IMO Longlists 1980)

<u>ដំណោះស្រាយ</u>

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន k និង m យើងមាន: $|a_{k+m}-a_k-a_m|\leq 1$ នោះយើងបាន:

$$-1\leq a_{k+m}-a_k-a_m\leq 1\Leftrightarrow a_{k+m}-1\leq a_k+a_m\leq a_{k+m}+1$$

យើងនឹងស្រាយតាមវិចារដោយកំនើនធៀបនឹង q ថា:

$$a_{pq}-(q-1)\leq qa_p\leq a_{pq}+(q-1) \qquad (*)$$

- ចំពោះ $q=1\Rightarrow(*):a_p\leq a_p\leq a_p$ ជាវិសមភាពពិត ។
- ឧបមាថាវិសមភាពនេះពិតដល់ q គឺថា:

$$a_{pq}-(q-1)\leq qa_p\leq a_{pq}+(q-1)$$

- ពិនិត្យចំពោះ $q+1$:

យើងមាន: $(q+1)a_p=qa_p+a_p\leq a_p+a_{pq}+(q-1)\leq a_{p+pq}+1$ $+(q-1)\ =\ a_{(q+1)p}+q$

ហើយ $(q+1)a_p=qa_p+a_p\geq a_p+a_{pq}-(q-1)\geq\ a_{p+pq}-1$ $-(q-1)=a_{(q+1)p}-q\ \Rightarrow\ a_{(q+1)p}-q\leq(q+1)a_p\leq a_{(q+1)p}+q$

នេះមានន័យថា: វិសមភាព $(*)$ ពិតដល់ $q+1$ ។

ដូច្នេះ $a_{pq}-(q-1)\leq qa_p\leq a_{pq}+(q-1)$ ចំពោះ $\forall p,q\in\mathbb{N}$ ។

ស្រាយដូចគ្នាដែរតាមវិចារដោយកំនើនធៀបនឹង p គេបាន ៖

$a_{pq}-(p-1)\le pa_q\le a_{pq}+(p-1)$ ចំពោះ $\forall p,q\in\mathbb{N}$ ។

យើងបានៈ

$$\left|qa_p-pa_q\right|\le\max\left\{\left|a_{pq}+(p-1)-\left(a_{pq}-(q-1)\right)\right|,\right.$$

$$\left.\left|a_{pq}+(q-1)-\left(a_{pq}-(p-1)\right)\right|\right\}=p+q-2<p+q$$

$\Rightarrow\quad\left|\frac{a_p}{p}-\frac{a_q}{q}\right|<\frac{1}{p}+\frac{1}{q}$ ចំពោះ $\forall p,q\in\mathbb{N}$ ។

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៧

តាង a ជាចំនួនគត់សេសមួយ ។ ចូរស្រាយបញ្ជាក់ថាៈ $a^{2^n}+2^{2^n}$ និង $a^{2^m}+2^{2^m}$ ជាចំនួនបឋមរវាងគ្នាចំពោះគ្រប់ចំនួនគត់វិជ្ជមាន n និង m ដែល $n\neq m$ ។

(Baltic Way 2001)

ដំណោះស្រាយ

ដោយមិនធ្វើឲ្យបាត់បង់លក្ខណៈទូទៅ , យើងសន្មតថា $m>n$ ។

ចំពោះចំនួនបឋម p ណាមួយដែលចែកដាច់ $a^{2^n}+2^{2^n}$ នោះគេបានៈ

$a^{2^n}\equiv-2^{2^n}\pmod p$

លើកអង្គទាំងពីរនៃសមីការនេះជាការចំនួន $m-n$ ដង គេបានៈ

$a^{2^m}\equiv 2^{2^m}\pmod p$ ហើយដោយ a ជាចំនួនគត់សេសនោះ $p\neq 2$

$\Rightarrow 2^{2^m}+2^{2^m}=2^{2^m+1}\not\equiv 0\pmod p$

$\Rightarrow a^{2^m} \equiv 2^{2^m} \equiv -2^{2^m} \pmod p$

$\Rightarrow a^{2^m} + 2^{2^m} \not\equiv 0 \pmod p \Rightarrow p$ ចែកមិនដាច់ $a^{2^m} + 2^{2^m}$

នេះបញ្ជាក់ថាៈ គ្រប់កត្តាបឋមនៃ $a^{2^n} + 2^{2^n}$ គឺចែកមិនដាច់ $a^{2^m} + 2^{2^m}$ ។

ដូចនេះ $a^{2^n} + 2^{2^n}$ និង $a^{2^m} + 2^{2^m}$ ជាចំនួនបឋមរវាងគ្នាចំពោះគ្រប់ចំនួនគត់វិជ្ជមាន n និង m ដែល $n \neq m$ ។

លំហាត់ទី៨

តាង a,b,c ជាបីចំនួនគត់ខុសៗគ្នា ។ $P(x)$ ជាពហុធាដែលមានមេគុណជាចំនួនគត់ ។ ចូរបង្ហាញថាៈ មិនអាចមានករណីដែល $P(a)=b$, $P(b)=c$ និង $P(c)=a$ នោះទេ ។

(USAMO 1974)

ដំណោះស្រាយ

យើងមាន $P(x)$ ជាពហុធាដែលមានមេគុណជាចំនួនគត់ ហើយ a,b,c ជាបីចំនួនគត់ខុសៗគ្នា នោះតាមទ្រឹស្តីបទផលគុណកត្តាយើងបានៈ

$a-b \mid P(a)-P(b), b-c \mid P(b)-P(c)$ និង $c-a \mid P(c)-P(a)$

$\Rightarrow \dfrac{P(a)-P(b)}{a-b}, \dfrac{P(b)-P(c)}{b-c}, \dfrac{P(c)-P(a)}{c-a}$ ជាចំនួនគត់

ឧបមាថាៈ $P(a)=b$, $P(b)=c$ និង $P(c)=a$

$\Rightarrow \dfrac{b-c}{a-b}, \dfrac{c-a}{b-c}, \dfrac{a-b}{c-a}$ សុទ្ធតែជាចំនួនគត់ដែលមានផលគុណស្មើនឹង 1

នោះយើងទាញបាន តម្លៃដាច់ខាតរបស់វានីមួយៗត្រូវតែស្មើនឹង 1 មានន័យថាៈ

$$\left|\frac{b-c}{a-b}\right| = \left|\frac{c-a}{b-c}\right| = \left|\frac{a-b}{c-a}\right| = 1 \Rightarrow |a-b| = |b-c| = |c-a|$$

ជាករណីមិនអាច ព្រោះ a,b,c ជាចំនួនគត់ ខុសៗគ្នា , នេះបញ្ជាក់ថា: ការឧបមាខាងលើគឺខុស ។

ដូចនេះ មិនអាចមានករណីដែល: $P(a)=b$, $P(b)=c$ និង $P(c)=a$ នោះទេ ។

<u>លំហាត់ទី៩</u>

ស្វ៊ីត $p_1, p_2, \ldots$ ត្រូវបានកំណត់ដូចតទៅ: $p_1 = 2$ និង ចំពោះ $n \geq 2$, p_n ជាតួចែកបឋមដែលធំបំផុតនៃ $p_1 p_2 \ldots p_{n-1} + 1$ ។

ចូរស្រាយបញ្ជាក់ថា: 5 មិនមែនជាតួនៃស្វ៊ីតនេះទេ ។

(Australia Mathematical Olympiad 1982)

<u>ដំណោះស្រាយ</u>

យើងមាន: $p_1 = 2$ និង p_2(តួចែកបឋមធំបំផុតនៃ $p_1 + 1 = 3$)$= 3$

ហើយចំពោះ $k > 1$ យើងមាន:

$p_k =$ តួចែកបឋមធំបំផុតនៃ $p_1 p_2 \ldots p_{k-1} + 1$ នោះ $p_k > 2$

ព្រោះ $p_1 p_2 \ldots p_{k-1} + 1$ ជាចំនួនគត់សេស ។

ឧបមាថា: 5 ជាតួនៃស្វ៊ីត (p_n) មានន័យថា $p_n = 5$ ចំពោះ n ណាមួយ

គេបាន: $p_1 p_2 \ldots p_{n-1} + 1 = 3^m.5^l$ ព្រោះ $p_1 p_2 \ldots p_{n-1} + 1$ ជាចំនួនគត់សេស ហើយ 5 ជាតួចែកបឋមធំបំផុតរបស់វា ។

យើងសង្កេតឃើញថា: ចំពោះ $m \geq 1$ នោះ $3^m.5^l \equiv 0 \pmod 3$

តែ $p_1 p_2 \ldots p_{n-1} + 1 = 2 \cdot 3 \cdot p_3 \cdots p_{n-1} + 1 \equiv 1 \pmod 3$

$\Rightarrow p_1 p_2 \ldots p_{n-1} + 1 = 3^m.5^l$ ជាសមភាពផ្ទៀងផ្ទាត់ លុះត្រាតែ: $m = 0$

ក្នុងករណីនេះ គេបាន:

$p_1p_2...p_{n-1} = 2\cdot 3\cdot p_3\cdots p_{n-1} = 5^l - 1$

$$= (5-1)\left(5^{l-1}+5^{l-2}+\cdots+1\right)$$

គឺថា: $2\cdot 3\cdot p_3\cdots p_{n-1} = 4\left(5^{l-1}+5^{l-2}+\cdots+1\right)$

សមភាពនេះមិនពិតទេព្រោះ អង្គទី១ $\not\equiv 0 \pmod 4$

(ព្រោះ $p_3, p_4, ..., p_{n-1}$ សុទ្ធតែជាចំនួនបឋម>2)

តែអង្គទី២ $\equiv 0 \pmod 4$, នេះបញ្ជាក់ថា: ការឧបមាខាងលើគឺខុស

មានន័យថា: $p_n \neq 5$ ចំពោះគ្រប់ n ។

ដូចនេះ 5 មិនមែនជាតួនៃស្វ៊ីត(p_n) នោះទេ ។

<u>លំហាត់ទី១០</u>

តាង $f:\mathbb{N}\to\mathbb{N}$ ជាអនុគមន៍មួយដែលផ្ទៀងផ្ទាត់:

$f(n+1) > f(f(n))$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

ចូរស្រាយបញ្ជាក់ថា: $f(n) = n$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

(IMO 1977)

<u>ដំណោះស្រាយ</u>

តាង $P(n)$ ជាសំណើមួយដែលថា:“ បើ $m \geq n$ នោះ $f(m) \geq n$ ” ។

តាមវិចារដោយកំនើន , យើងនឹងស្រាយថា $P(n)$ ជាសំណើពិត:

ដោយចំពោះគ្រប់ $m \geq 1, f(m) \geq 1$ នោះបញ្ជាក់ថា: $P(1)$ ជាសំណើពិត

ឧបមាថាសំណើ $P(n)$ ពិតដល់ n គឺថា: បើ $m \geq n$ នោះ $f(m) \geq n$

យើងនឹងស្រាយថា: $P(n+1)$ ពិតគឺត្រូវស្រាយថា:

បើ $m \geq n+1$ នោះ $f(m) \geq n+1$ ។

ដោយ $m \geq n+1$ ឬ $m-1 \geq n$

$\Rightarrow f(m-1) \geq n \Rightarrow f(f(m-1)) \geq n$

យើងបាន: $f(m) > f(f(m-1)) \geq n$ ទាញបាន: $f(m) \geq n+1$

មានន័យថា: $P(n+1)$ ជាសំណើពិត ។

ដូច្នេះជាទូទៅ បើ $m \geq n$ នោះ $f(m) \geq n$ ។

ក្នុងករណីពិសេសយើងបាន: $f(n) \geq n$ ចំពោះគ្រប់ $n \geq 1$ ។

$\Rightarrow f(n+1) > f(f(n)) \geq f(n)$ ទាញបាន: f ជាអនុគមន៍កើនដាច់ខាត ។

យើងឧបមាថា: មាន k ណាមួយដែលធ្វើឲ្យ $f(k) \neq k$ ។

$\Rightarrow f(k) > k \Leftrightarrow f(k) \geq k+1$

$\Rightarrow f(k+1) > f(f(k)) \geq f(k+1)$ នេះជាសមភាពមិនពិត

ដែលបញ្ជាក់ថា: គ្មានចំនួនគត់ k ណាមួយធ្វើឲ្យ $f(k) \neq k$ នោះឡើយ ។

ដូចនេះ $f(n) = n$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។

លំហាត់ទី១១

តាង p និង q ជាចំនួនកុំផ្លិចដែល: $q \neq 0$ ។ ចូរស្រាយបញ្ជាក់ថា: បើឫសទាំងអស់នៃសមីការ $x^2 + px + q^2 = 0$ មានតម្លៃដាច់ខាតដូចគ្នា នោះ $\frac{p}{q}$ ជាចំនួនពិត ។

(Romanian Mathematical Olympiad 1999)

ដំណោះស្រាយ

តាង x_1 និង x_2 ជាឫសនៃសមីការ ហើយ $r = |x_1| = |x_2|$ ។

តាមទ្រឹស្តីបទវ្យែត គេបាន: $x_1 + x_2 = -p$ និង $x_1 x_2 = q^2$

$$\Rightarrow \frac{p^2}{q^2} = \frac{(x_1+x_2)^2}{x_1x_2} = \frac{x_1}{x_2} + \frac{x_2}{x_1} + 2$$

$$= \frac{x_1\bar{x}_2}{|x_2|^2} + \frac{x_2\bar{x}_1}{|x_1|^2} + 2 = \frac{x_1\bar{x}_2}{r^2} + \frac{x_2\bar{x}_1}{r^2} + 2$$

$$= 2 + \frac{1}{r^2}(x_1\bar{x}_2 + x_2\bar{x}_1) = 2 + \frac{2}{r_2}\cdot \text{Re}(x_1\bar{x}_2)$$

ព្រោះតាមរូបមន្ត: $z + \bar{z} = 2\text{Re}(z)$

មានន័យថា: $\frac{p^2}{q^2}$ ជាចំនួនពិត (1)

ម្យ៉ាងទៀត យើងមាន: $\text{Re}\left(x_1\overline{x_2}\right) \geq -\left|x_1\overline{x_2}\right| = -|x_1|\left|\overline{x_2}\right| = -r^2$

$$\Rightarrow \frac{p^2}{q^2} \geq 0 \quad (2)$$

តាម (1) និង (2) ទាញបាន: $\frac{p}{q}$ ជាចំនួនពិត ។

ដូចនេះ: $\frac{p}{q}$ ជាចំនួនពិតមួយ , ត្រូវបានស្រាយបញ្ជាក់ ។

__លំហាត់ទី៦__

ស៊ីតហ្វីបូណាស៊ី $(F_n)_{n\geq 1}$ ត្រូវបានកំណត់ដោយ: $F_1 = F_2 = 1$ និង $F_{n+2} = F_{n+1} + F_n, n \geq 1$ ។ ចូរស្រាយបញ្ជាក់ថា:

$$F_{2n} = \frac{F_{2n+2}^3 + F_{2n-2}^3}{9} - 2F_{2n}^3 \quad \text{ចំពោះគ្រប់ } n \geq 2 \text{ ។}$$

(Korean Mathematics Competition 2000)

ដំណោះស្រាយ

យើងមាន:

$$F_{2n+2}=F_{2n+1}+F_{2n}=F_{2n}+F_{2n}+F_{2n-1}=2F_{2n}+F_{2n}-F_{2n-2}$$

$$\Rightarrow F_{2n+2}=3F_{2n}-F_{2n-2}$$

$$\Rightarrow F_{2n+2}^3=\left(3F_{2n}-F_{2n-2}\right)^3$$

$$=27F_{2n}^3-F_{2n-2}^3-9F_{2n}F_{2n-2}\left(3F_{2n}-F_{2n-2}\right)$$

$$\Rightarrow F_{2n+2}^3+F_{2n-2}^3=27F_{2n}^3-9F_{2n}F_{2n-2}F_{2n+2}\qquad(*)$$

ម្យ៉ាងទៀត យើងមាន: $F_{2n}+F_{2n-4}=3F_{2n-2}$

$$\Rightarrow F_{2n}\left(F_{2n}+F_{2n-4}\right)=3F_{2n}F_{2n-2}=\left(F_{2n+2}+F_{2n-2}\right)F_{2n-2}$$

$$\Rightarrow F_{2n}^2-F_{2n-2}F_{2n+2}=F_{2n-2}^2-F_{2n-4}F_{2n}=\cdots=F_4^2-F_2F_6$$

$$=3^2-1\cdot 8=1\quad\Rightarrow F_{2n-2}F_{2n+2}=F_{2n}^2-1$$

$\Rightarrow$ តាម $(*)$ គេបាន: $F_{2n+2}^3+F_{2n-2}^3=27F_{2n}^3-9F_{2n}\left(F_{2n}^2-1\right)$

$$\Leftrightarrow\ F_{2n}=\frac{F_{2n+2}^3+F_{2n-2}^3}{9}-2F_{2n}^3$$

ដូចនេះសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី១៣

ចូរស្រាយបញ្ជាក់ថាឫសទាំង5នៃសមីការ:

$a_5x^5+a_4x^4+a_3x^3+a_2x^2+a_1x+a_0=0$ មិនអាចជាចំនួនពិតទាំងអស់បានទេ បើ $2a_2^4<5a_5a_3$ ។

(USAMO 1983)

ដំណោះស្រាយ

តាង r_i , $(i=1,2,3,4,5)$ ជាឫសទាំង 5 នៃសមីការ:

$a_5x^5+a_4x^4+a_3x^3+a_2x^2+a_1x+a_0=0$ នោះតាមទ្រឹស្តីបទវ្យែត

គេបាន: $\sum_{i=1}^{5} r_i = -\frac{a_4}{a_5}$ ហើយ $\sum_{1\le i<j\le 5} r_ir_j = \frac{a_3}{a_5}$ ។

តាមលក្ខខ័ណ្ឌ: $2a_2^4 < 5a_5a_3 \Leftrightarrow 2\left(\frac{a_4}{a_5}\right)^2 < 5\cdot\frac{a_3}{a_5}$

$$\Leftrightarrow 2\left(\sum_{i=1}^{5} r_i\right)^2 < 5\cdot\sum_{1\le i<j\le 5} r_ir_j$$

$$\Leftrightarrow 2\cdot\sum_{i=1}^{5} r_i^2 + 4\cdot\sum_{1\le i<j\le 5} r_ir_j < 5\cdot\sum_{1\le i<j\le 5} r_ir_j$$

$$\Leftrightarrow 2\cdot\sum_{i=1}^{5} r_i^2 < \sum_{1\le i<j\le 5} r_ir_j \qquad (*)$$

យើងឧបមាថា: r_i , $(i=1,2,3,4,5)$ សុទ្ធតែជាចំនួនពិតនោះ

យើងបាន: $r_i^2+r_j^2 \ge 2r_ir_j \quad ,(1\le i<j\le 5)$

$$\Rightarrow \sum_{1\le i<j\le 5}\left(r_i^2+r_j^2\right) \ge 2\cdot\sum_{1\le i<j\le 5}\left(r_ir_j\right)$$

$$\Leftrightarrow 2\sum_{i=1}^{5} r_i^2 \ge \sum_{1\le i<j\le 5} r_ir_j$$ ផ្ទុយពីលក្ខខ័ណ្ឌ $(*)$

នេះមានន័យថា:ការឧបមាខាងលើគឺខុស ។

ដូចនេះ ឫសទាំង5នៃសមីការ:

$a_5x^5+a_4x^4+a_3x^3+a_2x^2+a_1x+a_0=0$ មិនអាចជាចំនួនពិតទាំងអស់បានទេ បើ $2a_2^4 < 5a_5a_3$ ។

<u>លំហាត់ទី១៨</u>

តាង x,y ជាចំនួនគត់ដែល $x,y\neq -1$ ហើយផ្ទៀងផ្ទាត់:

$\frac{`x^4-1}{y+1}+\frac{y^4-1}{x+1}\in\mathbb{Z}$ ។ ចូរស្រាយបញ្ជាក់ថា:

$x^4y^{44}-1$ ចែកដាច់នឹង $x+1$ ។

(Vietnam Mathematical Olympiad 2007)

<u>ដំណោះស្រាយ</u>

យើងតាង $\frac{x^4-1}{y+1}=\frac{a}{b}$ និង $\frac{y^4-1}{x+1}=\frac{c}{d}$ ដែល $b,d\neq 0$ និង $(a,b)=(c,d)=1$ ។

តាមសម្មតិកម្ម: $\frac{`x^4-1}{y+1}+\frac{y^4-1}{x+1}\in\mathbb{Z}$

$\Rightarrow \frac{a}{b}+\frac{c}{d}=\frac{ad+bc}{bd}\in\mathbb{Z}\Rightarrow bd\,|\,ad+bc\ \Rightarrow d\,|\,ad+bc\Rightarrow d\,|\,bc$

$\Rightarrow d\,|\,b$ (ព្រោះ $(c,d)=1$) $(*)$

ម្យ៉ាងទៀត: $\frac{ac}{bd}=(x+1)\left(x^2+1\right)(y+1)\left(y^2+1\right)\in\mathbb{Z}\ \Rightarrow bd\,|\,ac$

$\Rightarrow b\,|\,ac\Rightarrow b\,|\,c$ (ព្រោះ $(a,b)=1$) $(**)$

តាម $(*)$ និង $(**)$ គេបាន: $d\,|\,c\Rightarrow d=1\Rightarrow\frac{y^4-1}{x+1}=c\in\mathbb{Z}$

$\Rightarrow x+1\,|\,y^4-1$

យើងមាន:

$$x^4y^{44}-1=x^4y^{44}-y^{44}+y^{44}-1$$

$$=y^{44}\left(x^4-1\right)+\left(y^4-1\right)m\quad,(m\in\mathbb{Z})$$

$$= y^{44}(x-1)(x+1)\left(x^2+1\right)+\left(y^4-1\right)m$$

$$\Rightarrow\ x+1 \mid x^4 y^{44}-1$$

ដូចនេះ $x^4y^{44}-1$ ចែកដាច់នឹង $x+1$ ។

លំហាត់ទី១៥

តាង $\{a_n\}_{n\geq 0}$ ជាស្វ៊ីតនៃចំនួនពិតដែលផ្ទៀងផ្ទាត់: $a_{n+1}\geq a_n^2+\frac{1}{5}$ ចំពោះគ្រប់ $n\geq 0$ ។ ចូរស្រាយបញ្ជាក់ថា: $\sqrt{a_{n+5}}\geq a_{n-5}^2$ ចំពោះគ្រប់ $n\geq 5$ ។

(USA , Team Selection Test 2001)

ដំណោះស្រាយ

យើងមាន:

$$\begin{cases} a_{n+1}\geq a_n^2+\frac{1}{5} \\ a_{n+2}\geq a_{n+1}^2+\frac{1}{5} \\ a_{n+3}\geq a_{n+2}^2+\frac{1}{5} \\ a_{n+4}\geq a_{n+3}^2+\frac{1}{5} \\ a_{n+5}\geq a_{n+4}^2+\frac{1}{5} \end{cases}$$

បូកអង្គនិងអង្គនៃវិសមភាពទាំងអស់ខាងលើនេះ គេបាន:

$$a_{n+5} \geq a_n^2 + \left(a_{n+1}^2 - a_{n+1} + \frac{1}{4}\right) + \left(a_{n+2}^2 - a_{n+2} + \frac{1}{4}\right)$$

$$+\left(a_{n+3}^2 - a_{n+3} + \frac{1}{4}\right) + \left(a_{n+4}^2 - a_{n+4} + \frac{1}{4}\right)$$

$$= a_n^2 + \left(a_{n+1} - \frac{1}{2}\right)^2 + \left(a_{n+2} - \frac{1}{2}\right)^2 + \left(a_{n+3} - \frac{1}{2}\right)^2$$

$$+\left(a_{n+4} - \frac{1}{2}\right)^2 \geq a_n^2 \quad \Rightarrow a_{n+5} \geq a_n^2 \quad ,\forall\ n \geq 0$$

$\Rightarrow a_n \geq a_{n-5}^2 \ ,\forall n \geq 5 \quad \Rightarrow a_{n+5} \geq a_{n-5}^4 \ ,\forall n \geq 5$

$\Rightarrow \sqrt{a_{n+5}} \geq a_{n-5}^2 \ ,\forall n \geq 5$ ។

ដូចនេះ $\sqrt{a_{n+5}} \geq a_{n-5}^2$ ចំពោះគ្រប់ $n \geq 5$ ។

លំហាត់ទី១៦

គេតាង $\{x\}$ ជាផ្នែកទសភាគនៃចំនួនពិត x ។ ចូរស្រាយបញ្ជាក់ថា:

$\lim_{n\to\infty}\left\{\left(2+\sqrt{3}\right)^n\right\} = 1$ ។

(Australia mathematical Olympiad 1982)

ដំណោះស្រាយ

តាមរូបមន្តនៃការពន្លាតទ្វេធា *Newton*, យើងសង្កេតឃើញថា:

$\left(2-\sqrt{3}\right)^n = a - b\sqrt{3}$ និង $\left(2+\sqrt{3}\right)^n = a + b\sqrt{3}$

ដែល a,b ជាចំនួនគត់ ។

យើងបាន: $\left(2-\sqrt{3}\right)^n+\left(2+\sqrt{3}\right)^n=2a$ ជាចំនួនគត់

$$\Rightarrow \left\{\left(2-\sqrt{3}\right)^n\right\}+\left\{\left(2+\sqrt{3}\right)^n\right\}=1$$

$$\Rightarrow \left\{\left(2+\sqrt{3}\right)^n\right\}=1-\left\{\left(2-\sqrt{3}\right)^n\right\}$$

ដោយ $0<2-\sqrt{3}<1 \Rightarrow 0<\left(2-\sqrt{3}\right)^n<1$

$$\Rightarrow \left\{\left(2-\sqrt{3}\right)^n\right\}=\left(2-\sqrt{3}\right)^n$$

យើងបាន: $\left\{\left(2+\sqrt{3}\right)^n\right\}=1-\left(2-\sqrt{3}\right)^n$

$$\Rightarrow \lim_{n\to\infty}\left\{\left(2+\sqrt{3}\right)^n\right\}=1-\lim_{n\to\infty}\left(2-\sqrt{3}\right)^n=1$$

ព្រោះ $0<2-\sqrt{3}<1 \Rightarrow \lim_{n\to\infty}\left(2-\sqrt{3}\right)^n=0$ ។

ដូចនេះ $\lim_{n\to\infty}\left\{\left(2+\sqrt{3}\right)^n\right\}=1$ ត្រូវបានស្រាយបញ្ជាក់ ។

<u>លំហាត់ទី១៧</u>

តាង $f(x)=x^2+2007x+1$ ។ ចូរស្រាយបញ្ជាក់ថា:
ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n , សមីការ $f\left(f\left(\ldots\left(f(x)\right)\ldots\right)\right)=0$
(មាន n ដងនៃ f) , មានយ៉ាងតិចឫសជាចំនួនពិតមួយ ។

(Brazil mathematical Olympiad 2007)

ដំណោះស្រាយ

តាង $G(x)=f\left(f\left(...\left(f(x)...\right)\right)\right)$, (មាន n ដងនៃ f) ។

យើងសង្កេតឃើញថា:

បើ $x\to\infty \Rightarrow f(x)=x^2+2007x+1$

$$=x^2\left(1+\frac{2007}{x}+\frac{1}{x^2}\right)\to+\infty$$

$\Rightarrow G(x)\to+\infty$

$\Rightarrow$ បើ $x\to\infty\Rightarrow G(x)\to+\infty$

នេះមានន័យថា: ប្រាកដជាមានចំនួនពិត α មានតម្លៃធំគ្រប់គ្រាន់មួយ ដែល $G(\alpha)>0 \quad (1)$

ម្យ៉ាងទៀត: យើងតាង β ជាឫសមួយនៃសមីការ:

$f(x)=x \Leftrightarrow x^2+2006x+1=0$ ដែលជាសមីការមានឫសសុទ្ធតែជាចំនួនពិតវិជ្ជមាននោះយើងទាញបាន: $\beta<0$ ។

$\Rightarrow G(\beta)=\beta<0 \quad (2)$

តាម (1) និង (2) គេបាន: $G(\alpha)\cdot G(\beta)<0$,

នោះតាមទ្រឹស្តីបទតម្លៃកណ្តាល: $\exists x$ មួយដែល $x\in(\alpha,\beta)$ ធ្វើឲ្យ $G(x)=0$ ។

ដូចនេះ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ,

សមីការ $G(x)=f\left(f\left(...\left(f(x)\right)...\right)\right)=0$ (មាន n ដងនៃ f),

មានយ៉ាងតិចឫសជាចំនួនពិតមួយ ។

លំហាត់ទី១៨

គេឲ្យអនុគមន៍: $f(x)=\cos(a_1+x)+\frac{1}{2}\cos(a_2+x)+$ $\frac{1}{4}\cos(a_3+x)+\cdots+\frac{1}{2^{n-1}}\cos(a_n+x)$ ដែល a_i ជាចំនួនពិតថេរ និង អថេរពិត x, ចូរស្រាយបញ្ជាក់ថា: បើ $f(x_1)=f(x_2)=0$ នោះ គេបាន: x_1-x_2 ជាពហុគុណនៃ π ។

(IMO 1969)

ដំណោះស្រាយ

យើងមាន: $f(x)=\cos(a_1+x)+\frac{1}{2}\cos(a_2+x)+\frac{1}{4}\cos(a_3+x)$

$$+\cdots+\frac{1}{2^{n-1}}\cos(a_n+x) \qquad (*)$$

$$\Rightarrow f(-a_1)=\cos 0+\frac{1}{2}\cos(a_2-a_1)+\cdots+\frac{1}{2^{n-1}}\cos(a_n-a_1)$$

$$\Rightarrow f(-a_1)\geq 1-\frac{1}{2}-\frac{1}{4}-\cdots\frac{1}{2^{n-1}}=1-\left(1-\frac{1}{2^{n-1}}\right)>0$$

នេះបញ្ជាក់ថាអនុគមន៍ f(x) មិនមែនស្មើនឹង 0 គ្រប់ x នោះទេ ។

ម្យ៉ាងទៀត:

$$f(x)=\sum_{k=1}^{n}\frac{1}{2^{k-1}}\cdot\cos(a_k+x)$$

$$=\sum_{k=1}^{n}\left(\frac{1}{2^{k-1}}\cdot\cos a_k\cdot\cos x-\frac{1}{2^{k-1}}\cdot\sin a_k\cdot\sin x\right)$$

$$=\cos x\cdot\sum_{k=1}^{n}\frac{1}{2^{k-1}}\cdot\cos a_k-\sin x\cdot\sum_{k=1}^{n}\frac{1}{2^{k-1}}\cdot\sin a_k$$

តាង $A=\sum_{k=1}^{n}\frac{1}{2^{k-1}}\cdot\cos a_k$ និង $B=\sum_{k=1}^{n}\frac{1}{2^{k-1}}\cdot\sin a_k$

ដែល A និង B មិនអាចស្មើនឹង 0 ព្រមគ្នានោះទេ ព្រោះ បើ

$A=B=0$ នោះ $f(x)=0$ គ្រប់ x ដែលផ្ទុយពី $(*)$ ។

ក្នុងករណីនេះ , យើងបាន:

$$\begin{aligned} f(x) &= A\cdot\cos x - B\cdot\sin x \\ &= \sqrt{A^2+B^2}\left(\sin\alpha\cdot\cos x-\cos\alpha\cdot\sin x\right) \\ &= \sqrt{A^2+B^2}\cdot\sin(\alpha-x) \quad ,\left(\sqrt{A^2+B^2}\neq 0\right) \end{aligned}$$

ដែល $\sin\alpha=\frac{A}{\sqrt{A^2+B^2}}$ និង $\cos\alpha=\frac{B}{\sqrt{A^2+B^2}}$ ។

ដោយ $f(x_1)=f(x_2)=0 \Rightarrow \sin(\alpha-x_1)=\sin(\alpha-x_1)=0$

$$\Rightarrow \begin{cases}\alpha-x_1=k_1\pi \\ \alpha-x_2=k_2\pi\end{cases},(k_1,k_2\in\mathbb{Z}) \quad \Rightarrow x_1-x_2=(k_1-k_2)\pi$$

$\Rightarrow$ x_1-x_2 ជាពហុគុណ នៃ π ។

លំហាត់ទី១៩

តាង $n>3$ និង $a_1,a_2,...,a_n$ ជាចំនួនពិតដែលផ្ទៀងផ្ទាត់:

$a_1+a_2+\cdots+a_n\geq n$ និង ${a_1}^2+{a_2}^2+\cdots+{a_n}^2\geq n^2$ ។

ចូរស្រាយបញ្ជាក់ថា: $\max\{a_1,a_2,...,a_n\}\geq 2$ ។

(USAMO 1999)

ដំណោះស្រាយ

យើងឧបមាថា: $a_i < 2$ ចំពោះគ្រប់ $i = 1, 2, ..., n$ ។

តាង $x_i = 2 - a_i > 0$ គេបាន:

$$\sum_{i=1}^{n} x_i = \sum_{i=1}^{n} (2 - a_i) = \sum_{i=1}^{n} 2 - \sum_{i=1}^{n} a_i = 2n - \sum_{i=1}^{n} a_i \le 2n - n = n$$

ហើយ $n^2 \le \sum_{i=1}^{n} a_i^2 = \sum_{i=1}^{n} (2 - x_i)^2 = 4n - 4\sum_{i=1}^{n} x_i + \sum_{i=1}^{n} x_i^2 \quad (1)$

តែចំពោះ $x_i > 0$ គេបាន: $\sum_{i=1}^{n} x_i^2 \le \left(\sum_{i=1}^{n} x_i\right)^2 \le n \cdot \sum_{i=1}^{n} x_i$

$\Rightarrow n^2 \le 4n - 4\sum_{i=1}^{n} x_i + n \cdot \sum_{i=1}^{n} x_i$

$\Leftrightarrow (n-4)\left(n - \sum_{i=1}^{n} x_i\right) \le 0$, វិសមភាពនេះមិនពិតព្រោះ $n \ge 4$ និង

$\sum_{i=1}^{n} x_i \le n$ ។

នាំឲ្យការឧបមាខាងលើគឺខុស មានន័យថា: ចំនួន $a_i, (i = 1, 2, ..., n)$ មិនអាចសុទ្ធតែតូចជាង 2 ទេគឺត្រូវមានយ៉ាងហោចណាស់ a_i មួយដែរដែល ≥ 2 ។

ដូចនេះ $\max\{a_1, a_2, ..., a_n\} \ge 2$ ។

លំហាត់ទី២០

គេកំណត់ស្វ៊ីតនៃអនុគមន៍ $\left(f_n(x)\right)_{n\in\mathbb{N}_0}$ ដូចតទៅ: $f_0(x)=1,$
$f_1(x)=x$ និង $\left(f_n(x)\right)^2-1=f_{n-1}(x)\cdot f_{n+1}(x)$,
ចំពោះគ្រប់ $n\geq 1$ ។ ចូរស្រាយបញ្ជាក់ថា: ចំពោះn នីមួយៗ ,
$f_n(x)$ ជាពហុធាដែលមានមេគុណជាចំនួនគត់ ។

(India Mathematical Olympiad 2012)

ដំណោះស្រាយ

ចំពោះគ្រប់ $n\geq 1,$ យើងមាន: $\left(f_n(x)\right)^2-1=f_{n-1}(x)\cdot f_{n+1}(x)$

$$\Rightarrow\left(f_{n+1}(x)\right)^2-1=f_n(x)\cdot f_{n+2}(x)$$

ដកអង្គនិងអង្គនៃសមភាពទាំងពីរនេះ, យើងបាន:

$$\left(f_n(x)\right)^2-\left(f_{n+1}(x)\right)^2=f_{n-1}(x)\cdot f_{n+1}(x)-f_n(x)\cdot f_{n+2}(x)$$

$$\Leftrightarrow f_n(x)\left(f_n(x)+f_{n+2}(x)\right)=f_{n+1}(x)\left(f_{n-1}(x)+f_{n+1}(x)\right)$$

$$\Rightarrow\frac{f_{n+2}(x)+f_n(x)}{f_{n+1}(x)}=\frac{f_{n+1}(x)+f_{n-1}(x)}{f_n(x)}=\cdots=\frac{f_2(x)+f_0(x)}{f_1(x)}$$

$$=x\quad\Rightarrow f_{n+1}(x)=xf_n(x)-f_{n-1}(x)\quad ,n\geq 1$$

តាមវិចារដោយកំនើន, យើងនឹងអាចស្រាយបានថា: $f_n(x)$ ជាពហុធាមានមេគុណជាចំនួនគត់ ។

ដូចនេះ ចំពោះn នីមួយៗ , $f_n(x)$ ជាពហុធាដែលមានមេគុណជាចំនួនគត់ ។

លំហាត់ទី២១

តាង k,m,n ជាចំនួនគត់វិជ្ជមានដែលផ្ទៀងផ្ទាត់: $k>n>1$ និង $(k,n)=1$ ។ ចូរស្រាយបញ្ជាក់ថា: បើ $k-n|k^m-n^{m-1}$ នោះ $k\le 2n-1$ ។

(Indonesia National Science Olympiad 2003)

ដំណោះស្រាយ

យើងមាន: $k^m-n^m=(k-n)\left(k^{m-1}+k^{m-2}\cdot n+\cdots+k\cdot n^{m-2}+n^{m-1}\right)$

$\Rightarrow k-n|k^m-n^m$ តែតាមសម្មតិកម្ម: $k-n|k^m-n^{m-1}$

$\Rightarrow k-n|\left(k^m-n^{m-1}\right)-\left(k^m-n^m\right)$

$\Leftrightarrow k-n|n^m-n^{m-1}=n^{m-1}(n-1) \qquad (1)$

ដោយ $(k,n)=1 \Rightarrow (k-n,n)=1 \Rightarrow \left(k-n,n^{m-1}\right)=1 \quad (2)$

តាម (1) និង (2) គេទាញបាន: $k-n|n-1$

ដោយសារតែ $k>n>1$, យើងបាន: $k-n\le n-1\Leftrightarrow k\le 2n-1$

ដូចនេះ $k\le 2n-1$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២២

តាង a,b ជាចំនួនពិតដែលផ្ទៀងផ្ទាត់: $3^a+13^b=17^a$ និង $5^a+7^b=11^b$ ។ ចូរស្រាយបញ្ជាក់ថា: $a<b$ ។

(Romanian Mathematical Olympiad 2002)

ដំណោះស្រាយ

យើងឧបមាថា: $a \geq b$ នោះ $13^b \leq 13^a$ និង $5^b \leq 5^a$

តាមសម្មតិកម្ម: $3^a + 13^b = 17^a \Rightarrow 3^a + 13^a \geq 17^a$

$$\Leftrightarrow \left(\frac{3}{17}\right)^a + \left(\frac{13}{17}\right)^a \geq 1$$

ពិនិត្យអនុគមន៍: $f(x) = \left(\frac{3}{17}\right)^x + \left(\frac{13}{17}\right)^x$, $f(x)$ជាអនុគមន៍ចុះ

ជានិច្ច ហើយ $f(1) = \frac{3}{17} + \frac{13}{17} = \frac{16}{17} < 1 \Rightarrow f(a) \geq 1 > f(1)$

$\Rightarrow a < 1 \quad (*)$

ម្យ៉ាងទៀត: $5^a + 7^b = 11^b \Rightarrow 5^b + 7^b \leq 11^b$

$$\Leftrightarrow \left(\frac{5}{11}\right)^b + \left(\frac{7}{11}\right)^b \leq 1$$

ពិនិត្យអនុគមន៍: $g(x) = \left(\frac{5}{11}\right)^x + \left(\frac{7}{11}\right)^x$, $g(x)$ ជាអនុគមន៍ចុះ

ជានិច្ច ហើយ $g(1) = \frac{5}{11} + \frac{7}{11} = \frac{12}{11} > 1 \Rightarrow g(b) \leq 1 < g(1)$

$\Rightarrow b > 1 \quad (**)$

តាម $(*)$ និង $(**)$ គេទាញបាន: $a < 1 < b$,វិសមភាពនេះផ្ទុយពីការឧបមាខាងដើមដែលថា: $a \geq b$ ។

ដូចនេះ $a < b$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៣

តាង a,b,c ជាចំនួនគត់វិជ្ជមាន ។

ចូរស្រាយបញ្ជាក់ថា: បីចំនួន $a^2+b+c\,,b^2+c+a\,,c^2+a+b$ មិនអាចជាការេប្រាកដទាំងអស់បានទេ ។

(APMO 2011)

ដំណោះស្រាយ

ឧបមាថាបីចំនួន $a^2+b+c, b^2+c+a, c^2+a+b$ សុទ្ធតែជាការេប្រាកដ

ដោយ a^2+b+c ជាការេប្រាកដធំជាង a^2 $\Rightarrow a^2+b+c \geq (a+1)^2$

$\Leftrightarrow b+c \geq 2a+1$

សម្រាយដូចគ្នាដែរ គេបាន: $c+a \geq 2b+1$ និង $a+b \geq 2c+1$ ។

បូកអង្គនិងអង្គនៃវិសមភាពទាំងបីខាងលើ យើងបាន:

$2(a+b+c) \geq 2(a+b+c)+3$ ជាវិសមភាពមិនពិត ។

នេះបញ្ជាក់ថា: ការឧបមាខាងលើគឺខុស ។

ដូចនេះ បីចំនួន $a^2+b+c, b^2+c+a, c^2+a+b$ មិនអាចជាការេប្រាកដទាំងអស់បានទេ ។

លំហាត់ទី២៤

តាង $\{a_n\}$ ជាស្វ៊ីតមួយដែលផ្ទៀងផ្ទាត់: $a_1=5$ និង

$a_n=\sqrt[n]{a_{n-1}^{n-1}+2^{n-1}+2\cdot 3^{n-1}}$ ចំពោះគ្រប់ $n \geq 2$ ។

ចូរស្រាយបញ្ជាក់ថា: $\{a_n\}$ ជាស្វ៊ីតចុះ ។

(Vietnam Mathematical Olympiad 2010)

ដំណោះស្រាយ

ចំពោះគ្រប់ $n\geq 2$, យើងមាន: $a_n=\sqrt[n]{a_{n-1}^{n-1}+2^{n-1}+2\cdot 3^{n-1}}$

$\Leftrightarrow a_n^n=a_{n-1}^{n-1}+2^{n-1}+2\cdot 3^{n-1}$

យើងបាន:

$$a_2^2=a_1+2+2\cdot 3$$
$$a_3^3=a_2^2+2^2+2\cdot 3^2$$
$$a_4^4=a_3^3+2^3+2\cdot 3^3$$
$$\dots\dots\dots\dots\dots\dots\dots\dots$$
$$a_n^n=a_{n-1}^{n-1}+2^{n-1}+2\cdot 3^{n-1}$$

បូកអង្គនិងអង្គ:

$$a_n^n=a_1+\left(2+2^2+\cdots+2^{n-1}\right)+2\left(3+3^2+\cdots+3^{n-1}\right)$$
$$=5+2\cdot\frac{2^{n-1}-1}{2-1}+2\cdot 3\cdot\frac{3^{n-1}-1}{3-1}=5+2^n-2+3^n-3=2^n+3^n$$

$\Rightarrow a_n=\sqrt[n]{2^n+3^n}=3\sqrt[n]{1+\left(\frac{2}{3}\right)^n}=3\sqrt[n]{1+f_n}$ ដែល $f_n=\left(\frac{2}{3}\right)^n$

ដោយ $0<\frac{2}{3}<1$ នោះ $0<f_n<f_{n-1}\Rightarrow 1<1+f_n<1+f_{n-1}$

យើងបាន: $1<(1+f_n)^{\frac{1}{n}}<(1+f_{n-1})^{\frac{1}{n}}\quad (1)$

ម្យ៉ាងទៀត: $\frac{1}{n}<\frac{1}{n-1}\quad ,\forall n\geq 2$

$\Rightarrow (1+f_{n-1})^{\frac{1}{n}}<(1+f_{n-1})^{\frac{1}{n-1}}\ ,\forall n\geq 2\ \ (2)$

តាម (1) និង (2) យើងបាន: $(1+f_n)^{\frac{1}{n}}<(1+f_{n-1})^{\frac{1}{n-1}}$

$\Rightarrow 3\sqrt[n]{1+f_n} < 3^{n-1}\sqrt{1+f_{n-1}} \Leftrightarrow a_n < a_{n-1}$, $\forall n \geq 2$

ដូចនេះ $\{a_n\}$ ជាស្វ៊ីតចុះ ។

លំហាត់ទី២៨

គេឲ្យ n, p ជាចំនួនគត់ដែល $n > 1$ និង p ជាចំនួនបឋម ។

បើ $n|p-1$ និង $p|n^3-1$, ចូរបង្ហាញថា: $4p-1$ ជាការេប្រាកដ ។

(Argentina ,Team Selection Test 2005)

ដំណោះស្រាយ

យើងមាន: $p|n^3-1 \Leftrightarrow p|(n-1)(n^2+n+1)$

ឧបមាថា: $p|n-1 \Rightarrow n-1 \geq p > p-1$, តែ $n|p-1 \Rightarrow p-1 \geq n$

$\Rightarrow n-1 > n$ ជាវិសមភាពមិនពិត ។

មានន័យថា: $p\nmid n-1$ នោះយើងទាញបាន: $p|n^2+n+1$, (p ជាចំនួនបឋម)

ដោយ $n|p-1$ នោះ $p-1 = nk \Leftrightarrow p = nk+1$ ចំពោះចំនួនគត់ $k \geq 1$

យើងបាន: $p|(n^2+n+1)-p \Leftrightarrow p|(n^2+n+1)-(nk+1)$

$\Leftrightarrow p|n(n-k+1)$

បើ $p|n$, នោះតាមសម្មតិកម្ម: $n|p-1$ គេទាញបាន: $p|p-1$ ដែលជាករណីមិនអាច , ដូច្នេះ យើងបាន: $p|n-k+1 \Rightarrow n-k+1 \geq p$ ឬ

$n-k+1=0$

បើ $n-k+1 \geq p = nk+1$ នោះ $n(k-1)+k \leq 0$, ជាវិសមភាពមិនពិត

នេះបញ្ជាក់ថា: $n-k+1=0$ នោះ $k=n+1$

$\Rightarrow p = nk+1 = n(n+1)+1 = n^2+n+1$

$\Rightarrow 4p-3=4n^2+4n+1=(2n+1)^2$

ដូចនេះ $4p-1$ ជាការេប្រាកដ ។

លំហាត់ទី២៦

តាង $x_1, x_2, \dots, x_{100}$ ជាចំនួនពិតមិនអវិជ្ជមានដែលផ្ទៀងផ្ទាត់:

$x_i + x_{i+1} + x_{i+2} \le 1$ ចំពោះគ្រប់ $i=1,2,\dots,100$ (យើងយក $x_{101}=x_1$, $x_{102}=x_2$) ។ ចូរកំណត់តម្លៃអតិបរមាដែលអាចនៃផលបូក:

$S=\sum_{i=1}^{100} x_i x_{i+2}$ ។

(IMO Shortlist 2010)

ដំណោះស្រាយ

ចំពោះគ្រប់ $i=1,2,\dots,100$ យើងមាន: $x_i + x_{i+1} + x_{i+2} \le 1$

$\Leftrightarrow x_{i+2} \le 1 - x_i - x_{i+1}$

យើងបាន:

$$S=\sum_{i=1}^{100} x_i x_{i+2} \le \sum_{i=1}^{100} x_i\left(1-x_i+x_{i+1}\right)=\sum_{i=1}^{100} x_i - \sum_{i=1}^{100} x_i^{\,2} - \sum_{i=1}^{100} x_i x_{i+1}$$

$$=\sum_{i=1}^{n} x_i - \frac{1}{2}\sum_{i=1}^{n}\left(x_i+x_{i+1}\right)^2$$

តាមវិសមភាព $Cauchy-schwarz:$

$$\sum_{i=1}^{100}\left(x_i+x_{i+1}\right)^2 \ge \frac{1}{100}\left(\sum_{i=1}^{100}\left(x_i+x_{i+1}\right)\right)^2$$

ដូច្នេះ $S \le \sum_{i=1}^{100} x_i - \frac{1}{200}\left(\sum_{i=1}^{100}(x_i + x_{i+1})\right)^2 = \sum_{i=1}^{100} x_i - \frac{2}{100}\left(\sum_{i=1}^{100} x_i\right)^2$

$$= \frac{2}{100}\left(\sum_{i=1}^{100} x_i\right)\left(\frac{100}{2} - \sum_{i=1}^{100} x_i\right)$$

ដោយប្រើវិសមភាព $AM - GM$ គេបាន:

$$S \le \frac{2}{100} \cdot \left(\frac{1}{2}\left(\sum_{i=1}^{100} x_i + \frac{100}{2} - \sum_{i=1}^{100} x_i\right)\right)^2 = \frac{2}{100}\left(\frac{100}{4}\right)^2 = \frac{25}{2}$$

ដូចនេះ $S_{\max} = \frac{25}{2}$ ។

<u>លំហាត់ទី២៧</u>

ចូររកគ្រប់អនុគមន៍ $f : \Re \to \Re$ ដែលផ្ទៀងផ្ទាត់: $\forall x \in \mathbb{R}$,

$f(x) = \max(2xy - f(y))$ ដែល $y \in \mathbb{R}$ ។

(Morocco Mathematical Olympiad 2011)

<u>ដំណោះស្រាយ</u>

តាមសម្មតិកម្ម: ចំពោះចំនួនពិត x ណាមួយ , យើងបាន:

$f(x) \ge 2xy - f(y)$ ចំពោះគ្រប់ $y \in \mathbb{R}$ ។

យក $x = y$ នោះ $f(x) \ge x^2$

កំណត់ $g(x) = f(x) - x^2 \ge 0$ នោះ $f(x) = g(x) + x^2$

យើងបាន: $f(x) = \max(2xy - f(y))$

$\Leftrightarrow g(x) + x^2 = \max(2xy - g(y) - y^2)$

$\Leftrightarrow g(x) = \max(2xy - y^2 - g(y)) - x^2$

$\Leftrightarrow g(x) = \max\left(-x^2 + 2xy - y^2 - g(y)\right)$

$\Leftrightarrow 0 \le g(x) = \max\left(-(x-y)^2 - g(y)\right) \le 0$

ទាញបាន: $g(x) = 0$ នោះ $f(x) = x^2, \forall x \in \mathbb{R}$ ។

ដូចនេះ $f(x) = x^2, \forall x \in \mathbb{R}$ ត្រូវបានកំណត់ ។

<u>លំហាត់ទី២៨</u>

គេឲ្យពហុធា $az^4 + bz^3 + cz^2 + dz^2 + e$ មានមេគុណសុទ្ធតែជាចំនួនគត់ (ដែល $a \neq 0$) និង មានឫស r_1, r_2, r_3, r_4 ដែល $r_1 + r_2$ ជាចំនួនសនិទាន ហើយ $r_3 + r_4 \neq r_1 + r_2$ ។ ចូរស្រាយបញ្ជាក់ថា: $r_1 r_2$ ជាចំនួនសនិទាន ។

(PUTNAM 2003)

<u>ដំណោះស្រាយ</u>

ដោយ r_1, r_2, r_3, r_4 ជាឫសនៃពហុធា $az^4 + bz^3 + cz^2 + dz^2 + e$ នោះតាមទ្រឹស្តីវ្យែត គេបាន:

$$\begin{cases} r_1 + r_2 + r_3 + r_4 = -\dfrac{b}{a} \\ r_1 r_2 + r_1 r_3 + r_1 r_4 + r_2 r_3 + r_2 r_4 + r_3 r_4 = \dfrac{c}{a} \\ r_1 r_2 r_3 + r_1 r_2 r_4 + r_2 r_3 r_4 + r_3 r_4 r_1 = -\dfrac{d}{a} \end{cases}$$

$$\Leftrightarrow \begin{cases} (r_1+r_2)+(r_3+r_4)=-\dfrac{b}{a} \\ (r_1+r_2)(r_3+r_4)+r_1r_2+r_3r_4=\dfrac{c}{a} \\ r_1r_2(r_3+r_4)+r_3r_4(r_1+r_2)=-\dfrac{d}{a} \end{cases}$$

តាង $m=r_1+r_2$ និង $n=r_3+r_4$, យើងបានៈ

$$\begin{cases} m+n=-\dfrac{b}{a} & (1) \\ mn+r_1r_2+r_3r_4=\dfrac{c}{a} & (2) \\ nr_1r_2+mr_3r_4=-\dfrac{d}{a} & (3) \end{cases}$$

ដោយ a,b,c,d ជាចំនួនគត់ , $(a\neq 0)$ នោះតាម (1) យើងបានៈ $m+n$ ជាចំនួនសនិទាន ទាញបានៈ n ជាចំនួនសនិទាន ព្រោះ $m=r_1+r_2$ ជាចំនួនសនិទាន នាំឲ្យ mn ជាចំនួនសនិទាន ហើយតាម (2) យើងបានៈ $mn+r_1r_2+r_3r_4$ ជាចំនួនសនិទាន នោះ $r_1r_2+r_3r_4$ ជាចំនួនសនិទាន នាំឲ្យ $m(r_1r_2+r_3r_4)$ ជាចំនួនសនិទាន តែតាម (3): $nr_1r_2+mr_3r_4$ ជាចំនួនសនិទាន នាំឲ្យ $m(r_1r_2+r_3r_4)-(nr_1r_2+mr_3r_4)=(m-n)r_1r_2$ ជាចំនួនសនិទាន តែដោយ $m=r_1+r_2\neq r_3+r_4=n$ នោះ $m-n\neq 0$ គេទាញបានៈ r_1r_2 ត្រូវតែជាចំនួនសនិទាន ។

ដូចនេះ r_1r_2 ជាចំនួនសនិទាន , ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៩

គេឲ្យ $a_0 = 1994$ និង $a_{n+1} = \dfrac{a_n^2}{a_n + 1}$ ចំពោះគ្រប់ចំនួនគត់មិនអវិជ្ជមាន n ,
ចូរស្រាយបញ្ជាក់ថា: $1994 - n$ ជាចំនួនគត់ធំបំផុត តូចជាងឬស្មើនឹង a_n
ចំពោះ $0 \le n \le 998$ ។

(IMO Shortlist 1994)

ដំណោះស្រាយ

យើងមាន: $a_n - a_{n+1} = a_n - \dfrac{a_n^2}{a_n + 1} = 1 - \dfrac{1}{a_n + 1} > 0$

$\Rightarrow a_n > a_{n+1}$ ចំពោះ $n = 0, 1, 2, \ldots$ គេបាន:

$a_0 > a_1 > a_2 > \cdots > a_n > \cdots$

ម្យ៉ាងទៀត: $a_n = a_0 + (a_1 - a_0) + (a_2 - a_1) + \cdots + (a_n - a_{n-1})$

$$= 1994 - n + \frac{1}{a_0 + 1} + \frac{1}{a_1 + 1} + \cdots + \frac{1}{a_{n-1} + 1} > 1994 - n \qquad (1)$$

ហើយចំពោះ $0 \le n \le 998$, យើងមាន:

$$\frac{1}{a_0 + 1} + \frac{1}{a_1 + 1} + \cdots + \frac{1}{a_{n-1} + 1} < \frac{1}{a_{n-1} + 1} + \frac{1}{a_{n-1} + 1} + \cdots + \frac{1}{a_{n-1} + 1}$$

$$= \frac{n}{a_{n-1} + 1} < \frac{998}{a_{997} + 1} < \frac{998}{1994 - 997 + 1} = 1$$

$$\Rightarrow 1994 - n + \frac{1}{a_0 + 1} + \frac{1}{a_1 + 1} + \cdots + \frac{1}{a_{n-1} + 1} < (1994 - n) + 1$$

$\Leftrightarrow a_n < (1994 - n) + 1 \quad (2)$

តាម (1) និង (2) គេបាន: $1994 - n < a_n < (1994 - n) + 1$

$\Rightarrow \lfloor a_n \rfloor = 1994 - n$

ដូចនេះ $1994-n$ ជាចំនួនគត់ធំបំផុត តូចជាងឬស្មើនឹង a_n ចំពោះ $0\le n\le 998$ ។

<u>លំហាត់ទី៣០</u>

គេឲ្យចំនួនគត់ $n>1$ ហើយ a,b ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់:

$a^n=a+1$ និង $b^{2n}=b+3a$ ។

តើ a និង b មួយណាធំជាងមួយណា ?

(USAMO 1993)

<u>ដំណោះស្រាយ</u>

យើងមាន: $a^n=a+1>1$, (ព្រោះ $a>0$) $\Rightarrow a>1$

ហើយ $a^{2n}=(a+1)^2>4a$ (តាមវិសមភាព $AM-GM$, សមភាពមិនអាចកើតមានទេព្រោះ $a>1$) ។

ម្យ៉ាងទៀត: $b^{2n}=b+3a \Rightarrow \left(\dfrac{b}{a}\right)^{2n}=\dfrac{b+3a}{a^{2n}}<\dfrac{b+3a}{4a}$

យើងឧបមាថា: $b\ge a$ នោះ $\dfrac{b+3a}{4a}\le\dfrac{b+3b}{4a}=\dfrac{b}{a}$

ទាញបាន: $\left(\dfrac{b}{a}\right)^{2n}<\dfrac{b}{a}$ ជាវិសមភាពមិនពិតព្រោះ $n>1$ ។

នេះបញ្ជាក់ថា: ការឧបមាខាងលើគឺខុស មានន័យថា: $b>a$ ។

ដូចនេះ $b>a$ ។

លំហាត់ទី៣១

k ជាចំនួនគត់វិជ្ជមានមួយ ។ ស្វ៊ីត $a_1, a_2, a_3, \ldots$ ត្រូវបានកំណត់ដោយៈ $a_1 = k+1$ និង $a_{n+1} = a_n^2 - ka_n + k$ ។ ចូរបង្ហាញថាៈ a_m និង a_n ជាចំនួនបឋមរវាងគ្នា ចំពោះ $m \neq n$ ។

(Poland Mathematical Olympiad 2002)

ដំណោះស្រាយ

យើងមានៈ $a_{n+1} = a_n^2 - ka_n + k$

$$\Rightarrow a_{n+1} - k = a_n(a_n - k) = a_n a_{n-1}(a_{n-1} - k)$$

$$= \cdots = a_n a_{n-1} \cdots a_1 (a_1 - k)$$

$$= a_n a_{n-1} \cdots a_1 \quad , (\text{ព្រោះ } a_1 = k+1) \qquad (1)$$

ឧបមាថាៈ $n > m$, យើងតាង $d = \gcd(a_m, a_n)$ នោះតាម (1) គេបានៈ $d|k$ ដោយ $a_n - k = a_{n-1}^2 - ka_{n-1} \Rightarrow d|a_{n-1}^2$

តាង p ជាតួចែកបឋមនៃ d នោះៈ $p|a_{n-1}^2 \Rightarrow p|a_{n-1}$, នេះមានន័យថាៈ គ្រប់តួចែកបឋមទាំងអស់នៃ d ចែកដាច់ a_{n-1} នោះយើងទាញបានៈ $d|a_{n-1}$

ធ្វើដូចរបៀបនេះជាបន្តបន្ទាប់យើងនឹងបានៈ $d|a_1 = k+1$

ដោយ $d|k$ នោះទាញបានៈ $d|1 \Rightarrow d = 1$ ។

ដូចនេះ a_m និង a_n ជាចំនួនបឋមរវាងគ្នា ចំពោះ $m \neq n$ ។

លំហាត់ទី៣២

តាង $f:\mathbb{R}\to\mathbb{R}$ ជាអនុគមន៍មួយដែលផ្ទៀងផ្ទាត់:
$f\left(f\left(x\right)\right)=x^2-x+1$ ចំពោះគ្រប់ចំនួនពិត x ,
ចូរកំណត់តម្លៃ $f\left(0\right)$ ។

(Baltic Way 2011)

ដំណោះស្រាយ

ចំពោះគ្រប់ចំនួនពិត x យើងមាន: $f\left(f\left(x\right)\right)=x^2-x+1$ នោះ
$f\left(f\left(0\right)\right)=1$
ម្យ៉ាងទៀត: $f\left(x^2-x+1\right)=f\left(f\left(f\left(x\right)\right)\right)=\left(f\left(x\right)\right)^2-f\left(x\right)+1$
នោះ $\left(f\left(0\right)\right)^2-f\left(0\right)+1=\left(f\left(1\right)\right)^2-f\left(1\right)+1=f\left(1\right)$
នាំឲ្យ $\left(f\left(1\right)\right)^2-2f\left(1\right)+1=0$ ទាញបាន: $f\left(1\right)=1$
ហើយ $f\left(0\right)\left(f\left(0\right)-1\right)=0$
បើ $f\left(0\right)=0$ នោះ $1=f\left(f\left(0\right)\right)=f\left(0\right)=0$ មិនពិត
ទាញបាន: $f\left(0\right)-1=0$
ដូចនេះ $f\left(0\right)=1$ ។

លំហាត់ទី៣៣

ចូរកំណត់គ្រប់ស្វ៊ីតនៃចំនួនពិត $a_1, a_2, ..., a_{1995}$ ដែលផ្ទៀងផ្ទាត់:
$2\sqrt{a_n-(n-1)} \geq a_{n+1}-(n-1)$ ចំពោះ $n=1,2,3,...,1994$ និង
$2\sqrt{a_{1995}-1994} \geq a_1+1$ ។

(APMO 1995)

ដំណោះស្រាយ

យើងមាន:

$$\sum_{n=1}^{1995} 2\sqrt{a_n-(n-1)} = \sum_{n=1}^{1994} 2\sqrt{a_n-(n-1)} + 2\sqrt{a_{1995}-1994}$$

$$\geq \sum_{n=1}^{1994}\left[a_{n+1}-(n-1)\right]+a_1+1 \geq \sum_{n=1}^{1994} a_{n+1}+a_1-\sum_{n=1}^{1994}(n-1)+1$$

$$=\sum_{n=1}^{1995} a_n-\sum_{n=1}^{1995}\left[(n-1)-1\right]=\sum_{n=1}^{1995}\left[a_n-(n-1)+1\right]$$

$$\Rightarrow \sum_{n=1}^{1995}\left[a_n-(n-1)+1-2\sqrt{a_n-(n-1)}\right] \leq 0$$

$$\Leftrightarrow \sum_{n=1}^{1995}\left(\sqrt{a_n-(n-1)}-1\right)^2 \leq 0$$

គេទាញបាន: $\sqrt{a_n-(n-1)}-1=0$ ចំពោះគ្រប់ $n=1,2,3,...,1995$

$\Leftrightarrow a_n=n$ ចំពោះគ្រប់ $n=1,2,3,...,1995$ ។

ដូចនេះ ស្វ៊ីតដែលត្រូវរកគឺ: $a_n=n$, $n=1,2,3,...,1995$ ។

លំហាត់ទី៣៨

ចូរបង្ហាញថា ចំពោះ $1 < a \le b \le c$ គេបានវិសមភាព:

$\log_a b + \log_b c + \log_c a \le \log_b a + \log_c b + \log_a c$ ។

(Russia Mathematical Olympiad 2009)

ដំណោះស្រាយ

តាង $x = \log_a b$, $y = \log_b c$ និង $z = \log_c a$ គេបាន:

$$xyz = \log_a b.\log_b c.\log_c a = \frac{\log b}{\log a} \cdot \frac{\log c}{\log b} \cdot \frac{\log a}{\log c} = 1$$

ដោយ $1 < a \le b \le c$ នោះគេបាន:

$$\begin{cases} x = \log_a b \ge 1 \\ y = \log_b c \ge 1 \\ z = \log_c a \le 1 \end{cases} \Leftrightarrow \begin{cases} x - 1 \ge 0 \\ y - 1 \ge 0 \\ z - 1 \le 0 \end{cases}$$

$$\Rightarrow (x-1)(y-1)(z-1) \le 0$$

$$\Leftrightarrow xyz - 1 + x + y + z - xy - yz - zx \le 0$$

$$\Leftrightarrow x + y + z \le xy + yz + zx$$

$$\Leftrightarrow x + y + z \le \frac{xy + yz + zx}{xyz} = \frac{1}{x} + \frac{1}{y} + \frac{1}{z}$$

$$\Leftrightarrow \log_a b + \log_b c + \log_c a \le \frac{1}{\log_a b} + \frac{1}{\log_b c} + \frac{1}{\log_c a}$$

ដូចនេះ $\log_a b + \log_b c + \log_c a \le \log_b a + \log_c b + \log_a c$,

ត្រូវបានបង្ហាញ ។

លំហាត់ទី៣៨

ពហុធា $x^4 - 2x^2 + ax + b$ មានឫសបួនជាចំនួនពិតខុសៗគ្នា ។
ចូរបង្ហាញថា តម្លៃដាច់ខាតនៃឫសនីមួយៗសុទ្ធតែតូចជាង $\sqrt{3}$ ។

(Hungary Mathematical Olympiad 1999)

ដំណោះស្រាយ

តាង p, q, r, s ជាឫសទាំងបួននៃ $x^4 - 2x^2 + ax + b$ នោះតាម
ទ្រឹស្តីបទវៀែត គេបាន: $p+q+r+s=0$ និង

$pq+qr+rs+pr+ps+qs=-2$

នោះ $p^2+q^2+r^2+s^2=0^2+4=4$

ដោយ $q \neq r \neq s$ នោះតាមវិសមភាព $Cauchy-schwarz$:

$(q+r+s)^2 < (1^2+1^2+1^2)(q^2+r^2+s^2)$

$\Leftrightarrow (-p)^2 < 3(4-p^2)$

$\Leftrightarrow p^2 < 12-3p^2$

$\Leftrightarrow p^2 < 3$

$\Rightarrow |p| < \sqrt{3}$

ស្រាយតាមរបៀបដូចគ្នាដែរ គេបាន: $|q|<\sqrt{3}$, $|r|<\sqrt{3}$, $|s|<\sqrt{3}$
ដូចនេះ តម្លៃដាច់ខាតនៃឫសនីមួយៗ សុទ្ធតែតូចជាង $\sqrt{3}$ ។

លំហាត់ទី៣៦

គេឲ្យ x, y, z ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់: $xyz \ge 1$,

ចូរបង្ហាញថា: $\frac{x^5 - x^2}{x^5 + y^2 + z^2} + \frac{y^5 - y^2}{y^5 + z^2 + x^2} + \frac{z^5 - z^2}{z^5 + x^2 + y^2} \ge 0$ ។

(IMO 2005)

ដំណោះស្រាយ

វិសមភាពដែលត្រូវស្រាយសមមូល:

$$\frac{x^2 - x^5}{x^5 + y^2 + z^2} + \frac{y^2 - y^5}{y^5 + z^2 + x^2} + \frac{z^2 - z^5}{z^5 + x^2 + y^2} \le 0$$

$$\Leftrightarrow \frac{x^2 - x^5}{x^5 + y^2 + z^2} + 1 + \frac{y^2 - y^5}{y^5 + z^2 + x^2} + 1 + \frac{z^2 - z^5}{z^5 + x^2 + y^2} + 1 \le 3$$

$$\Leftrightarrow \frac{x^2 + y^2 + z^2}{x^5 + y^2 + z^2} + \frac{x^2 + y^2 + z^2}{y^5 + z^2 + x^2} + \frac{x^2 + y^2 + z^2}{z^5 + x^2 + y^2} \le 3$$

តាមវិសមភាព **Cauchy-Schwarz** គេបាន:

$$\left(x^2 + y^2 + z^2\right)^2 = \left(\sqrt{x^5}.\sqrt{x^{-1}} + y.y + z.z\right)^2$$

$$\le \left(x^5 + y^2 + z^2\right)\left(\frac{1}{x} + y^2 + z^2\right) \le \left(x^5 + y^2 + z^2\right)\left(yz + y^2 + z^2\right) ,$$

$$\left(xyz \ge 1 \Rightarrow \frac{1}{x} \le yz\right)$$

$$\Rightarrow \quad \frac{x^2 + y^2 + z^2}{x^5 + y^2 + z^2} \le \frac{y^2 + z^2 + yz}{x^2 + y^2 + z^2}$$

$$\Rightarrow \sum_{cyclic} \frac{x^2 + y^2 + z^2}{x^5 + y^2 + z^2} \le \sum_{cyclic} \frac{y^2 + z^2 + yz}{x^2 + y^2 + z^2}$$

$$= \frac{2\left(x^2+y^2+z^2\right)+\left(xy+yz+zx\right)}{x^2+y^2+z^2} = 2+\frac{xy+yz+zx}{x^2+y^2+z^2} \le 2+1=3$$

$$\left(\left(x-y\right)^2+\left(y-z\right)^2+\left(z-x\right)^2 \ge 0 \Rightarrow x^2+y^2+z^2 \ge xy+yz+zx\right)$$

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៣៧

$f:\mathbb{R}\to\mathbb{R}$ ជាអនុគមន៍ដែលផ្ទៀងផ្ទាត់: $f\left(xf\left(y\right)\right)=yf\left(x\right)$
ចំពោះចំនួនពិត x,y មួយចំនួន ។ ចូរស្រាយបញ្ជាក់ថា:
$f\left(-x\right)=f\left(x\right)$ ចំពោះគ្រប់ចំនួនពិត x ។

(Kazakhstan Mathematical Olympiad 2012)

ដំណោះស្រាយ

យើងសង្កេតឃើញថា: បើ $f\left(x\right)=0$, $\forall x\in\mathbb{R}$ នោះ
$f\left(-x\right)=f\left(x\right)$ ចំពោះគ្រប់ $\forall x\in\mathbb{R}$ ។
យើងសិក្សាលើករណី $f\left(x\right)$ មិនស្មើនឹង 0 គ្រប់ x នោះត្រូវមាន x_0
មួយដែល $f\left(x_0\right)\neq 0$ ។
បើ $f\left(y_1\right)=f\left(y_2\right)$ នោះ

$$y_1 f\left(x_0\right)=f\left(x_0 f\left(y_1\right)\right)=f\left(x_0 f\left(y_2\right)\right)=y_2 f\left(x_0\right)$$

$\Rightarrow \left(y_1-y_2\right)f\left(x_0\right)=0 \Rightarrow y_1=y_2$
នេះបញ្ជាក់ថា: f ជាអនុវត្តប្រកាន់ ។
ចំពោះ $x=1$ គេបាន: $f\left(f\left(y\right)\right)=yf\left(1\right)$ នោះ $f\left(f\left(1\right)\right)=f\left(1\right)$
$\Rightarrow f\left(1\right)=1$ នោះយើងបាន: $f\left(f\left(y\right)\right)=y$ ឬ $f\left(f\left(x\right)\right)=x$
ដូច្នេះ $f\left(f\left(xy\right)\right)=xy \qquad (1)$

ដោយជំនួស x ដោយ $f(x)$ ក្នុងសមីការអនុគមន៍:

$$f(xf(y)) = yf(x)$$

គេបាន: $f(f(x)\cdot f(y)) = yf(f(x)) = yx \quad (2)$

តាម (1) និង (2) គេបាន: $f(f(x)\cdot f(y)) = f(f(xy))$

$\Rightarrow f(x)\cdot f(y) = f(xy)$

$\Rightarrow f^2(-1) = f(1) = 1$

$\Rightarrow f(-1) = -1 \quad$ (ព្រោះ $f(-1)\neq 1$)

គេបាន: $-f(x) = f(-1)\cdot f(x) = f(-x)$

ដូចនេះ $f(-x) = f(x)$ ចំពោះគ្រប់ចំនួនពិត x ។

លំហាត់ទី៣៨

តាង m,n ជាចំនួនគត់ធម្មជាតិដែល: $m+n+1$ ជាចំនួនបឋម និង ចែកដាច់ $2(m^2+n^2)-1$ ។ ចូរស្រាយបញ្ជាក់ថា: $m=n$ ។

(Swi ss Mathematical Olympiad 2010)

ដំណោះស្រាយ

យើងមាន:

$$m+n+1 \mid 2(m^2+n^2)-1 = (m-n)^2+(m+n)^2-1$$

$$= (m-n)^2+(m+n+1)(m+n-1)$$

$\Rightarrow m+n+1 \mid (m-n)^2$

$\Rightarrow m+n+1 \mid m-n \quad$ (ព្រោះ $m+n+1$ ជាចំនួនបឋម)

ដោយ $m+n+1>m-n \;\Rightarrow\; m-n=0 \Leftrightarrow\; m=n$

ដូចនេះ $m=n$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៣៩

គេឲ្យ $P(x)=2x^3-3x^2+2$ និង តាង

$S=\{P(n):n\in\mathbb{N},n\le 1999\}$, $T=\{n^2+1:n\in\mathbb{N}\}$ និង

$U=\{n^2+2:n\in\mathbb{N}\}$ ។ ចូរស្រាយបញ្ជាក់ថា: $S\cap T$ និង $S\cap U$

មានចំនួនធាតុស្មើគ្នា ។

(Romania Mathematical Olympiad 1999)

ដំណោះស្រាយ

តាង $|X|$ ជាចំនួនធាតុនៃសំណុំ X

ដោយ $P(n)=2n^3-3n^2+2=(n-1)^2(2n+1)+1$

នោះ $|S\cap T|$ ជាចំនួននៃការេប្រាកដមានទម្រង់ $(n-1)^2(2n+1)$

ដែល $n\in\mathbb{N}$, $n\le 1999$ ហើយ ចំពោះ $n\le 1999$, $(n-1)^2(2n+1)$

ជាការេប្រាកដលុះត្រាតែ: $n=1$ ឬ

$$n\in\left\{\frac{1}{2}(k^2-1):k=1,3,5,...,63\right\}$$

គេបាន: $|S\cap T|=33$ ។

ដូចគ្នាដែរ: $|S\cap U|$ ជាចំនួននៃការេប្រាកដមានទម្រង់:

$2n^3-3n^2=n^2(2n-3)$ ដែល $n\in\mathbb{N}$, $n\le 1999$

ហើយចំពោះ $n\le 1999, n^2(2n-3)$ ការេប្រាកដលុះត្រាតែ: $n=0$ ឬ

$n \in \left\{ \frac{1}{2}\left(k^2+3\right) : k = 1,3,5,\ldots,63 \right\}$ គេបាន: $|S \cap U| = 33$ ។

ដូចនេះ $|S \cap T| = |S \cap U|$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៤០

តាង r,s,t ជាឫសនៃសមីការ: $x(x-2)(3x-7)=2$ ។

ចូរបង្ហាញថា r,s,t ជាចំនួនពិតវិជ្ជមាន រួចហើយកំណត់តម្លៃនៃ:

$\arctan r + \arctan s + \arctan t$ ។

(Ibero American 1987)

ដំណោះស្រាយ

តាង $f(x) = x(x-2)(3x-7) - 2 = 3x^3 - 13x^2 + 14x - 2$

នោះ $f(0) = -2$, $f(1) = 2$, $f(2) = -2$, $f(3) = 4$

យើងបាន:

$f(0) \times f(1) = -4 < 0$

$f(1) \times f(2) = -4 < 0$

$f(2) \times f(3) = -8 < 0$

តាមទ្រឹស្តីបទតម្លៃកណ្តាលទាញបាន: សមីការ $f(x) = 0$ មានឫសបីគឺ ឫសមួយនៅចន្លោះ $(0,1)$, ឫសមួយទៀតនៅចន្លោះ $(1,2)$ ហើយ ឫសទីបីនៅ ចន្លោះ $(2,3)$, នេះបញ្ជាក់ថា: ឫសទាំងបី r,s,t នៃ សមីការ $f(x) = 0$ សុទ្ធតែជាចំនួនពិតវិជ្ជមាន ។

ម្យ៉ាងទៀត យើងតាង:

$a = \arctan r$ នោះ $r = \tan a$

$b=\arctan s$ នោះ $s=\tan b$

$c=\arctan t$ នោះ $t=\tan c$

តាមរូបមន្ត:

$$\tan(a+b+c)=\frac{\tan a+\tan b+\tan c-\tan a.\tan b.\tan c}{1-(\tan a.\tan b+\tan b.\tan c+\tan c.\tan a)}$$

យើងបាន: $\tan(\arctan r+\arctan s+\arctan t)=\dfrac{(r+s+t)-rst}{1-(rs+st+tr)}$

ដោយ r,s,t ជាឫសនៃសមីការ: $f(x)=0$ នោះតាមទ្រឹស្តីបទវ្យែត

គេបាន: $r+s+t=\dfrac{13}{3}$, $rs+st+tr=\dfrac{14}{3}$ និង $rst=\dfrac{2}{3}$

នាំឲ្យ $\tan(\arctan r+\arctan s+\arctan t)=\dfrac{\frac{13}{3}-\frac{2}{3}}{1-\frac{14}{3}}=-1$

នោះ $\arctan r+\arctan s+\arctan t=-\dfrac{\pi}{4}+k\pi$, $(k\in\mathbb{Z})$ **(1)**

ដោយ r,s,t ជាចំនួនពិតវិជ្ជមាន នោះមានន័យថា:

$$\begin{cases}\tan a>0\\ \tan b>0\\ \tan c>0\end{cases} \text{ នាំឲ្យ } \begin{cases}0<a<\dfrac{\pi}{2}\\ 0<b<\dfrac{\pi}{2}\\ 0<c<\dfrac{\pi}{2}\end{cases}$$

គេបាន: $0<a+b+c<\dfrac{3\pi}{2}$ ឬ

$0<\arctan r+\arctan s+\arctan t<\dfrac{3\pi}{2}$ **(2)**

តាម **(1)** និង **(2)** យើងបាន: $\arctan r+\arctan s+\arctan t=\dfrac{3\pi}{4}$

ដូចនេះ $\arctan r+\arctan s+\arctan t=\dfrac{3\pi}{4}$ ត្រូវបានកំណត់ ។

លំហាត់ទី៤១

តាង $n\geq 3$ ជាចំនួនគត់ និង តាង $a_2,a_3,\ldots,a_n$ ជាចំនួនពិតវិជ្ជមាន ដែល: $a_2a_3\ldots a_n=1$ ។ ចូរស្រាយបញ្ជាក់ថា:

$(1+a_2)^2(1+a_3)^3\ldots(1+a_n)^n>n^n$ ។

(IMO 2012)

ដំណោះស្រាយ

ដោយ $a_2a_3\ldots a_n=1$ នោះ យើងអាចតាង: $a_2=\dfrac{x_2}{x_3}$, $a_3=\dfrac{x_3}{x_4},\ldots,$

$a_n=\dfrac{x_n}{x_2}$ ដែល $x_2,x_3,\ldots,x_n>0$ ។

ដូច្នេះ វិសមភាពដែលត្រូវស្រាយសមមូល:

$(x_2+x_3)^2(x_3+x_4)^3\ldots(x_n+x_2)^n>n^nx_3^2x_4^3\ldots x_n^{n-1}x_2^n$

$\Leftrightarrow \prod_{k=2}^{n}(x_k+x_{k+1})^k>n^n\prod_{k=2}^{n}x_{k+1}^k$,(ក្នុងករណីនេះ , យក $x_{n+1}=x_2$)

តាមវិសមភាព $AM-GM$ យើងមាន:

$$(x_k+x_{k+1})^k=\left(x_k+(k-1)\frac{x_{k+1}}{k-1}\right)^k\geq k^kx_k\frac{x_{k+1}^{k-1}}{(k-1)^{k-1}}$$

$$=x_kx_{k+1}^{k-1}\frac{k^k}{(k-1)^{k-1}}$$

នាំឲ្យ $\prod_{k=2}^{n}\left(x_k+x_{k+1}\right)^k \ge \prod_{k=2}^{n} x_k x_{k+1}^{k-1}.\prod_{k=2}^{n}\frac{k^k}{\left(k-1\right)^{k-1}} = n^n\prod_{k=2}^{n} x_{k+1}^k$

សមភាពកើតមានកាលណា: $x_k = \frac{x_{k+1}}{k-1}$ ឬ $a_k = \frac{1}{k-1}$

ចំពោះគ្រប់ $k\in\{2,3,...,n\}$ ។

មានន័យថា: $a_2 = 1$ និង $a_k < 1$, $\forall k\in\{3,4,...,n\}$

យើងបាន: $a_2a_3...a_n < 1$ ផ្ទុយពីសម្មតិកម្មដែល $a_2a_3...a_n = 1$ ។

នេះបញ្ជាក់ថា សមភាពមិនអាចកើតមានបានទេ គឺថា:

$\prod_{k=2}^{n}\left(x_k+x_{k+1}\right)^k > n^n\prod_{k=2}^{n} x_{k+1}^k$ ពិត ។

ដូចនេះ $\left(1+a_2\right)^2\left(1+a_3\right)^3...\left(1+a_n\right)^n > n^n$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៤២

តាង a,n ជាចំនួនគត់ និង p ជាចំនួនបឋមមួយដែល: $p>|a|+1$ ។

ចូរស្រាយបញ្ជាក់ថា: ពហុធា $f\left(x\right)=x^n+ax+p$ មិនអាចសរសេរជាផលគុណនៃពីរពហុធាមិនថេរដែលមានមេគុណជាចំនួនគត់ ។

(Romanian Mathematical Olympiad 1999)

ដំណោះស្រាយ

តាង z ជាឫសមួយនៃពហុធា $f\left(x\right)$, យើងនឹងស្រាយថា: $|z|>1$.

ឧបមាថា $|z|\le 1$, នោះ $z^n+az=-p$

ទាញបាន:

$p=\left|z^n+az\right|=|z|\left|z^{n-1}+a\right|\le\left|z^{n-1}\right|+|a|\le 1+|a|$, ផ្ទុយពីសម្មតិកម្ម

នេះបញ្ជាក់ថា $|z|>1$ ។

យើងឧបមាថាពហុធា $f(x)$ អាចសរសេរជាផលគុណនៃពីរពហុធាមិនថេរដែលមានមេគុណជាចំនួនគត់ គឺមានន័យថា $f(x)=g(x).h(x)$,
យើងបាន: $p=f(0)=g(0).h(0)$
ដោយ p ជាចំនួនបឋម នោះទាញបាន $|g(0)|=1$ ឬ $|h(0)|=1$ ។
ដោយមិនធ្វើឲ្យបាត់បង់លក្ខណៈទូទៅ , យើងសន្មតថា $|g(0)|=1$
បើ $z_1, z_2, ..., z_k$ ជាឫសនៃ $g(x)$ នោះពួកវាក៏ជាឫសនៃ $f(x)$ ដែរ
នាំឲ្យ $|z_1|, |z_2|, ..., |z_k|>1$
យើងបាន: $1=|g(0)|=|z_1z_2...z_k|=|z_1||z_2|...|z_k|>1$, មិនពិត ។
បញ្ជាក់ថា ការឧបមាខាងលើគឺ ខុស ។
ដូចនេះ ពហុធា $f(x)$ មិនអាចសរសេរជាផលគុណនៃពីរពហុធាមិនថេរដែលមានមេគុណជាចំនួនគត់ ។

លំហាត់ទី៤៣

ចូរស្រាយបញ្ជាក់ថា បើ n មិនមែនជាពហុគុណនៃ 3 នោះមុំ $\frac{\pi}{n}$ អាចពុះចែកជាបីមុំប៉ុនៗគ្នាដោយប្រើតែបន្ទាត់និងដៃកឈាន ។

(USAMO 1981)

ដំណោះស្រាយ

ដោយ n មិនមែនជាពហុគុណនៃ 3 នោះ n និង 3 ត្រូវតែជាចំនួនបឋមរវាងគ្នា, តាមទ្រឹស្តីបទ $Bezout$: មានចំនួនគត់ a និង b ដែល $an+3b=1$ សមមូល: $a\frac{\pi}{n}+b\frac{\pi}{3}=\frac{\pi}{3n}$ ដែលក្នុងនោះ a និង b ត្រូវមានសញ្ញាផ្ទុយគ្នា ។

ប្រើដែកឈាន គូសរង្វង់មួយដែលមានធ្នូស្កាត់មុំផ្ចិត $\frac{\pi}{n}$ និង $\frac{\pi}{3}$ រួចប្រើរង្វាស់ធ្នូទាំងពីរនេះ សង់ធ្នូមួយដែលមានរង្វាស់ស្មើនឹង $|a|$ ដងនៃធ្នូដែលស្កាត់មុំ $\frac{\pi}{3}$ ជុំវិញរង្វង់ដែលបានសង់រួចតាមទិសដៅមួយដោយយក X ជាចំនុចចាប់ផ្តើម (គល់) និង A ជាចំនុចចុង ។

តាមទិសដៅមួយផ្សេងទៀត, ចាប់ផ្តើមពីចំនុច A យើងសង់ធ្នូមួយទៀតដែលមានរង្វាស់ស្មើនឹង $|b|$ ដងនៃធ្នូដែលស្កាត់ដោយមុំ $\frac{\pi}{n}$ ហើយយក Y ជាចំនុចចុងនៃធ្នូនោះ ។ តាមសមភាព $a\frac{\pi}{n}+b\frac{\pi}{3}=\frac{\pi}{3n}$ គេបាន: រង្វាស់ធ្នូ $XY=\frac{\pi}{3n}$ តាមរយះរង្វាស់ធ្នូនេះ , គេអាចខ័ណ្ឌចែកធ្នូដែលស្កាត់ដោយមុំផ្ចិត $\frac{\pi}{n}$ ជាធ្នូបីតូចៗប៉ុនគ្នា ដែលនេះបញ្ជាក់ថា: មុំ $\frac{\pi}{n}$ អាចពុះចែកជាមុំបីប៉ុនៗគ្នាដោយប្រើតែ បន្ទាត់ និង ដែកឈាន ។

លំហាត់ទី៤៨

ស្វ៊ីតនៃចំនួនគត់ $u_0,u_1,u_2,\ldots$ ផ្ទៀងផ្ទាត់: $u_0=1$ និង $u_{n+1}u_{n-1}=ku_n$ ចំពោះ $n\geq 1$ ហើយដែល k ជាចំនួនគត់វិជ្ជមានថេរមួយ ។
បើ $u_{2000}=2000$, ចូរកំណត់តម្លៃដែលអាចនៃ k ។

(British Mathematical Olympiad 1994)

ដំណោះស្រាយ

តាង $u_1 = x$, ដោយ $u_{n+1}u_{n-1} = ku_n$, $n \geq 1$ និង $u_0 = 1$ នោះគេបាន:

$u_2 = kx$, $u_3 = k^2$, $u_4 = \frac{k^2}{x}$, $u_5 = \frac{k}{x}$, $u_6 = 1$, $u_7 = x$, ... ។

យើងសង្កេតឃើញថា: $u_0 = u_6$, $u_1 = u_7$, ...

នាំឲ្យ (u_n) ជាស្វ៊ីតខួបដែលមានខួបស្មើនឹង 6

គេបាន: $u_2 = u_8 = u_{14} = \cdots = u_{6\times 333+2} = u_{2000}$

គឺថា: $u_2 = u_{2000} \Leftrightarrow kx = 2000 \Leftrightarrow \frac{k}{x} \cdot x^2 = 2^4.5^3$

ដោយ k ជាចំនួនគត់វិជ្ជមាន ហើយ $\frac{k}{x} = u_5$ ជាចំនួនគត់

នោះយើងទាញបាន: $x^2 \in \{1, 2^2, 2^4, 2^2.5^2, 2^4.5^2, 5^2\}$

$\Rightarrow x \in \{1, 2, 4, 10, 20, 5\}$

$\Rightarrow k \in \{2000, 1000, 500, 200, 100, 400\}$

ដូចនេះ តម្លៃដែលអាចនៃ k គឺ:

$k \in \{2000, 1000, 500, 200, 100, 400\}$ ។

លំហាត់ទី៤៥

តាង p ជាចំនួនបឋមសេសមួយ ។ ចូរស្រាយបញ្ជាក់ថា:

$$\sum_{k=1}^{p-1} k^{2p-1} \equiv \frac{p(p+1)}{2} \pmod{p^2}$$ ។

(Canadian Mathematical Olympiad 2004)

ដំណោះស្រាយ

យើងមាន: $\sum_{k=1}^{p-1} k^{2p-1} = 1^{2p-1} + 2^{2p-1} + \cdots + (p-1)^{2p-1}$

$= \left(1^{2p-1} + (p-1)^{2p-1}\right) + \left(2^{2p-1} + (p-2)^{2p-1}\right) + \cdots$

$+ \left(\left(\frac{p-1}{2}\right)^{2p-1} + \left(\frac{p+1}{2}\right)^{2p-1}\right)$, ($p \pm 1$ ជាចំនួនគត់គូ)

$= \sum_{k=1}^{\frac{p-1}{2}} \left(k^{2p-1} + (p-k)^{2p-1}\right) \quad (*)$

តាមការពន្លាតទ្វេធា *Newton* គេបាន:

$(p-k)^{2p-1} = p^{2p-1} - \cdots - C_{2p-1}^{2} \cdot p^2 k^{2p-3} + C_{2p-1}^{1} \cdot pk^{2p-2} - k^{2p-1}$

ដោយ គ្រប់តួនៃអង្គខាងស្តាំនៃសមភាពនេះសុទ្ធតែចែកដាច់នឹង p^2 លើកលែងតែពីរតួចុងក្រោយ នោះគេបាន:

$(p-k)^{2p-1} \equiv C_{2p-1}^{1} \cdot pk^{2p-2} - k^{2p-1} \pmod{p^2}$

$\Leftrightarrow (p-k)^{2p-1} + k^{2p-1} \equiv (2p-1)pk^{2p-2} \pmod{p^2} \quad (1)$

ចំពោះ $1 \le k < p$, k ចែកមិនដាច់នឹង p នោះតាមទ្រឹស្តីបទ

Fermat : $k^{p-1} \equiv 1 \pmod{p}$

នាំឲ្យ $(2p-1)k^{2p-2} \equiv (2p-1)(1^2) \equiv -1 \pmod{p}$

គេបាន: $(2p-1)k^{2p-2} = mp - 1$ ចំពោះចំនួនគត់ m ណាមួយ ។

នោះ $(2p-1)pk^{2p-2} = mp^2 - p \equiv -p \pmod{p^2} \quad (2)$

តាម (1) និង (2) គេបាន:

$(p-k)^{2p-1} + k^{2p-1} \equiv -p \pmod{p^2} \quad (**)$

តាម $(*)$ និង $(**)$ នាំឲ្យ:

$$\sum_{k=1}^{p-1} k^{2p-1} \equiv \sum_{k=1}^{\frac{p-1}{2}} (-p) \equiv \left(\frac{p-1}{2}\right)(-p)$$
$$\equiv \frac{p-p^2}{2} + p^2 \equiv \frac{p(p+1)}{2} \pmod{p^2}$$

ដូចនេះ $\sum_{k=1}^{p-1} k^{2p-1} \equiv \frac{p(p+1)}{2} \pmod{p^2}$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៤៦

(u_n) ជាស្វ៊ីតមួយដែលកំណត់ដោយ: $u_1 = 1, u_2 = 2$ និង $u_{n+1} = 3u_n - u_{n-1}$ ចំពោះ $n \geq 2$ ។ (v_n) ជាស្វ៊ីតមួយទៀតដែលផ្ទៀងផ្ទាត់: $v_n = \sum_{i=1}^{n} arc\cot u_i$, $n = 1, 2, 3, ...$ ។

ចូរគណនា $\lim_{n\to\infty} v_n$ ។

(Vietnam Mathematical Olympiad 1984)

ដំណោះស្រាយ

យើងសង្កេតឃើញថា:

$$u_1 = 1 = F_1$$
$$u_2 = 2 = F_3$$
$$u_3 = 5 = F_5$$
$$u_4 = 13 = F_7, ...$$

នេះបញ្ជាក់ថាតួនីមួយៗនៃស្វ៊ីត (u_n) ជាតួទីសេសនៃស្វ៊ីតហ្វីបូណាស៊ី (F_n) ដែលកំណត់ដោយ: $F_1 = F_2 = 1$ និង $F_{n+1} = F_n + F_{n-1}$, $n \geq 2$

ម្យ៉ាងទៀត យើងមាន:

$$arc\cot F_{2i} - arc\cot F_{2i+1} = arc\cot\frac{F_{2i}F_{2i+1}+1}{F_{2i+1}-F_{2i}}$$
$$= arc\cot\frac{F_{2i}F_{2i+1}+1}{F_{2i-1}} \qquad (*)$$

យើងនឹងស្រាយថា: $F_{n+1}F_{n+2} - F_nF_{n+3} = (-1)^n$ ចំពោះ $n \ge 1$:

យើងមាន: $F_{n+1}F_{n+2} - F_nF_{n+3} = F_{n+1}(F_{n+1}+F_n) - F_n(F_{n+1}+F_{n+2})$

$$= F_{n+1}^2 - F_nF_{n+2} = F_{n+1}^2 - F_n(F_n + F_{n+1}) = F_{n+1}^2 - F_n^2 - F_nF_{n+1}$$
$$= (F_{n+1}-F_n)(F_{n+1}+F_n) - F_nF_{n+1} = F_{n-1}F_{n+2} - F_nF_{n+1}$$
$$= -(F_nF_{n+1} - F_{n-1}F_{n+2}) = \cdots = (-1)^{n-1}(F_2F_3 - F_1F_4) = (-1)^n$$

ដូច្នេះ $F_{n+1}F_{n+2} - F_nF_{n+3} = (-1)^n$ ចំពោះ $n \ge 1$ ពិត ។

យក $n = 2i-1$ គេបាន: $F_{2i}F_{2i+1} - F_{2i-1}F_{2i+2} = -1$

នាំឲ្យ $\dfrac{F_{2i}F_{2i+1}+1}{F_{2i-1}} = F_{2i+2}$

តាម $(*)$: $\arctan F_{2i} - \arctan F_{2i+1} = \arctan F_{2i+2}$

$$\Leftrightarrow \arctan F_{2i+1} = \arctan F_{2i} - \arctan F_{2i+2}$$

$$\Leftrightarrow \sum_{i=1}^{n} \arctan F_{2i+1} = \sum_{i=1}^{n}(\arctan F_{2i} - \arctan F_{2i+2})$$

$$\Leftrightarrow \sum_{i=2}^{n} \arctan u_i = \arctan F_2 - \arctan F_{2n+2}$$

$$\Rightarrow \lim_{n\to\infty}\sum_{i=2}^{n} \arctan u_i = \lim_{n\to\infty}\arctan u_1 - \lim_{n\to\infty}\arctan F_{2n+2}$$

ដោយ $\lim_{n\to\infty} F_{2n+2} = +\infty$ នោះ $\lim_{n\to\infty} arc\cot F_{2n+1} = 0$

គេបាន: $\lim_{n\to\infty}\sum_{i=2}^{n} arc\cot u_i = arc\cot u_1 = arc\cot 1 = \dfrac{\pi}{4}$

ដូចនេះ $\lim_{n\to\infty}\sum_{i=1}^{n} arc\cot u_i = \dfrac{\pi}{4} + \dfrac{\pi}{4} = \dfrac{\pi}{2}$ ។

លំហាត់ទី៤៧

តាង u និង v ជាពីរចំនួនពិតដែលផ្ទៀងផ្ទាត់៖
$(u+u^2+u^3+\cdots+u^8)+10u^9=(v+v^2+v^3+\cdots+v^{10})+10v^{11}=8$ ។ ចូរកំណត់ថាតើ u ឬ v មួយណាធំជាង ។

(USAMO1989)

ដំណោះស្រាយ

គេពិនិត្យអនុគមន៍ពីរ៖ $f(x)=1+x+x^2+\cdots+x^8+10x^9$ និង $g(x)=1+x+x^2+\cdots+x^{10}+10x^{11}$ នោះតាមសម្មតិកម្ម យើងបាន៖ $f(u)=g(v)=9$ ។

ហើយ $g(x)-f(x)=10x^{11}+x^{10}-9x^9=x^9(10x-9)(x+1)$

យើងសង្កេតឃើញថា៖ $f(0)=1<9=f(u)$ ហើយ

$$f\left(\frac{9}{10}\right)=1+\frac{9}{10}+\cdots+\frac{9^8}{10^8}+10\cdot\frac{9^9}{10^9}=\frac{1-\frac{9^9}{10^9}}{1-\frac{9}{10}}+10\cdot\frac{9^9}{10^9}$$

$=10>9=f(u)$ នាំឲ្យ $f(0)<f(u)<f\left(\frac{9}{10}\right)$

ដោយ $f(x)$ ជាអនុគមន៍កើនជានិច្ច នោះទាញបាន៖ $0<u<\frac{9}{10}$

ដូច្នេះ $g(u)-f(u)=u^9(10u-9)(u+1)<0$

នោះ $g(u)<f(u)=g(v)$ នាំឲ្យ $u<v$ ព្រោះ $g(x)$ ជាអនុគមន៍កើនជានិច្ច

ដូចនេះ $u<v$ ។

លំហាត់ទី៤៨

ចូររកគ្រប់ចំនួនគត់វិជ្ជមាន k ដែលផ្ទៀងផ្ទាត់វិសមភាព:
$k(ab+bc+ca)>5(a^2+b^2+c^2)$ ក្នុងនោះ a,b,c ត្រូវតែជារង្វាស់ជ្រុងនៃត្រីកោណមួយ ។

(China Girl's Mathematical Olympiad 2002)

ដំណោះស្រាយ

យើងមាន: $k(ab+bc+ca)>5(a^2+b^2+c^2)\ \ (*)$

ដោយ $(a-b)^2+(b-c)^2+(c-a)^2\geq 0$

$\Leftrightarrow\ a^2+b^2+c^2\geq ab+bc+ca$

គេបាន: $k(ab+bc+ca)>5(ab+bc+ca)$

នាំឲ្យ $k>5$ ឬ $k\geq 6$ ព្រោះ $k\in\mathbb{N}\ \ (1)$

តែយើងដឹងហើយថា វិសមភាព $(*)$ ផ្ទៀងផ្ទាត់លុះត្រាតែ: a,b,c ត្រូវតែជារង្វាស់ជ្រុងនៃត្រីកោណមួយ ដូច្នេះបើយើងយក $\{a,b,c\}=\{1,1,2\}$ ដែលជាសំណុំត្រីធាតុមិនអាចផ្គុំជាត្រីកោណមួយបាននោះយើងនឹងបាន: $k(1\times 1+1\times 2+2\times 1)\leq 5(1^2+1^2+2^2)$

$\Leftrightarrow k\leq 6\ \ (2)$

តាម (1) និង (2) ទាញបាន: $k=6$ ។

យើងនឹងស្រាយបញ្ជាក់ថា: $k=6$ ពិតប្រាកដមែន ៖

ចំពោះ $k=6$ នោះគេបាន:

$6(ab+bc+ca)>5(a^2+b^2+c^2)\ \ (\Omega)$

$\Leftrightarrow 5a^2-6(b+c)a+5(b^2+c^2)-6bc<0$ ជាវិសមីការដឺក្រេទី២ មានអញ្ញាត a ហើយមាន:

$\Delta'=[3(b+c)]^2-5[5(b^2+c^2)-6bc]=-16b^2+48bc-16c^2$

$$= -16\left(b^2 - 3bc + c^2\right) = -16\left[(b-c)^2 - bc\right]$$

$$= -16(b-c)^2 + 16bc \le 16bc \le 4(b+c)^2$$

នាំឲ្យ $a < \dfrac{3(b+c)+\sqrt{\Delta'}}{5} \le \dfrac{3(b+c)+2(b+c)}{5}$

$\Leftrightarrow a < b+c$ ដូចគ្នាដែរ បើយើងប្រើវិសមីការ (Ω) ដោយយក b រួច c ជាអញ្ញាតវិញ នោះគេនឹងបាន: $b < c+a$ និង $c < a+b$

នេះបញ្ជាក់ថា: a,b,c ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។

ដូចនេះ $k = 6$ មានតែមួយគត់ ។

លំហាត់ទី៤៩

គេឲ្យ $l\,,m$ និង n ជាចំនួនគត់វិជ្ជមានដែល $m-n$ ជាចំនួនបឋម និង $8\left(l^2 - mn\right) = 2\left(m^2+n^2\right) + 5(m+n)l$ ។ ចូរស្រាយបញ្ជាក់ថា: $11l+3$ ជាការេប្រាកដ ។

(Bulgarian Mathematical Olympiad , Regional round 2006)

ដំណោះស្រាយ

តាង $m-n=p$ និង $m+n=q$ $\Rightarrow m = \frac{1}{2}(p+q)$ និង $n = \frac{1}{2}(q-p)$

យើងបាន: $mn = \frac{1}{4}\left(q^2-p^2\right)$ និង $m^2+n^2 = \frac{1}{2}\left(p^2+q^2\right)$

សមភាពដែលគេឲ្យសមមូល: $8\left(l^2 - \frac{1}{4}\left(q^2-p^2\right)\right) = \left(p^2+q^2\right) + 5ql$

$\Leftrightarrow 8l^2 - 2q^2 + 2p^2 = p^2 + q^2 + 5ql \Leftrightarrow 3q^2 + 5ql - 8l^2 = p^2$

$\Leftrightarrow (q-l)(3q+8l) = p^2$

ដោយ $p = m-n$ ជាចំនួនបឋម ហើយ $3q+8l > q-l$ នោះគេទាញបាន:

$$\begin{cases} q-l=1 \\ 3q+8l=p^2 \end{cases} \Rightarrow 3(1+l)+8l=p^2 \Leftrightarrow 11l+3=p^2$$

ដូចនេះ $11l+3$ ជាការេប្រាកដ ។

លំហាត់ទី៥០

ចូរស្រាយបញ្ជាក់ថា ស្វ៊ីតដែលកំណត់ដោយ: $y_0=1$ និង

$y_{n+1}=\frac{1}{2}\left(3y_n+\sqrt{5y_n^2-4}\right)$ ចំពោះ $n\geq 0$ មានតួសុទ្ធតែជាចំនួនគត់ ។

(British Mathematical Olympiad 2002)

ដំណោះស្រាយ

ចំពោះគ្រប់ $n\geq 0$ យើងមាន: $y_{n+1}=\frac{1}{2}\left(3y_n+\sqrt{5y_n^2-4}\right)$

$\Leftrightarrow\ 2y_{n+1}-3y_n=\sqrt{5y_n^2-4}\quad (*)$

$\Leftrightarrow\ 4y_{n+1}^2-12y_{n+1}y_n+9y_n^2=5y_n^2-4$

$\Leftrightarrow\ y_{n+1}^2-3y_{n+1}y_n+y_n^2+1=0\quad (1)$

$\Rightarrow\ y_n^2-3y_ny_{n-1}+y_{n-1}^2+1=0\quad (2)$

ដកអង្គនិងអង្គនៃ (1) និង (2) គេបាន: $y_{n+1}^2-y_{n-1}^2-3y_{n+1}y_n+3y_ny_{n-1}=0$

$\Leftrightarrow\ (y_{n+1}-y_{n-1})(y_{n+1}+y_{n-1})-3y_n(y_{n+1}-y_{n-1})=0$

$\Leftrightarrow\ (y_{n+1}-y_{n-1})(y_{n+1}+y_{n-1}-3y_n)=0$

តែតាម $(*)$: $2y_{n+1}-3y_n\geq 0\Rightarrow 2y_{n+1}\geq 3y_n\Rightarrow y_{n+1}>y_n$

$\Rightarrow\ y_{n+1}>y_n>y_{n-1}\ \Rightarrow\ y_{n+1}-y_n>0$

$\Rightarrow\ y_{n+1}-3y_n+y_{n-1}=0$

យើងមាន: $y_0=1$ នោះ $y_1=\frac{1}{2}\left(3y_0+\sqrt{5y_0^2-4}\right)=2$

សង្កេតឃើញថា: $y_0\ ,\ y_1\in\mathbb{Z}$

ឧបមាថា: $y_{n-1}\,,\,y_n\in\mathbb{Z} \quad\Rightarrow\; y_{n+1}=3y_n-y_{n-1}\in\mathbb{Z}$

នោះតាមវិចារអនុមានរួមគណិតវិទ្យា គេបាន: $y_n\in\mathbb{Z}$ គ្រប់ $n\geq 0$ ។

ដូចនេះ គ្រប់តួនៃស្វ៊ីត $(y_n)_{n\geq 0}$ ជាចំនួនគត់ ។

<u>លំហាត់ទី៥១</u>

ចំនួនពិតវិជ្ជមាន a,b,c ផ្ទៀងផ្ទាត់សមភាព: $(a+b)(b+c)(c+a)=8$ ។

ចូរស្រាយបញ្ជាក់ថា: $\dfrac{a+b+c}{3}\geq\sqrt[27]{\dfrac{a^3+b^3+c^3}{3}}$ ។

(Macedonia Mathematical Olympiad 2008)

<u>ដំណោះស្រាយ</u>

គេមានឯកលក្ខណះភាព:

$$\begin{aligned}(a+b+c)^3 &= a^3+b^3+c^3+3(a+b)(b+c)(c+a)\\ &= a^3+b^3+c^3+24 \quad (\text{ព្រោះ } (a+b)(b+c)(c+a)=8\ )\\ &= a^3+b^3+c^3+3+3+3+3+3+3+3+3\\ &\geq 9\sqrt[9]{(a^3+b^3+c^3)3^8} \quad (\text{ ប្រើវិសមភាព } Cauchy\ 9 \text{ តួ })\end{aligned}$$

$$\Leftrightarrow\; a+b+c\geq 3\sqrt[27]{\frac{a^3+b^3+c^3}{3}}$$

$$\Leftrightarrow\; \frac{a+b+c}{3}\geq\sqrt[27]{\frac{a^3+b^3+c^3}{3}}$$

ដូចនេះវិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៨២

គេឲ្យ f ជាអនុគមន៍មានតម្លៃជាចំនួនពិតហើយផ្ទៀងផ្ទាត់:

$f(x,y)=f(x,z)-2f(y,z)-2z$ ចំពោះគ្រប់ចំនួនពិត x,y និង z ។

ចូរកំណត់តម្លៃនៃ $f(2005,1000)$ ។

(Singapore Mathematical Olympiad 2005)

ដំណោះស្រាយ

ចំពោះគ្រប់ចំនួនពិត x,y និង z យើងមាន:

$f(x,y)=f(x,z)-2f(y,z)-2z$

យក $x=y=z$ នោះ $f(x,x)=-x$ ចំពោះគ្រប់ចំនួនពិត x ។

យក $x=y$ នោះ $f(x,x)=f(x,z)-2f(x,z)-2z$

$\Rightarrow f(x,z)=-f(x,x)-2z=x-2z$

យក $x=2005$ និង $z=1000$ នោះ $f(2005,1000)=2005-2\times1000=5$

ដូចនេះ $f(2005,1000)=5$ ។

លំហាត់ទី៨៣

ចូរស្រាយបញ្ជាក់ថា: គ្មានចំនួនដែលមានទម្រង់ $44\cdots4443$ ណាមួយចែកដាច់នឹង 13 នោះទេ ។

(Dutch Mathematical Olympiad 2007)

ដំណោះស្រាយ

ឧបមាថា: មានចំនួនមួយដែលមានទម្រង់ $\underbrace{44\cdots4443}_{k}$ ចែកដាច់នឹង 13

យើងបាន: $\underbrace{44\cdots4443}_{k}-13=\underbrace{44\cdots44430}_{k-1}=\underbrace{44\cdots4443}_{k-1}\times10$ ក៏ចែកដាច់នឹង

13 ដែរ នាំឲ្យ $\underbrace{44\cdots4443}_{k-1}$ ចែកដាច់នឹង 13 ព្រោះ 10 និង 13 ជាចំនួនបឋមរវាងគ្នា ។ ដោយចេះតែបន្តធ្វើតាមរបៀបនេះ យើងនឹងបានៈ 43 ចែកដាច់នឹង 13 តែនេះជាករណីមិនពិត ។ បញ្ជាក់ថា ការឧបមាខាងលើគឺខុស ។ ដូចនេះគ្មានចំនួនដែលមានទម្រង់ $44\cdots4443$ ណាមួយចែកដាច់នឹង 13 នោះទេ ។

លំហាត់ទី៤៨

គេឲ្យ A ជាចំនួនពិត និង n ជាចំនួនគត់ដែល $2\le n\le 19$ ។ រកគ្រប់ពហុធា $P(x)$ ដែលមានមេគុណជាចំនួនពិតហើយផ្ទៀងផ្ទាត់ៈ
$P\left(P\left(P(x)\right)\right)=Ax^n+19x+99$ ។

(Austria Mathematical Olympiad 1999)

ដំណោះស្រាយ

តាង $m=\deg P(x)$ នោះ $\deg P\left(P\left(P(x)\right)\right)=m^3$

គេមានៈ $P\left(P\left(P(x)\right)\right)=Ax^n+19x+99$

បើ $A\neq 0$ នោះ $n=m^3$

ដោយ $2\le n\le 19 \Leftrightarrow 2\le m^3\le 19 \Rightarrow m=2$ (ព្រោះ m ជាចំនួនគត់)

$\Rightarrow n=8$ គេបានៈ $P(x)=ax^2+bx+c$ ដែល $a,b,c\in\mathbb{R}$ និង $a\neq 0$

$$\Rightarrow P\left(P(x)\right)=a\left(ax^2+bx+c\right)^2+b\left(ax^2+bx+c\right)+c$$

$$=a^3x^4+2a^2bx^3+\cdots$$

$$\Rightarrow P\left(P\left(P(x)\right)\right)=a^3\left(ax^2+bx+c\right)^4+2a^2b\left(ax^2+bx+c\right)^3+\cdots$$

$$=a^7x^8+4a^6bx^7+\cdots$$

តែ $P\left(P\left(P(x)\right)\right)=Ax^8+19x+99$ ទាញបានៈ $4a^6b=0\Rightarrow b=0$

ព្រោះ $a \neq 0$ នោះយើងបាន: $P(x) = ax^2 + c \Rightarrow P(-x) = P(x)$

$\Rightarrow P(P(P(-x))) = P(P(P(x)))$ នាំឲ្យ $P(P(P(x)))$ ជាអនុគមន៍គូ ផ្ទុយពី

$P(P(P(x))) = Ax^8 + 19x + 99$ ដែលមិនមែនជាអនុគមន៍គូ , នេះបញ្ជាក់ថា:

A ត្រូវតែស្មើនឹង 0 ។

ក្នុងករណីនេះ គេបាន: $P(P(P(x))) = 19x + 99$ នាំឲ្យ $\deg P(x) = 1$

នោះគេតាង $P(x) = \alpha x + \beta \quad , \alpha \neq 0$ គេបាន:

$$P(P(x)) = \alpha P(x) + \beta = \alpha(\alpha x + \beta) + \beta = \alpha x^2 + \alpha\beta + \beta$$

$$\Rightarrow P(P(P(x))) = \alpha^2 P(x) + \alpha\beta + \beta = \alpha^2(\alpha x + \beta) + \alpha\beta + \beta$$

$$= \alpha^3 x + (\alpha^2 + \alpha + 1)\beta$$

ដោយ $P(P(P(x))) = 19x + 99$

$$\Rightarrow \begin{cases} \alpha^3 = 19 \\ (\alpha^2 + \alpha + 1)\beta = 99 \end{cases} \Rightarrow \begin{cases} \alpha = \sqrt[3]{19} \\ \beta = \dfrac{99}{\alpha^2 + \alpha + 1} = \dfrac{99(\alpha - 1)}{\alpha^3 - 1} = \dfrac{99(\sqrt[3]{19} - 1)}{18} \end{cases}$$

ដូចនេះ: $P(x) = \sqrt[3]{19}x + \dfrac{99}{18}(\sqrt[3]{19} - 1)$ ។

លំហាត់ទី៤៨

បើ a ជាឫសពិតនៃសមីការ: $x^5 - x^3 + x - 2 = 0$ ។ បង្ហាញថា $\lfloor a^6 \rfloor = 3$ ។

(India Mathematical Olympiad 2004)

ដំណោះស្រាយ

ដោយ a ជាឫសពិតមួយនៃសមីការ: $x^5 - x^3 + x - 2 = 0$ នោះមានន័យថា:

$$a^5 - a^3 + a - 2 = 0 \quad , \quad (a \neq 0)$$

$$\Leftrightarrow a^5 = a^3 - a + 2$$

$$\Rightarrow a^7 = a^5 - a^3 + 2a^2$$
$$= a^3 - a + 2 - a^3 + 2a^2$$
$$= 2a^2 - a + 2$$
$$\Leftrightarrow a^7 + a = 2a^2 + 2$$
$$\Rightarrow a^6 + 1 = 2a + \frac{2}{a} \ge 2\sqrt{(2a)\left(\frac{2}{a}\right)} = 4 \text{ (តាមវិសមភាព } Cauchy)$$
$$\Rightarrow a^6 \ge 3 \quad (1)$$

ហើយ $a^5 + a = a^3 + 2$

$$\Rightarrow \frac{a^3+2}{a^3} = \frac{a^5+a}{a^3} = a^2 + \frac{1}{a^2} > 2\sqrt{a^2 \cdot \frac{1}{a^2}} = 2$$

(សមភាពមិនអាចកើតមានបានទេព្រោះ $a \neq \pm 1$ ផ្ទុយមកវិញ បើ $a = \pm 1$ នោះ a មិនមែនជាឫសនៃសមីការគេឲ្យនោះទេ)

$$\Leftrightarrow 1 + \frac{2}{a^3} > 2 \Rightarrow a^3 < 2 \Rightarrow a^6 < 4 \quad (2)$$

តាម (1) និង (2) គេបាន: $3 \le a^6 < 4$ នោះ $\lfloor a^6 \rfloor = 3$

ដូចនេះ $\lfloor a^6 \rfloor = 3$ ។

<u>លំហាត់ទី៥៦</u>

$a_1, a_2, a_3, \cdots$ ជាស្វ៊ីតមួយដែលផ្ទៀងផ្ទាត់: $a_1 = 2$, $a_2 = 5$ និង $a_{n+2} = (2 - n^2)a_{n+1} + (2 + n^2)a_n$ ចំពោះគ្រប់ $n \ge 1$ ។ តើមានសន្ទស្សន៍ p, q, r ដែលផ្ទៀងផ្ទាត់: $a_p a_q = a_r$ ដែរឬទេ ?

(1995 Czech-Slovak Match)

ដំណោះស្រាយ

យើងសង្កេតឃើញថា: $a_1 = 2 \equiv 2(\mathrm{mod}3)$ និង $a_2 = 5 \equiv 2(\mathrm{mod}3)$

ឧបមាថា: $a_n \equiv 2(\mathrm{mod}3)$ និង $a_{n+1} \equiv 2(\mathrm{mod}3)$ គេបាន:

$a_{n+2} \equiv (2-n^2)2 + (2+n^2)2 = 8 \equiv 2(\mathrm{mod}3)$

នោះតាមវិចារអនុមានរួមគណិតវិទ្យា គេបាន: $a_n \equiv 2(\mathrm{mod}3)$ ចំពោះគ្រប់ $n \ge 1$

ក្នុងនោះ $a_p \equiv 2(\mathrm{mod}3)$, $a_q \equiv 2(\mathrm{mod}3)$ $\Rightarrow$ $a_p a_q \equiv 4 \equiv 1(\mathrm{mod}3)$

ហើយ $a_r \equiv 2(\mathrm{mod}3)$ $\Rightarrow$ $a_p a_q \not\equiv a_r(\mathrm{mod}3)$ $\Rightarrow$ $a_p a_q \ne a_r$ ចំពោះគ្រប់ p,q,r ។

ដូចនេះ មិនមានសន្ទស្សន៍ p,q,r ដែលផ្ទៀងផ្ទាត់: $a_p a_q = a_r$ នោះទេ ។

លំហាត់ទី៨៧

គេឲ្យ a និង b ជាពីរចំនួនគត់វិជ្ជមានដែល $a > b$ ។

គេដឹងថា: $\gcd(a-b, ab+1) = 1$ និង $\gcd(a+b, ab-1) = 1$,

ចូរស្រាយបញ្ជាក់ថា: $(a-b)^2 + (ab+1)^2$ មិនមែនជាការេប្រាកដ ។

(Iran Mathematical Olympiad 2010)

ដំណោះស្រាយ

គេមាន: $(a-b)^2 + (ab+1)^2 = a^2 - 2ab + b^2 + a^2b^2 + 2ab + 1$

$$= (a^2+1)(b^2+1)$$

យើងនឹងស្រាយឲ្យឃើញថា: $\gcd(a^2+1, b^2+1) = 1$:

តាង $\delta = \gcd(a^2+1, b^2+1)$ នោះ $\delta | a^2+1 \wedge \delta | b^2+1$

$\Rightarrow \delta | (a^2+1) - (b^2+1)$ $\Rightarrow \delta | (a-b)(a+b)$

ឧបមាថា: $\delta \ne 1$ នោះយើងតាង d ជាតួចែកបឋមមួយនៃ δ , $(d > 1)$

$\Rightarrow d|\delta \Rightarrow d|(a-b)(a+b) \Rightarrow d|a-b \vee d|a+b$, (d ជាចំនួនបឋម)

• បើ $d|a-b$:

យើងមាន: $\delta|a^2+1 \wedge \delta|b^2+1$ ហើយ $d|\delta \Rightarrow d|a^2+1 \wedge d|b^2+1$

$\Rightarrow d|(a^2+1)(b^2+1)=(a-b)^2+(ab+1)^2$

$\Rightarrow d|(ab+1)^2$ ព្រោះ $d|a-b$

$\Rightarrow d|ab+1$ ព្រោះ d ជាចំនួនបឋម

$\Rightarrow d|\gcd(a-b,ab+1)=1$ មិនពិតព្រោះ $d>1$

• បើ $d|a+b$:

យើងមាន: $d|(a^2+1)(b^2+1)=(a+b)^2+(ab-1)^2$

$\Rightarrow d|(ab-1)^2$

$\Rightarrow d|ab-1$

$\Rightarrow d|\gcd(a+bb,ab-1)=1$ មិនពិតព្រោះ $d>1$

ទាំងពីរករណីនេះបញ្ជាក់ថា: ការឧបមាដែលថា $\delta\neq 1$ គឺខុស ។

ដូច្នេះ δ ត្រូវតែស្មើនឹង 1 មានន័យថា: a^2+1 និង b^2+1 ជាចំនួនបឋមរវាងគ្នា នាំឲ្យ បើ $(a-b)^2+(ab+1)^2=(a^2+1)(b^2+1)$ ជាការេប្រាកដលុះត្រាតែ a^2+1 និង b^2+1 ត្រូវតែជាការេប្រាកដទាំងពីរ តែនេះជាករណីមិនអាច ។

ដូចនេះ $(a-b)^2+(ab+1)^2$ មិនមែនជាការេប្រាកដនោះទេ ។

លំហាត់ទី៤៨

រង្វាស់ជ្រុង a , b , c និង u , v , w នៃពីរត្រីកោណ ABC និង UVW ផ្ទៀងផ្ទាត់នូវប្រព័ន្ធសមីការៈ $u(v+w-u)=a^2$, $v(w+u-v)=b^2$ និង $w(u+v-w)=c^2$ ។ ចូរស្រាយបញ្ជាក់ថា ABC ជាត្រីកោណមានមុំក្នុងទាំងបីជាមុំស្រួចហើយសរសេរមុំ U , V , W ជាអនុគមន៍នៃ A , B , C ។

(British Mathematical Olympiad 1996)

ដំណោះស្រាយ

យើងមានៈ

$$\begin{cases} u(v+w-u)=a^2 \\ v(w+u-v)=b^2 \\ w(u+v-w)=c^2 \end{cases} \Leftrightarrow \begin{cases} a^2=uv+uw-u^2 \\ b^2=vw+vu-v^2 \\ c^2=wu+wv-w^2 \end{cases}$$

$$\Rightarrow a^2+b^2-c^2=2uv-u^2-v^2+w^2$$

$$=w^2-(u-v)^2=(w-u+v)(w+u-v)>0$$

(ព្រោះ $w+v>u$, $w+u>v$ វិសមភាពក្នុងត្រីកោណ UVW)

$$\Rightarrow \cos C=\frac{a^2+b^2-c^2}{2ab}>0$$

ស្រាយដូចគ្នាដែរៈ $\cos B>0$, $\cos A>0$

នាំឲ្យ A , B , C សុទ្ធតែជាមុំស្រួច ។

ម្យ៉ាងទៀត $\cos C=\sqrt{\frac{(a^2+b^2-c^2)^2}{4a^2b^2}}$

$$=\sqrt{\frac{(w-u+v)^2(w+u-v)^2}{4uv(v+w-u)(w+u-v)}}$$

$$=\sqrt{\frac{(w-u+v)(w+u-v)}{4uv}}$$

$$= \sqrt{\frac{2uv - u^2 - v^2 + w^2}{4uv}}$$

$$= \frac{1}{\sqrt{2}}\sqrt{1 - \frac{u^2 + v^2 - w^2}{2uv}}$$

$$= \frac{1}{\sqrt{2}}\sqrt{1 - \cos W}$$

$\Rightarrow \sqrt{2}\cos C = \sqrt{1 - \cos W}$

$\Leftrightarrow \cos W = 1 - 2\cos^2 C = -\cos 2C = \cos(\pi - 2C)$

$\Rightarrow W = \pi - 2C$

ដូចគ្នា: $V = \pi - 2B$, $U = \pi - 2A$

ដូចនេះ A , B , C ជាមុំស្រួច ហើយ $U = \pi - 2A$, $V = \pi - 2B$ និង $W = \pi - 2C$ ។

<u>លំហាត់ទី៥៩</u>

គេឲ្យ a , b , c ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់: $a^3 + b^3 = c^3$ ។

ចូរស្រាយបញ្ជាក់ថា: $a^2 + b^2 - c^2 > 6(c-a)(c-b)$ ។

(India National Mathematical Olympiad 2009)

<u>ដំណោះស្រាយ</u>

តាមវិសមភាព $AM - GM$ គេមាន:

$bc^2 + cb^2 + b^3 + ac^2 + ca^2 + a^3 \geq 6\sqrt[6]{(bc^2)(cb^2)(b^3)(ac^2)(ca^2)(a^3)} = 6abc$

ដែលសមភាពកើតមានកាលណា: $bc^2 = cb^2 = b^3 = ac^2 = ca^2 = a^3$

នាំឲ្យ $a = b = c$ តែ $a^3 + b^3 = c^3$ ទាញបាន: $a = b = c = 0$ មិនពិតព្រោះ $a,b,c \in \mathbb{R}^+$ នេះបញ្ជាក់ថាវិសមភាពខាងលើមិនអាចក្លាយជាសមភាពទេ

គឺថា: $bc^2 + cb^2 + b^3 + ac^2 + ca^2 + a^3 > 6abc$

ចែកអង្គទាំងពីរនៃវិសមភាពនេះនឹង $ab>0$ គេបាន:

$$\frac{c^2+cb+b^2}{a}+\frac{c^2+ca+a^2}{b}>6c$$

គុណអង្គទាំងពីរនៃវិសមភាពនេះនឹង $(c-a)(c-b)>0$ គេបាន:

$$\frac{(c-a)(c^3-b^3)}{a}+\frac{(c-b)(c^3-a^3)}{b}>6c(c-a)(c-b)$$

ដោយ $a^3+b^3=c^3$ នាំឲ្យ $c^3-a^3=b^3$ និង $c^3-b^3=a^3$ គេបាន:

$$\frac{a^3(c-a)}{a}+\frac{b^3(c-b)}{b}>6c(c-a)(c-b)$$

$$\Leftrightarrow\ a^2(c-a)+b^2(c-b)>6c(c-a)(c-b)$$

$$\Leftrightarrow\ a^2c-a^3+b^2c-b^3>6c(c-a)(c-b)$$

$$\Leftrightarrow\ a^2+b^2-\frac{a^3+b^3}{c}>6(c-a)(c-b)$$

តែ $a^3+b^3=c^3 \Rightarrow \dfrac{a^3+b^3}{c}=c^2$

ដូចនេះ: $a^2+b^2-c^2>6(c-a)(c-b)$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៦០

គេឲ្យពហុធា $P(x)=x^3+ax^2+bx+c$ មានឫសសុទ្ធតែជាចំនួនពិត ហើយ គេតាង $Q(x)=5x^2-16x+2004$ ។ ឧបមាថា $P(Q(x))=0$ គ្មានឫសជាចំនួនពិត , ចូរស្រាយបញ្ជាក់ថា: $P(2004)>2004$ ។

(India International Mathematical Olympiad Training Camp 2005)

ដំណោះស្រាយ

តាង $P(x)=(x-x_1)(x-x_2)(x-x_3)$ ដែល x_1 , x_2 , x_3 ជាឫសពិតទាំងបីនៃ $P(x)$

ដោយ $P(Q(x))=0$ ជាសមីការគ្មានឫសជាចំនួនពិត នោះទាញបាន:

$Q(x)=x_i \quad ; \quad i=1,2,3$ ត្រូវតែជាសមីការគ្មានឫសជាចំនួនពិត នោះ $\Delta<0$ ។

យើងមាន: $Q(x)=x_i \Leftrightarrow 5x^2-16x+2004=x_i$

$\Leftrightarrow 5x^2-16x+2004-x_i=0 \quad \Rightarrow \Delta=16^2-20(2004-x_i)<0$

$\Leftrightarrow 2004-x_i>\dfrac{64}{4}$ ចំពោះ $i=1,2,3$

$\Rightarrow P(2004)=(2004-x_1)(2004-x_2)(2004-x_3)>\left(\dfrac{64}{5}\right)^3>2004$

ដូចនេះ $P(2004)>2004$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៦១

ស្វ៊ីតពីរ (x_n) និង (y_n) ត្រូវបានកំណត់ដោយ: $x_0=365$,

$x_{n+1}=x_n\left(x_n^{1986}+1\right)+1622$ ចំពោះគ្រប់ $n\geq 0$ និង $y_0=16$,

$y_{n+1}=y_n\left(y_n^3+1\right)-1952$ ចំពោះគ្រប់ $n\geq 0$ ។ ចូរស្រាយបញ្ជាក់ថា:

$\left|x_p-x_q\right|>0$ ចំពោះគ្រប់ $p,q\geq 1$ ។

(Vietnam Mathematical Olympiad 1987)

ដំណោះស្រាយ

កត់សម្គាល់ឃើញថា: (x_n) និង (y_n) ជាស្វ៊ីតនៃចំនួនគត់វិជ្ជមាន ។

គេមាន $x_{n+1}=x_n\left(x_n^{1986}+1\right)+1622=x_n^{1987}+x_n+1622$

$\Rightarrow x_{n+1}-x_n=x_n^{1987}+1622$

$\Rightarrow x_1-x_0=x_0^{1987}+1622=\left(365^{1987}-365\right)+1987$

ដោយ 1987 ជាចំនួនបឋម នោះតាមទ្រឹស្តីបទ *Fermat* គេបាន:

$365^{1987}\equiv 365(\text{mod}1987) \Leftrightarrow 365^{1987}-365\equiv 0(\text{mod}1987)$

$\Rightarrow\ x_1 - x_0 \equiv 0 \pmod{1987}$

$\Leftrightarrow\ x_1 \equiv x_0 \pmod{1987}$

ដូចគ្នាដែរ:

$x_2 - x_1 = x_1^{1987} + 1622 \equiv x_0^{1987} + 1622 = \left(365^{1987} - 365\right) + 1987 \equiv 0$
$\pmod{1987}\ \ \Rightarrow\ x_2 \equiv x_1 \equiv x_0 \pmod{1987}$

តាមរបៀបនេះយើងបាន: $x_n \equiv x_0 \pmod{1987}$ គ្រប់ $n \geq 1$

ដោយ $x_0 = 365$ នោះ $x_n \equiv 365 \pmod{198}$ គ្រប $n \geq 1$ ។

ម្យ៉ាងទៀត $y_{n+1} = y_n\left(y_n^3 + 1\right) - 1952 = y_n^4 + y_n - 1952$

$\Leftrightarrow\ y_{n+1} - y_n = y_n^4 - 1952$

$\Rightarrow\ y_1 - y_0 = y_0^4 - 1952 = 16^4 - 1952 = 63584 = 32 \cdot 1987$

$\Rightarrow\ y_1 - y_0 \equiv 0 \pmod{1987}\ \Leftrightarrow\ y_1 \equiv y_0 \pmod{1987}$

ដូចគ្នាដែរ: $y_2 - y_1 = y_1^4 - 1952 \equiv y_0^4 - 1952 \equiv 0 \pmod{1987}$

$\Rightarrow\ y_2 \equiv y_1 \equiv y_0 \pmod{1987}$

តាមលំនាំនេះយើងបាន: $y_n \equiv y_0 \pmod{1987}$ គ្រប់ $n \geq 1$

ដោយ $y_0 = 16$ នោះ $y_n \equiv 16 \pmod{1987}$ គ្រប់ $n \geq 1$ ។

ចំពោះគ្រប់ $p, q \geq 1$ យើងមាន: $x_p \equiv 365 \pmod{1987}$ និង

$y_q \equiv 16 \pmod{1987}$

$\Rightarrow\ x_p - x_q \equiv 365 - 16 \equiv 349 \pmod{1987}$

នេះបញ្ជាក់ថា $x_p \neq y_q$ គ្រប់ $p, q \geq 1$ ។

ដូចនេះ $\left|x_p - x_q\right| > 0$ ចំពោះគ្រប់ $p, q \geq 1$ ។

លំហាត់ទី៦២

គេឲ្យ n ជាចំនួនគត់មួយ ។ បង្ហាញថា: បើ $2+2\sqrt{1+12n^2}$ ជាចំនួនគត់ នោះ វាត្រូវតែជាការេប្រាកដ ។

(British Mathematical Olympiad 2006)

ដំណោះស្រាយ

តាង $2+2\sqrt{1+12n^2}=m$ ជាចំនួនគត់

$\Leftrightarrow\ 4\left(1+12n^2\right)=(m-2)^2$ ក្នុងករណីនេះ , m ត្រូវតែជាចំនួនគត់គូ គឺ

$m=2i$

គេបាន: $1+12n^2=(i-1)^2$ ទាញបាន: i ត្រូវតែជាចំនួនគត់គូ គឺ $i=2j$

គេបាន: $1+12n^2=(2j-1)^2\ \Leftrightarrow\ 1+12n^2=4j^2-4j+1$

$\Leftrightarrow\ 3n^2=j(j-1)$

ដោយ $\gcd(j,j-1)=1$ នោះ $j=3k^2$, $j-1=l^2$ ឬ $j=k^2$, $j-1=3l^2$

* បើ $j=3k^2$, $j-1=l^2$ នោះ $l^2+1=3k^2\ \Rightarrow\ l^2+1\equiv 0(\mathrm{mod}\,3)$

$\Leftrightarrow\ l^2\equiv -1(\mathrm{mod}\,3)$ មិនពិតទេព្រោះ ចំពោះគ្រប់ចំនួនពិត l , $l^2\not\equiv -1(\mathrm{mod}\,3)$

* បើ $j=k^2$, $j-1=3l^2$ នោះ $m=2i=4j=4k^2=(2k)^2$ ជាការេប្រាកដ ។

ដូចនេះ ចំពោះគ្រប់ចំនួនគត់ n , បើ $2+2\sqrt{1+12n^2}$ ជាចំនួនគត់នោះ វាត្រូវតែជាការេប្រាកដ ។

លំហាតទី៦៣

ចូររកគ្រប់ចំនួនគត់ x និង ចំនួនបឋម p ដែលផ្ទៀងផ្ទាត់: $x^8+2^{2^x+2}=p$ ។

(Greece Mathematical Olympiad 2008)

ដំណោះស្រាយ

យើងមាន: $x^8 + 2^{2^x+2} = p$

យើងសង្កេតឃើញថា បើ $x<0$ នោះ $2^x \in \mathbb{Q} \Rightarrow 2^{2^x+2} \in \overline{\mathbb{Q}}$

$\Rightarrow p = x^8 + 2^{2^x+2} \notin \mathbb{N}$ មិនពិត ដូច្នេះ $x \geq 0$

បើ $x=0$ នោះ $p=2^3$ មិនមែនជាចំនួនបឋម ។

បើ $x=1$ នោះ $p=17$ ជាចំនួនបឋម គេបាន $x=1$ និង $p=17$ ជាចម្លើយមួយ

បើ $x \geq 2$:

$$p = \left(x^4\right)^2 + 4\cdot 2^{2^x}$$

$$= \left(x^4 + 2\cdot 2^{2^{x-1}}\right)^2 - 4x^4\cdot 2^{2^{x-1}}$$

$$= \left(x^4 + 2\cdot 2^{2^{x-1}} - 2x^2\cdot 2^{2^{x-2}}\right)\left(x^4 + 2\cdot 2^{2^{x-1}} + 2x^2\cdot 2^{2^{x-2}}\right)$$

ដើម្បីឲ្យ p អាចជាចំនួនបឋមលុះត្រាតែ: $x^4 + 2\cdot 2^{2^{x-1}} - 2x^2\cdot 2^{2^{x-2}} = 1$

$\Leftrightarrow \left(x^4 - 2x^2\cdot 2^{2^{x-2}} + 2^{2^{x-1}}\right) + 2^{2^{x-1}} = 1$

$\Leftrightarrow \left(x^2 - 2^{2^{x-2}}\right)^2 + 2^{2^{x-1}} = 1$ ជាករណីមិនអាច ។

ដូចនេះ $x=1$ និង $p=17$ ជាចម្លើយតែមួយគត់ ។

លំហាត់ទី៦៨

គេឲ្យ a_1, a_2, a_3, a_4, a_5 ជាចំនួនពិតដែលផ្ទៀងផ្ទាត់សមីការខាងក្រោម:

$\dfrac{a_1}{k^2+1} + \dfrac{a_2}{k^2+2} + \dfrac{a_3}{k^2+3} + \dfrac{a_4}{k^2+4} + \dfrac{a_5}{k^2+5} = \dfrac{1}{k^2}$ ចំពោះ $k = 1,2,3,4,5$ ។

ចូរកំណត់តម្លៃនៃ $\dfrac{a_1}{37} + \dfrac{a_2}{38} + \dfrac{a_3}{39} + \dfrac{a_4}{40} + \dfrac{a_5}{41}$ ។

(APMO 2009)

ដំណោះស្រាយ

តាង $P(x)=x^2(x^2+1)(x^2+2)(x^2+3)(x^2+4)(x^2+5)\left(\frac{a_1}{x^2+1}+\frac{a_2}{x^2+2}+\frac{a_3}{x^2+3}+\frac{a_4}{x^2+4}+\frac{a_5}{x^2+5}-\frac{1}{x^2}\right)$ ជាពហុធាដឺក្រេទី 10

ដោយ $\frac{a_1}{k^2+1}+\frac{a_2}{k^2+2}+\frac{a_3}{k^2+3}+\frac{a_4}{k^2+4}+\frac{a_5}{k^2+5}=\frac{1}{k^2}$ ចំពោះ $k=1,2,3,4,5$

នោះ $P(\pm1)=P(\pm2)=P(\pm3)=P(\pm4)=P(\pm5)=0$

នាំឲ្យ $x=\pm1,\pm2,\pm3,\pm4,\pm5$ គេបាន:

$$P(x)=\lambda(x^2-1^2)(x^2-2^2)(x^2-3^2)(x^2-4^2)(x^2-5^2)$$

នោះ $P(0)=-\lambda(5!)^2$

តែ: $P(x)=x^2(x^2+1)(x^2+2)(x^2+3)(x^2+4)(x^2+5)\left(\frac{a_1}{x^2+1}+\frac{a_2}{x^2+2}+\frac{a_3}{x^2+3}+\frac{a_4}{x^2+4}+\frac{a_5}{x^2+5}\right)-(x^2+1)(x^2+2)(x^2+3)(x^2+4)(x^2+5)$

នោះ $P(0)=-(5!)$ នាំឲ្យ $-\lambda(5!)^2=-(5!)\Rightarrow \lambda=\frac{1}{5!}$

គេបាន: $P(x)=\frac{1}{5!}(x^2-1^2)(x^2-2^2)(x^2-3^2)(x^2-4^2)(x^2-5^2)$

ដោយ: $P(x)=x^2(x^2+1)(x^2+2)(x^2+3)(x^2+4)(x^2+5)\left(\frac{a_1}{x^2+1}+\frac{a_2}{x^2+2}+\frac{a_3}{x^2+3}+\frac{a_4}{x^2+4}+\frac{a_5}{x^2+5}-\frac{1}{x^2}\right)$

នាំឲ្យ $\frac{a_1}{x^2+1}+\frac{a_2}{x^2+2}+\frac{a_3}{x^2+3}+\frac{a_4}{x^2+4}+\frac{a_5}{x^2+5}$

$$=\frac{\frac{1}{5!}(x^2-1^2)(x^2-2^2)(x^2-3^2)(x^2-4^2)(x^2-5^2)}{x^2(x^2+1)(x^2+2)(x^2+3)(x^2+4)(x^2+5)}+\frac{1}{x^2}$$

យក $x=6$ គេបាន:

$$\frac{a_1}{37}+\frac{a_2}{38}+\frac{a_3}{39}+\frac{a_4}{40}+\frac{a_5}{41}$$

$$=\frac{\frac{1}{5!}\left(6^2-1^2\right)\left(6^2-2^2\right)\left(6^2-3^2\right)\left(6^2-4^2\right)\left(6^2-5^2\right)}{6^2\left(6^2+1\right)\left(6^2+2\right)\left(6^2+3\right)\left(6^2+4\right)\left(6^2+5\right)}+\frac{1}{6^2}$$

$$=\frac{187465}{6744582}$$

ដូចនេះ $\frac{a_1}{37}+\frac{a_2}{38}+\frac{a_3}{39}+\frac{a_4}{40}+\frac{a_5}{41}=\frac{187465}{6744582}$ ត្រូវបានកំណត់ ។

លំហាត់ទី៦៥

រកគ្រប់អនុគមន៍ $f:\mathbb{N}\to\mathbb{N}$ ដែលផ្ទៀងផ្ទាត់: $f(1)=1$,

$f(mn)=\frac{f(m)f(n)}{f(\gcd(m,n))}$ និង $\underbrace{(f\circ f\circ\cdots\circ f)}_{2000}(m)=m$

ចំពោះគ្រប់ $m\ ,\ n\in\mathbb{N}$ ។

(Iran Mathematical Olympiad 2000)

ដំណោះស្រាយ

ចំពោះគ្រប់ $m\ ,\ n\in\mathbb{N}$ យើងមាន: $f(mn)=\frac{f(m)f(n)}{f(\gcd(m,n))}$

នោះយើងបាន: $f(4)=f(2\times 2)=\frac{f(2)f(2)}{f(\gcd(2,2))}=f(2)$

ម្យ៉ាងទៀត $\underbrace{(f\circ f\circ\cdots\circ f)}_{2000}(m)=m$ ចំពោះគ្រប់ $m\in\mathbb{N}$

នោះ $2=\underbrace{(f\circ f\circ\cdots\circ f)}_{2000}(2)=\underbrace{(f\circ f\circ\cdots\circ f)}_{1999}(f(2))$

$=\underbrace{(f\circ f\circ\cdots\circ f)}_{1999}(f(4))=\underbrace{(f\circ f\circ\cdots\circ f)}_{2000}(4)=4$ ជាករណីមិនអាចមាន ។

ដូចនេះ គ្មានអនុគមន៍ f ណាផ្ទៀងផ្ទាត់លក្ខខណ្ឌប្រធានលំហាត់នោះទេ ។

លំហាត់ទី៦៦

គេឲ្យ a , b , c , d ជាចំនួនពិតវិជ្ជមានដែល:

$\frac{1}{1+a^4}+\frac{1}{1+b^4}+\frac{1}{1+c^4}+\frac{1}{1+d^4}=1$ ។ ចូរស្រាយបញ្ជាក់ថា: $abcd\geq 3$ ។

(Latvia 2002)

ដំណោះស្រាយ

តាង $a^2=\tan A$, $b^2=\tan B$, $c^2=\tan C$, $d^2=\tan D$

ដូច្នេះសមភាពដែលគេឲ្យសមមូល:

$$\frac{1}{1+\tan^2 A}+\frac{1}{1+\tan^2 B}+\frac{1}{1+\tan^2 C}+\frac{1}{1+\tan^2 D}=1$$

$$\Leftrightarrow\ \cos^2 A+\cos^2 B+\cos^2 C+\cos^2 D=1$$

$$\Rightarrow\ 1-\cos^2 A=\cos^2 B+\cos^2 C+\cos^2 D\geq 3\sqrt[3]{\cos^2 B\cdot\cos^2 C\cdot\cos^2 D}$$

$$\Leftrightarrow\ \sin^2 A\geq 3\sqrt[3]{\cos^2 B\cdot\cos^2 C\cdot\cos^2 D}$$

ដូចគ្នាដែរ: $\sin^2 B\geq 3\sqrt[3]{\cos^2 A\cdot\cos^2 C\cdot\cos^2 D}$

$$\sin^2 C\geq 3\sqrt[3]{\cos^2 A\cdot\cos^2 B\cdot\cos^2 D}$$

$$\sin^2 D\geq 3\sqrt[3]{\cos^2 A\cdot\cos^2 B\cdot\cos^2 C}$$

គុណអង្គនិងអង្គនៃវិសមភាពទាំងបួនខាងលើ គេបាន:

$$\sin^2 A\cdot\sin^2 B\cdot\sin^2 C\cdot\sin^2 D\geq 3^4\cos^2 A\cdot\cos^2 B\cdot\cos^2 C\cdot\cos^2 D$$

$$\Leftrightarrow\ \tan^2 A\cdot\tan^2 B\cdot\tan^2 C\cdot\tan^2 D\geq 3^4$$

$$\Leftrightarrow\ a^4b^4c^4d^4\geq 3^4$$

$\Rightarrow \quad abcd \geq 3$

ដូចនេះ $abcd \geq 3$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៦៧

ចូរស្រាយបញ្ជាក់ថា បើ m, n និង r ជាចំនួនគត់វិជ្ជមាន ហើយ
$1+m+n\sqrt{3}=\left(2+\sqrt{3}\right)^{2r-1}$ នោះ m ជាការេប្រាកដ ។

(British Mathematical Olympiad 1986)

ដំណោះស្រាយ

តាមរូបមន្តពន្លាតទ្វេធា *Newton* គេមាន:

$$\left(2+\sqrt{3}\right)^{2r-1}=\sum_{k=0}^{2r-1} C_{2r-1}^{k}\cdot 2^{(2r-1)-k}\cdot\left(\sqrt{3}\right)^{k}$$
$$=\left(2^{2r-1}+3C_{2r-1}^{2}\cdot 2^{2r-3}+\cdots+3^{r-1}C_{2r-1}^{2r-2}\cdot 2\right)$$
$$+\left(C_{2r-1}^{1}\cdot 2^{2r-2}+3C_{2r-1}^{3}\cdot 2^{2r-4}+\cdots+3^{r-1}C_{2r-1}^{2r-1}\right)\sqrt{3}$$

ហើយដូចគ្នាដែរចំពោះ

$$\left(2-\sqrt{3}\right)^{2r-1}=\sum_{k=0}^{2r-1} C_{2r-1}^{k}\cdot 2^{(2r-1)-k}\cdot\left(-\sqrt{3}\right)^{k}$$
$$=\left(2^{2r-1}+3C_{2r-1}^{2}\cdot 2^{2r-3}+\cdots+3^{r-1}C_{2r-1}^{2r-2}\cdot 2\right)$$
$$-\left(C_{2r-1}^{1}\cdot 2^{2r-2}+3C_{2r-1}^{3}\cdot 2^{2r-4}+\cdots+3^{r-1}C_{2r-1}^{2r-1}\right)\sqrt{3}$$

តាង $a=2^{2r-1}+3C_{2r-1}^{2}\cdot 2^{2r-3}+\cdots+3^{r-1}C_{2r-1}^{2r-2}\cdot 2$

ហើយ $b=C_{2r-1}^{1}\cdot 2^{2r-2}+3C_{2r-1}^{3}\cdot 2^{2r-4}+\cdots+3^{r-1}C_{2r-1}^{2r-1}$ ដែល a និង b សុទ្ធតែ ជាចំនួនគត់វិជ្ជមាន ក្នុងនោះ $a+1=\left(2^{2r-1}+1\right)+3C_{2r-1}^{2}\cdot 2^{2r-3}+\cdots+3^{r-1}C_{2r-1}^{2r-2}\cdot 2$ $=3x$ ដែល $x=\left(2^{2r-2}-2^{2r-3}+\cdots-2+1\right)+\left(C_{2r-1}^{2}\cdot 2^{2r-3}+\cdots+3^{r-2}C_{2r-1}^{2r-1}\cdot 2\right)$ ជាចំនួនគត់សេស យើងបាន: $\left(2+\sqrt{3}\right)^{2r-1}=a+b\sqrt{3}$ និង

$$\left(2-\sqrt{3}\right)^{2r-1}=a-b\sqrt{3}$$

នាំឲ្យ $\left(2+\sqrt{3}\right)^{2r-1}\left(2-\sqrt{3}\right)^{2r-1}=\left(a+b\sqrt{3}\right)\left(a-b\sqrt{3}\right)$

$\Leftrightarrow\ a^2-3b^2=1\ \Leftrightarrow\ (a-1)\left(\dfrac{a+1}{3}\right)=b^2\quad(*)$

យើងនឹងស្រាយថា៖ $\gcd\left(a-1,\dfrac{a+1}{3}\right)=1$

តាង $d=\gcd\left(a-1,\dfrac{a+1}{3}\right)$ នោះ $a-1=pd$ និង $\dfrac{a+1}{3}=qd$ ដែល $\gcd(p,q)=1$

នាំឲ្យ $(a-1)-3\left(\dfrac{a+1}{3}\right)=pd-3qd$ ឬ $(3q-p)d=2$ នាំឲ្យ $d|2$

ដោយ $a-1=3x-2$ និង $\dfrac{a+1}{3}=x$ សុទ្ធតែជាចំនួនគត់សេស នោះ

$d=\gcd\left(a-1,\dfrac{a+1}{3}\right)$ ក៏ត្រូវតែជាចំនួនគត់សេសដែរ យើងទាញបាន៖ $d=1$

មានន័យថា $a-1$ និង $\dfrac{a+1}{3}$ ជាចំនួនបឋមរវាងគ្នា តាម $(*)$ នាំឲ្យ $a-1$ និង $\dfrac{a+1}{3}$ ត្រូវតែជាការេប្រាកដទាំងពីរ ។

ដោយ $\left(2+\sqrt{3}\right)^{2r-1}=a+b\sqrt{3}$ តែតាមសម្មតិកម្ម៖

$$1+m+n\sqrt{3}=\left(2+\sqrt{3}\right)^{2r-1}$$

ទាញបាន៖ $1+m=a$ នោះ $m=a-1$ ជាការេប្រាកដ ។

ដូចនេះ m ជាការេប្រាកដ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៦៨

ចូរស្រាយបញ្ជាក់ថា ប្រព័ន្ធសមីការ $x^3+y^3+z^3=x+y+z$ និង $x^2+y^2+z^2=xyz$ គ្មានចម្លើយ (x,y,z) ជាចំនួនពិតវិជ្ជមានទេ ។

(Canadian Mathematical Olympiad 2003)

ដំណោះស្រាយ

តាង $f(x,y,z)=(x^3-x)+(y^3-y)+(z^3-z)$

ដោយ $x^3+y^3+z^3=x+y+z$ នោះ $f(x,y,z)=0$

បើ $x,y,z\geq 1$ នោះ $f(x,y,z)\geq 0$ ដែលសមភាពកើតមានកាលណា: $x=y=z=1$ តែបើ $x=y=z=1$ នោះសមីការ $x^2+y^2+z^2=xyz$ មិនផ្ទៀងផ្ទាត់ នេះបញ្ជាក់ថា បើប្រព័ន្ធសមីការមានចម្លើយ (x,y,z) ជាចំនួនពិតវិជ្ជមាន នោះយ៉ាងតិចបំផុតមានមួយនៃអញ្ញាតទាំងបីត្រូវតែតូចជាង 1 យើងសន្មតថា: $x<1$ គេបាន: $x^2+y^2+z^2>y^2+z^2\geq 2yz>yz>xyz$ ផ្ទុយពីសម្មតិកម្ម: $x^2+y^2+z^2=xyz$ ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា: ប្រព័ន្ធសមីការគ្មានចម្លើយ (x,y,z) ជាចំនួនពិតវិជ្ជមាននោះទេ ។

លំហាត់ទី៦៩

គេឲ្យ $f(x)$ ជាពហុធា *monic* ដឺក្រេទី 1991 ដែលមានមេគុណជាចំនួនគត់ ហើយគេតាង $g(x)=\left(f(x)\right)^2-9$ ។ ចូរស្រាយបញ្ជាក់ថា: ចំនួននៃឫសដែលជាចំនួនគត់ខុសៗគ្នារបស់សមីការ $g(x)=0$ មិនអាចលើសពី 1995 នោះទេ ។

(IMO Shortlist 1991)

ដំណោះស្រាយ

យើងមាន: $g(x)=\left(f(x)\right)^2-9=\left(f(x)-3\right)\left(f(x)+3\right)$

តាង $x_1, x_2, x_3, \ldots, x_k$ ជាឫសគត់ខុសៗគ្នានៃសមីការ $f(x)-3=0$ និង $y_1, y_2, y_3, \ldots, y_h$ ជាជាឫសគត់ខុសៗគ្នានៃសមីការ $f(x)+3=0$ ហើយយើងសន្មតថា: $x_1<x_2<x_3<\cdots<x_k$, $y_1<y_2<y_3<\cdots<y_h$ និង $x_i\neq y_j$ ។

ឧបមាថា: ចំនួននៃឫសគត់ខុសៗគ្នារបស់សមីការ $g(x)=0$ លើសពី 1995 នោះមានន័យថា: $k+h>1995$ ឬ $k+h\geq 1996$

ដោយ $f(x)$ មានដឺក្រេ 1991 នោះឫសនៃសមីការ $f(x)-3=0$ និង $f(x)+3=0$ មានចំនួនមិនលើសពី 1991 ទេ គឺថា: $k\leq 1991$ និង $h\leq 1991$

នាំឲ្យ $k, h\geq 5$

ដោយឫសនៃសមីការ $g(x)=0$ សុទ្ធតែជាចំនួនគត់ខុសៗគ្នា នោះច្បាស់ជាមាន i, j ដែល $\left|x_i-y_j\right|\geq 7$ $(*)$

តាង $f(x)=x^{1991}+a_{1990}x^{1990}+\cdots+a_0$,($f(x)$ ជាពហុធា *monic* ដឺក្រេទី 1991)

នោះ $f(x_i)-3=0$ គ្រប់ $i=1,2,3,\ldots,k$ និង $f\left(y_j\right)+3=0$ គ្រប់ $j=1,2,3,\ldots,h$ ។

គេបាន:

$$\begin{cases} x_i^{1991} + a_{1990}x_i^{1990} + \cdots + a_0 = 3 \\ y_j^{1991} + a_{1990}y_j^{1990} + \cdots + a_0 = -3 \end{cases}$$

ដកអង្គនិងអង្គគេបាន: $\left(x_i^{1991} - y_j^{1991}\right) + \left(x_i^{1990} - y_j^{1990}\right)a_{1990} + \cdots + \left(x_i - y_j\right)a_1 = 6$

ដោយ $x_i - y_j \mid x_i^m - y_j^m$ ចំពោះគ្រប់ $m = 1,2,3,\ldots,1991$

នាំឲ្យ $x_i - y_j \mid 6$ នោះ $\left|x_i - y_j\right| \le 6$ ចំពោះគ្រប់ $i = 1,2,3,\ldots,k$ និង $j = 1,2,3,\ldots,h$ ផ្ទុយពី $(*)$ នេះបញ្ជាក់ថា: ការឧបមាខាងលើគឺខុស ។

ដូចនេះ ចំនួនឫសនៃសមីការ $g(x) = 0$ មិនអាចលើសពី 1995 នោះទេ ។

<u>លំហាត់ទី៧០</u>

គេឲ្យ a, b, c ជាចំនួនពិតវិជ្ជមានដែល $a + b + c = 1$ ។

ចូរបង្ហាញថា: $\sqrt{a^{1-a}b^{1-b}c^{1-c}} \le \dfrac{1}{3}$ ។

(Austria Mathematical Olympiad 2008)

<u>ដំណោះស្រាយ</u>

របៀបទី១

តាមលក្ខណៈស៊ីមេទ្រី យើងសន្មតថា: $a \ge b \ge c > 0$

នាំឲ្យ $\log a \ge \log b \ge \log c$ គេបាន: $(a-b)(\log a - \log b) \ge 0$,

$(b-c)(\log b - \log c) \ge 0$ និង $(a-c)(\log a - \log c) \ge 0$

នោះ: $(a-b)(\log a - \log b) + (b-c)(\log b - \log c) + (a-c)(\log a - \log c) \ge 0$

$$\Leftrightarrow 2(a\log a + b\log b + c\log c) \ge (\log b + \log c)a + (\log c + \log a)b + (\log a + \log b)c$$

$$\Leftrightarrow 2\left(\log a^a + \log b^b + \log c^c\right) \ge a\log bc + b\log ca + c\log ab$$

$\Leftrightarrow\ 2\log a^a b^b c^c \geq \log b^a c^a + \log c^b a^b + \log a^c b^c$

$\Leftrightarrow\ 2\log a^a b^b c^c + \log a^a b^b c^c \quad \geq \log b^{a+c} c^{b+a} a^{b+c} + \log a^a b^b c^c$

$\Leftrightarrow\ 3\log a^a b^b c^c \geq \log a^{a+b+c} b^{a+b+c} c^{a+b+c}$

$\Leftrightarrow\ \log\left(a^a b^b c^c\right)^3 \geq \log abc$ ព្រោះ $a+b+c=1$

$\Leftrightarrow \left(a^a b^b c^c\right)^3 \geq abc$

$\Leftrightarrow\ a^a b^b c^c \geq (abc)^{\frac{1}{3}} = (abc)(abc)^{-\frac{2}{3}}$

$\Leftrightarrow\ \dfrac{abc}{a^a b^b c^c} \leq (abc)^{\frac{2}{3}}$

$\Leftrightarrow\ \sqrt{a^{1-a} b^{1-b} c^{1-c}} \leq \sqrt[3]{abc} \leq \dfrac{a+b+c}{3} = \dfrac{1}{3}$

ដូចនេះវិសមភាព $\sqrt{a^{1-a} b^{1-b} c^{1-c}} \leq \dfrac{1}{3}$ ត្រូវបានស្រាយបញ្ជាក់ ។

របៀបទី២

តាមលក្ខណះស៊ីមេទ្រី យើងសន្មតថាៈ $a \geq b \geq c > 0$

នាំឲ្យ $\log a \geq \log b \geq \log c$ ដោយប្រើវិសមភាព *Chebyshev* គេបានៈ

$\dfrac{a+b+c}{3} \cdot \dfrac{\log a + \log b + \log c}{3} \leq \dfrac{a\log a + b\log b + c\log c}{3}$

$\Leftrightarrow\ \log abc \leq \log\left(a^a b^b c^c\right)^3$ ព្រោះ $a+b+c=1$

$\Leftrightarrow\ abc \leq \left(a^a b^b c^c\right)^3 \Rightarrow \sqrt{a^{1-a} b^{1-b} c^{1-c}} \leq \sqrt[3]{abc} \leq \dfrac{a+b+c}{3} = \dfrac{1}{3}$

ដូចនេះវិសមភាព $\sqrt{a^{1-a} b^{1-b} c^{1-c}} \leq \dfrac{1}{3}$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៧១

តាង f ជាអនុគមន៍មួយកំណត់ពីសំណុំនៃចំនួនគត់ទៅសំណុំនៃចំនួនគត់វិជ្ជមាន , គេសន្មតថា ចំពោះពីរចំនួនគត់ m និង n នោះផលសង $f(m)-f(n)$ ចែកដាច់នឹង $f(m-n)$ ។ ចូរស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនគត់ m និង n ដែល $f(m)\le f(n)$ នោះ ចំនួន $f(n)$ ចែកដាច់នឹង $f(m)$ ។

(IMO 2011)

ដំណោះស្រាយ

ចំពោះគ្រប់ចំនួនគត់ m និង n គេមាន: $f(m-n)|f(m)-f(n)$

យក $n=0$ នោះ $f(m)|f(m)-f(0)$ នាំឲ្យ $f(m)|f(0)$ ចំពោះគ្រប់ចំនួនគត់ m ។

យក $m=0$ នោះ $f(-n)|f(0)-f(n)$ នាំឲ្យ $f(-n)|f(n)$ ហើយគេក៏បាន: $f(n)|f(-n)$ ទាញបាន: $f(-n)=f(n)$ ចំពោះគ្រប់ចំនួនគត់ n

ហើយ $f(m+n)=f\left(m-(-n)\right)|f(m)-f(-n)=f(m)-f(n)$ ។

ចំពោះចំនួនគត់ m និង n ដែល $f(m)\le f(n)$ នោះគេបាន:

$f(m+n)\le f(n)-f(m)$

ម្យ៉ាងទៀត $f(n)=f\left((m+n)-m\right)|f(m+n)-f(m)$

នាំឲ្យ $f(n)\le|f(m+n)-f(m)|$ ឬ $f(m+n)-f(m)=0$

*ករណី $f(n)\le|f(m+n)-f(m)|$ នោះ $f(n)\le f(m+n)-f(m)$ ឬ $-f(n)\ge f(m+n)-f(m)$

បើ $f(n)\le f(m+n)-f(m)$

នាំឲ្យ $f(n)+f(m)\le f(m+n)\le f(n)-f(m)$

គេបាន: $2f(m)\le 0$ មិនពិតព្រោះ f មានតម្លៃជាចំនួនគត់វិជ្ជមាន ។

បើ $-f(n)\geq f(m+n)-f(m)$

នាំឲ្យ $f(m)\leq f(n)\leq f(m)-f(m+n)$

គេបាន: $f(m+n)\leq 0$ មិនពិតព្រោះ f មានតម្លៃជាចំនួនគត់វិជ្ជមាន ។

*ករណីចុងក្រោយ $f(m+n)-f(m)=0$ ឬ $f(m+n)=f(m)$

ដោយ $f(m+n)|f(m)-f(n) \Leftrightarrow f(m)|f(m)-f(n)$

នាំឲ្យ $f(m)|f(n)$

ដូចនេះ ចំពោះគ្រប់ចំនួនគត់ m និង n ដែល $f(m)\leq f(n)$ នោះចំនួន $f(n)$ ចែកដាច់នឹង $f(m)$ ។

លំហាត់ទី៧២

គេឲ្យ a និង b ជាចំនួនគត់វិជ្ជមាន ។ ចូរស្រាយបញ្ជាក់ថា បើ $4ab-1$ ជាតួចែកនៃ $(4a^2-1)^2$ នោះ $a=b$ ។

(IMO 2007)

ដំណោះស្រាយ

បើ $a=b$ នោះ $4ab-1|(4a^2-1)^2$ ពិត ។

ឧបមាថា: មានគូ $(a,b)\in\mathbb{N}^2$ ដែល $a\neq b$ ហើយផ្ទៀងផ្ទាត់ $4ab-1|(4a^2-1)^2$

ជ្រើសរើសគូ (a,b) មួយណាដែលធ្វើឲ្យ $2a+b$ មានតម្លៃតូចជាងគេ

គេពិនិត្យ: $4b^2-1=4b^2-(4ab)^2+(4ab)^2-1$

$$=4b^2-(4ab)^2+(4ab-1)(4ab+1)$$

$$\equiv 4b^2(1-4a^2)\ (\operatorname{mod} 4ab-1)$$

$$\Rightarrow\ (4b^2-1)^2\equiv 16b^4(4a^2-1)^2\equiv 0(\operatorname{mod} 4ab-1)$$

$\Rightarrow\ 4ab-1|(4b^2-1)^2$ បញ្ជាក់ថា: (b,a) ក៏ជាគូដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

លំហាត់ដែរ គេបាន: $2b+a>2a+b$ នោះ $b>a$ ។

ម្យ៉ាងទៀត: $4ab-1 \mid (4a^2-1)^2$

$\Rightarrow (4a^2-1)^2=(4ab-1)k$ ដែល $k\in\mathbb{N}$

ដោយ $4ab-1\equiv -1 \pmod{4a} \Rightarrow k(4ab-1)\equiv -k \pmod{4a}$

$\Rightarrow (4a^2-1)^2\equiv -k \pmod{4a}$ តែ $(4a^2-1)^2\equiv 1 \pmod{4a}$

ទាញបាន: $k=4al-1$ ដែល $l\in\mathbb{N}$ ហើយ $(4a^2-1)^2=(4ab-1)k$

នោះ $k=4al-1 \mid (4a^2-1)^2$ បញ្ជាក់ថា: (a,l) ក៏ជាគូដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

លំហាត់ដែរ គេបាន: $2a+l>2a+b \Rightarrow l>b>a \quad (*)$

ដោយ $(4a^2-1)^2=(4ab-1)(4al-1)$

$\Leftrightarrow 16a^4-8a^2+1=16a^2bl-4ab-4al+1$

$\Rightarrow 4a^3-2a=4abl-b-l=(4al-1)b-l>(4al-1)a-l$

$\Leftrightarrow 4a^3-2a>4a^2l-a-l$

$\Leftrightarrow 4a^3-a>4a^2l-l$

$\Leftrightarrow (4a^2-1)a>(4a^2-1)l$

$\Rightarrow a>l$ ផ្ទុយពី $(*)$ នេះបញ្ជាក់ថា: ការឧបមាដែលថាមានគូ $(a,b)\in\mathbb{N}^2$

ដែល $a\neq b$ ហើយផ្ទៀងផ្ទាត់ $4ab-1 \mid (4a^2-1)^2$ មិនពិតទេ ។

ដូចនេះ បើ $4ab-1$ ជាតួចែកនៃ $(4a^2-1)^2$ លុះត្រាតែ $a=b$ ។

លំហាត់ទី៧៣

គេឲ្យ $a_1, a_2, \dots, a_n, \dots$ ជាស្វ៊ីតនៃចំនួនពិតដែលផ្ទៀងផ្ទាត់: $0\le a_n\le 1$ និង $a_n-2a_{n+1}+a_{n+2}\ge 0$ ចំពោះ $n=1,2,3,\dots$ ។ ចូរស្រាយបញ្ជាក់ថា: $0\le (n+1)(a_n-a_{n+1})\le 2$ ចំពោះគ្រប់ $n=1,2,3,\dots$ ។

(IMO Shortlist 1975)

ដំណោះស្រាយ

ចំពោះ $n=1,2,3,\ldots$ យើងមាន: $a_n-2a_{n+1}+a_{n+2}\ge 0$

$\Leftrightarrow\ a_n-a_{n+1}\ge a_{n+1}-a_{n+2}$

តាង $\Delta a_n=a_n-a_{n+1}$ នាំឲ្យ $\Delta a_n\ge \Delta a_{n+1}$ នោះចំពោះ $k\ge n$, $\Delta a_k\le \Delta a_n$

គេបាន: $a_n-a_{n+m}=\left(a_n-a_{n+1}\right)+\left(a_{n+1}-a_{n+2}\right)+\cdots+\left(a_{n+m-1}-a_{n+m}\right)$

$$=\Delta a_n+\Delta a_{n+1}+\cdots+\Delta a_{n+m-1}\le\ m\Delta a_n$$

$\Leftrightarrow\ a_n-a_{n+m-1}\le\ m\Delta a_n$

ឧបមាថា: $\Delta a_n<0$ ចំពោះ n ខ្លះ នោះចំពោះ m មានតម្លៃធំគ្រប់គ្រាន់ គេបាន:

$a_n-a_{n+m}<-1$ មិនពិតព្រោះ $0\le a_n\le 1$, $n=1,2,3,\ldots$ ។

ដូច្នេះការឧបមាខាងលើគឺខុស មានន័យថា: $\Delta a_n\ge 0$ ចំពោះគ្រប់ $n=1,2,3,\ldots$

គេបាន $(n+1)\Delta a_n\ge 0$ ចំពោះគ្រប់ $n=1,2,3,\ldots$ (1)

ម្យ៉ាងទៀត: $0\le a_n\le 1$, $n=1,2,3,\ldots$

នោះ $n\ge a_1+a_2+a_3+\cdots+a_n$

$$=\left(a_1-a_2\right)+2\left(a_2-a_3\right)+\cdots+n\left(a_n-a_{n+1}\right)+na_{n+1}$$

$$=\Delta a_1+2\Delta a_2+\cdots+n\Delta a_n+na_{n+1}$$

$$\ge\Delta a_n+2\Delta a_n+\cdots+n\Delta a_n=\left(1+2+\cdots+n\right)\Delta a_n=\frac{n\left(n+1\right)}{2}\Delta a_n$$

នាំឲ្យ $(n+1)\Delta a_n\le 2$ (2)

តាម (1) និង (2) គេបាន: $0\le(n+1)\Delta a_n\le 2$

ដូចនេះ $0\le(n+1)\left(a_n-a_{n+1}\right)\le 2$ ចំពោះគ្រប់ $n=1,2,3,\ldots$ ។

លំហាត់ទី៧៤

គេឲ្យ $a_1,a_2,\dots,a_n$ ជាចំនួនពិត ។ ចំពោះគ្រប់ i $(1\le i\le n)$ គេកំណត់:

$d_i=\max\{a_i:1\le j\le i\}-\min\{a_j:i\le j\le n\}$ ហើយគេតាង

$d=\max\{d_i:1\le i\le n\}$ ។

ក/ ចូរស្រាយបញ្ជាក់ថា ចំពោះចំនួនពិត $x_1\le x_2\le\cdots\le x_n$ នោះ

$\max\{|x_i-a_i|:1\le i\le n\}\ge\dfrac{d}{2}$ $(*)$ ។

ខ/ ចូរបង្ហាញថា មានចំនួនពិត $x_1\le x_2\le\cdots\le x_n$ ដែលធ្វើឲ្យ $(*)$ ក្លាយជាសមភាព ។

(IMO 2007)

ដំណោះស្រាយ

ក/. ស្រាយបញ្ជាក់ថា ចំពោះចំនួនពិត $x_1\le x_2\le\cdots\le x_n$ នោះ

$\max\{|x_i-a_i|:1\le i\le n\}\ge\dfrac{d}{2}$ $(*)$:

យើងសន្មតថា: $d=\max\{d_i:1\le i\le n\}=d_m$ ចំពោះសន្ទស្សន៍ m , $(1\le m\le n)$ ណាមួយ ហើយតាង k និង l , $(1\le k\le m\le l\le n)$ ជាសន្ទស្សន៍ដែល $d_m=a_k-a_l$ នោះយើងបាន: $d_m=a_k-a_l\le(a_k-x_k)+(x_l-a_l)$

(ព្រោះដោយ $k\le l$ នោះ $x_k\le x_l$ ឬ $x_l-x_k\ge 0$)

យើងទាញបាន: $a_k-x_k\ge\dfrac{d_m}{2}=\dfrac{d}{2}$ ឬ $x_l-a_l\ge\dfrac{d_m}{2}=\dfrac{d}{2}$

ដូចនេះ $\max\{|x_i-a_i|:1\le i\le n\}\ge\dfrac{d}{2}$ ចំពោះចំនួនពិត $x_1\le x_2\le\cdots\le x_n$ ។

ខ/.មានចំនួនពិត $x_1\le x_2\le\cdots\le x_n$ ដែលធ្វើឲ្យ $(*)$ ក្លាយជាសមភាព:

តាង $M_i=\max\{a_j:1\le j\le i\}$ និង $m_i=\min\{a_j:i\le j\le n\}$

យើងយក $x_i=\dfrac{m_i+M_i}{2}$ នោះ $\{x_i\}$ ជាស្វ៊ីតមិនចុះ ព្រោះ $\{m_i\}$ និង $\{M_i\}$ សុទ្ធ

តែជាស្វ៊ីតមិនចុះ ។

ដោយ $m_i \le a_i \le M_i$ និង $d_i = M_i - m_i$ នោះយើងបាន:

$$-\frac{d_i}{2} = \frac{m_i - M_i}{2} = \frac{m_i + M_i - 2M_i}{2} = \frac{m_i + M_i}{2} - M_i = x_i - M_i \le x_i - a_i$$

គឺថា: $x_i - a_i \ge -\frac{d_i}{2} \quad (1)$

ហើយ $\frac{d_i}{2} = \frac{M_i - m_i}{2} = \frac{M_i + m_i - 2m_i}{2} = \frac{M_i + m_i}{2} - m_i = x_i - m_i \ge x_i - a_i$

គឺថា: $x_i - a_i \le \frac{d_i}{2} \quad (2)$

តាម (1) និង (2) យើងបាន: $-\frac{d_i}{2} \le x_i - a_i \le \frac{d_i}{2}$ នោះ $|x_i - a_i| \le \frac{d_i}{2}$

នាំឲ្យ $\max\{|x_i - a_i| : 1 \le i \le n\} \le \max\left\{\frac{d_i}{2} : 1 \le i \le n\right\} = \frac{d}{2}$

តែតាម $(*)$ គេទាញបាន: $\max\{|x_i - a_i| : 1 \le i \le n\} = \frac{d}{2}$ ចំពោះស្វ៊ីត $\{x_i\}$ ។

ដូចនេះ មានចំនួនពិត $x_1 \le x_2 \le \cdots \le x_n$ ដែលធ្វើឲ្យ $(*)$ ក្លាយជាសមភាព ។

__លំហាត់ទី៧៨__

រកគ្រប់ចំនួនបឋម p ដែលផ្ទៀងផ្ទាត់: $2^p + p^2$ ក៏ជាចំនួនបឋមដែរ ។

(Albanian IMO TST 2011)

__ដំណោះស្រាយ__

បើ $p = 2$ នោះ $2^p + p^2 = 8$ មិនមែនជាចំនួនបឋម ។

បើ $p = 3$ នោះ $2^p + p^2 = 17$ ជាចំនួនបឋមនាំឲ្យ $p = 3$ ជាចម្លើយមួយ ។

បើ $p > 3$ (p ត្រូវតែជាចំនួនសេស) នោះ $2^p \equiv (-1)^p \equiv -1 \pmod 3$

ហើយតាមទ្រឹស្តីបទ $Fermat$: $p^2 \equiv 1 \pmod 3$ គេបាន: $2^p + p^2 \equiv 0 \pmod 3$

នោះ $2^p + p^2$ មិនមែនជាចំនួនបឋមទេ ។

ដូចនេះ $p = 3$ ជាចំនួនបឋមតែមួយគត់ដែលធ្វើឲ្យ $2^p + p^2$ ក៏ជាចំនួនបឋមដែរ

លំហាត់ទី៧៦

តាង a, b, c ជាចំនួនពិត ។ ចូរស្រាយបញ្ជាក់ថា:

$$ab + bc + ca + \max\{|a-b|, |b-c|, |c-a|\} \leq 1 + \frac{1}{3}(a+b+c)^2 \quad ។$$

(Baltic Way 2012)

ដំណោះស្រាយ

វិសមភាពដែលត្រូវស្រាយអាចសរសេរជា:

$$\Leftrightarrow \ 4\left((a+b+c)^2 - 3(ab+bc+ca)\right) + 12 \geq 12\max\{|a-b|, |b-c|, |c-a|\}$$

$$\Leftrightarrow \ T = 2\left((a-b)^2 + (b-c)^2 + (c-a)^2\right) + 12 \geq 12\max\{|a-b|, |b-c|, |c-a|\}$$

តាមវិសមភាព $Cauchy - Schwarz$:

$$(a-b)^2 = \left((a-c)+(c-b)\right)^2 \leq 2\left((a-c)^2 + (c-b)^2\right)$$

$$\Leftrightarrow 2\left((a-b)^2 + (b-c)^2 + (c-a)^2\right) \geq 3(a-b)^2$$

ស្រាយដូចគ្នា: $2\left((a-b)^2 + (b-c)^2 + (c-a)^2\right) \geq 3(b-c)^2$

និង $2\left((a-b)^2 + (b-c)^2 + (c-a)^2\right) \geq 3(c-a)^2$

គេបាន: $T \geq 3(a-b)^2 + 12 = 3\left((a-b)^2 + 4\right) \geq 3 \cdot 2\sqrt{(a-b)^2 \cdot 4} = 12|a-b|$

ដូចគ្នាដែរ: $T \geq 12|b-c|$ និង $T \geq 12|c-a|$

យើងទាញបាន: $T \geq 12\max\{|a-b|, |b-c|, |c-a|\}$ ពិត ។

ដូចនេះវិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៧៧

ចូរកំណត់គ្រប់ពហុធា $P(x)$ ដែលមានមេគុណជាចំនួនពិតហើយផ្ទៀងផ្ទាត់: $(x+1)P(x-1)-(x-1)P(x)$ ជាពហុធាថេរ ។

(Canadian Mathematical Olympiad 2013)

ដំណោះស្រាយ

តាង $R(x)=(x+1)P(x-1)-(x-1)P(x)$

$\Rightarrow R(-1)=2P(-1)$ និង $R(1)=2P(0)$

ដោយ $R(x)$ ជាពហុធាថេរ នោះ $R(-1)=R(1)$

$\Rightarrow P(-1)=P(0)=k$ ចំពោះចំនួនថេរ k ណាមួយ

ដូច្នេះយើងអាចតាង $P(x)=x(x+1)Q(x)+k$ ដែល $Q(x)$ ជាពហុធាមួយ

នោះ $P(x-1)=x(x-1)Q(x-1)+k$

យើងបាន: $R(x)=(x+1)x(x-1)Q(x-1)+(x+1)k-(x-1)x(x+1)Q(x)$

$-(x-1)k=x(x-1)(x+1)\left(Q(x-1)-Q(x)\right)+2k$

$R(x)$ ជាពហុធាថេរលុះត្រាតែ: $Q(x-1)=Q(x)$ ចំពោះគ្រប់ x

$\Rightarrow Q(x-1)=Q(x)=c$ ចំពោះចំនួនថេរ c ណាមួយ

ដូចនេះ $P(x)=cx(x+1)+k$ ដែល $c\,,k$ ជាចំនួនថេរ ។

លំហាត់ទី៧៨

គេឲ្យ $34!=295232799cd96041408476186096435ab000000$ ។

ចូរកំណត់លេខខ្ទង់ $a\,,b\,,c\,,d$ ។

(British Mathematical Olympiad 2002)

ដំណោះស្រាយ

តាមសម្មតិកម្ម: $34!=295232799cd96041408476186096435ab\times10^{6}$

តែ $34!=1\cdot2\cdot3\cdots33\cdot34=2^{32}\cdot3^{15}\cdot5^{7}\cdot7^{4}\cdot11^{3}\cdot13^{2}\cdot17^{2}\cdot19\cdot23\cdot29\cdot31$

$=19\cdot23\cdot29\cdot31\cdot2^{25}\cdot3^{15}\cdot7^{4}\cdot11^{3}\cdot13^{2}\cdot17^{2}\cdot10^{7}$

នាំឲ្យ $295232799cd96041408476186096435ab$

$=19\cdot23\cdot29\cdot31\cdot2^{25}\cdot3^{15}\cdot7^{4}\cdot11^{3}\cdot13^{2}\cdot17^{2}\cdot10 \qquad (*)$

ទាញបាន: $b=0$ ហើយ $a\neq0$ ។

យើងសង្កេតឃើញថា: អង្គទី២នៃ $(*)$ ចែកដាច់នឹង 4 នោះអង្គទី១នៃ $(*)$ ក៏ត្រូវចែកដាច់នឹង 4 ដែរ នាំឲ្យ $\overline{5a}$ ចែកដាច់នឹង 4 ទាញបាន: $a=2$ ។

ម្យ៉ាងទៀត អង្គទី២នៃ $(*)$ ចែកដាច់នឹង 9 ផង 11ផង នោះអង្គទី១នៃ $(*)$ ក៏ត្រូវមានលក្ខណះ ដូច្នេះដែរ គេបាន:

$$\begin{cases}141+c+d\equiv0(\text{mod}9)\\(80+d)-(61+c)\equiv0(\text{mod}11)\end{cases}$$

$$\Leftrightarrow\begin{cases}c+d\equiv3(\text{mod}9)\\d-c\equiv3(\text{mod}11)\end{cases}$$

ដោយ $0\le c,d\le9$ នោះ $-9\le d-c\le9$ និង $0\le c+d\le18$

$$\Rightarrow\begin{cases}c+d=\{3,12\}\\d-c=\{-8,3\}\end{cases}$$

$*$ករណី $\begin{cases}c+d=3\\d-c=-8\end{cases}\Rightarrow 2d=-5$ មិនពិត

$*$ករណី $\begin{cases}c+d=12\\d-c=3\end{cases}\Rightarrow 2d=15$ មិនពិត

$*$ករណី $\begin{cases}c+d=12\\d-c=-8\end{cases}\Rightarrow 2d=4\Rightarrow d=2\Rightarrow c=10$ មិនពិត ព្រោះ $0\le c\le9$

$*$ករណី $\begin{cases}c+d=3\\d-c=3\end{cases}\Rightarrow 2d=6\Rightarrow d=3\Rightarrow c=0$ យក

ដូចនេះ $a=2,b=0,c=0,d=3$ ។

លំហាត់ទី៧៩

ចូរស្រាយបញ្ជាក់ថាបើ a , b , c ជាចំនួនគត់ធម្មជាតិដែលផ្ទៀងផ្ទាត់:
$a^{2007}+b^{2007}=c^{2007}$ នោះ $\min\{a,b\}\geq 2007$ ។

(Vietnam Olympic 2007)

ដំណោះស្រាយ

ឧបមាថា: $a\leq b$ នោះ $\min\{a,b\}=a$ (1)

តាមសម្មតិកម្ម: $a^{2007}+b^{2007}=c^{2007}$

ទាញបាន: $c>b$ ឬ $c\geq b+1$ (ព្រោះ $b,c\in\mathbb{N}^*$)

$$\Rightarrow c^{2007}\geq (b+1)^{2007}=b^{2007}+2007b^{2006}+\cdots+1$$
$$\geq b^{2007}+2007b^{2006}$$

$$\Rightarrow c^{2007}-b^{2007}\geq 2007b^{2006}\geq 2007a^{2006}$$

$$\Rightarrow a^{2007}\geq 2007a^{2006}$$

$$\Rightarrow a\geq 2007 \quad (2)$$

តាម (1) និង (2) យើងបាន: $\min\{a,b\}\geq 2007$

ដូចនេះ $\min\{a,b\}\geq 2007$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៨០

គេឲ្យ a, b, n ជាចំនួនគត់ដែលធំជាង 1 និង $0 \le x_i \le b$ ចំពោះ $i = 0,1,2,\ldots,n$ ហើយ $x_n \ne 0, x_{n-1} \ne 0$ ។ $\overline{x_n x_{n-1} \ldots x_1 x_0}$ តាងឲ្យចំនួន A_n នៅក្នុងប្រព័ន្ធរបាប់គោល a ហើយតាងឲ្យ B_n ក្នុងប្រព័ន្ធរបាប់គោល b , ដូចគ្នាដែរ $\overline{x_{n-1} x_{n-2} \ldots x_1 x_0}$ តាងឲ្យចំនួន A_{n-1} នៅក្នុងប្រព័ន្ធរបាប់គោល a ហើយតាងឲ្យ B_{n-1} ក្នុងប្រព័ន្ធរបាប់ គោល b ។ ចូរស្រាយបញ្ជាក់ថា: $a < b$ លុះត្រាតែ $\frac{A_{n-1}}{A_n} < \frac{B_{n-1}}{B_n}$ ។

(IMO 1970)

ដំណោះស្រាយ

តាមសម្មតិកម្ម: $A_n = \overline{x_n x_{n-1} \ldots x_1 x_0}_{(a)} = x_n a^n + x_{n-1} a^{n-1} + \cdots + x_0$

$$A_{n-1} = \overline{x_{n-1} x_{n-2} \ldots x_1 x_0}_{(a)} = x_{n-1} a^{n-1} + x_{n-2} a^{n-2} + \cdots + x_0$$

$$B_n = \overline{x_n x_{n-1} \ldots x_1 x_0}_{(b)} = x_n b^n + x_{n-1} b^{n-1} + \cdots + x_0$$

$$B_{n-1} = \overline{x_{n-1} x_{n-2} \ldots x_1 x_0}_{(b)} = x_{n-1} b^{n-1} + x_{n-2} a^{n-2} + \cdots + x_0$$

តាង $F(t) = \dfrac{x_n t^n + x_{n-1} t^{n-1} + \cdots + x_1 t + x_0}{x_{n-1} t^{n-1} + x_{n-2} t^{n-2} + \cdots + x_1 t + x_0}$

$$= 1 + \frac{x_n t^n}{x_{n-1} t^{n-1} + x_{n-2} t^{n-2} + \cdots + x_1 t + x_0}$$

$= 1 + \dfrac{x_n}{G(t)}$ ដែល $G(t) = \dfrac{x_{n-1}}{t} + \dfrac{x_{n-2}}{t^2} + \cdots + \dfrac{x_1}{t^{n-1}} + \dfrac{x_0}{t^n}$

ដោយចំពោះ $i = 0,1,2,\ldots,n : x_i \ge 0$ នោះ $G(t)$ ជាអនុគមន៍ចុះ នាំឲ្យ $F(t)$ ជាអនុគមន៍កើន យើងបាន:

- បើ $a > b$ នោះ $F(a) > F(b)$ ឬ $\dfrac{A_n}{A_{n-1}} > \dfrac{B_n}{B_{n-1}}$ ឬ $\dfrac{A_{n-1}}{A_n} < \dfrac{B_{n-1}}{B_n}$

• បើ $\frac{A_{n-1}}{A_n} < \frac{B_{n-1}}{B_n}$ ឬ $\frac{A_n}{A_{n-1}} > \frac{B_n}{B_{n-1}}$ ឬ $F(a) > F(b)$ នោះ $a > b$

ដូចនេះ $a < b$ លុះត្រាតែ $\frac{A_{n-1}}{A_n} < \frac{B_{n-1}}{B_n}$ ។

លំហាត់ទី៨១

គេឲ្យស្វ៊ីត $a_0 , a_1 , a_2 , \dots$ និង $b_0 , b_1 , b_2 ,\dots$ ដែល $a_0 , b_0 > 0$ ហើយ

$a_{n+1} = a_n + \frac{1}{2b_n}$, $b_{n+1} = b_n + \frac{1}{2a_n}$ ។ ចូរស្រាយបញ្ជាក់ថា:

$Max\{a_{2006}, b_{2006}\} > \sqrt{2007}$ ។

(Vietnam Olympic 2007)

ដំណោះស្រាយ

គេមាន: $a_{n+1}b_{n+1} = \left(a_n + \frac{1}{2b_n}\right)\left(b_n + \frac{1}{2a_n}\right)$

$$= a_n b_n + \frac{1}{4a_n b_n} + 1$$

$$= a_{n-1}b_{n-1} + \frac{1}{4a_{n-1}b_{n-1}} + \frac{1}{4a_n b_n} + 2$$

$$= \cdots = a_0 b_0 + \sum_{i=0}^{n} \frac{1}{4a_i b_i} + n + 1$$

នាំឲ្យ $a_{2006} \cdot b_{2006} = a_0 b_0 + \sum_{i=0}^{2005} \frac{1}{4a_i b_i} + 2006$

$$> a_0 b_0 + \frac{1}{4a_0 b_0} + 2006 \geq 2\sqrt{a_0 b_0 \cdot \frac{1}{4a_0 b_0}} + 2006 = 2007 \quad (1)$$

ម្យ៉ាងទៀត: $Max\{a_{2006}, b_{2006}\} \geq a_{2006} > 0$ ហើយ

$Max\{a_{2006}, b_{2006}\} \geq b_{2006} > 0$

នាំឲ្យ $\left(Max\{a_{2006}, b_{2006}\}\right)^2 \geq a_{2006} \cdot b_{2006} \quad (2)$

តាម (1) និង (2) ទាញបាន: $\left(Max\{a_{2006},b_{2006}\}\right)^2 > 2007$

ដូចនេះ $Max\{a_{2006},b_{2006}\} > \sqrt{2007}$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៨២

គេឲ្យ $f(x) = x^n + 5x^{n-1} + 3$ ដែល $n > 1$ ជាចំនួនគត់ ។

ចូរស្រាយបញ្ជាក់ថា: $f(x)$ មិនអាចសរសេរជាផលគុណនៃពីរពហុធាដែលមាន មេគុណជាចំនួនគត់ហើយមានដឺក្រេយ៉ាងតិចបំផុត 1 នោះឡើយ ។

(IMO1993)

ដំណោះស្រាយ

ឧបមាថា $f(x) = g(x)\cdot h(x)$ ដែល $g(x)$ និង $h(x)$ ជាពហុធាមិនថេរមាន មេគុណជាចំនួនគត់ ។

គេមាន: $f(x) = x^n + 5x^{n-1} + 3 \Rightarrow f(0) = g(0)\cdot h(0) = 3$

នោះច្បាស់ជាមានមួយក្នុងចំណោម $g(0)$ និង $h(0)$ ស្មើនឹង ± 1 , សន្មតថា: $g(0) = \pm 1$ ដូច្នេះ យើងអាចតាង $g(x) = x^r + \cdots \pm 1$

ដោយ $f(\pm 1) \neq 0$ នោះ $r > 1$ ឬ $r \geq 2$ ។

តាង $z_1, z_2, \ldots, z_r$ ជាឫសនៃពហុធា $g(x)$ នោះ

$g(x) = (x - z_1)(x - z_2)\cdots(x - z_r)$ គេបាន: $g(0) = (-z_1)(-z_2)\cdots(z_r)$

$\Rightarrow |z_1 z_2 \cdots z_r| = |g(0)| = 1$ ឬ $\left|\prod_{i=1}^{r} z_i^{n-1}\right| = 1$

ហើយ: $|g(-5)| = |(-5 - z_1)(-5 - z_2)\cdots(-5 - z_r)|$

$= |(5 + z_1)(5 + z_2)\cdots(5 + z_r)| = \left|\prod_{i=0}^{r}(5 + z_i)\right| = \left|\prod_{i=0}^{r}(5 + z_i)\right|\left|\prod_{i=0}^{r} z_i^{n-1}\right|$

$= \left|\prod_{i=0}^{r} z_i^{n-1}(5 + z_i)\right|$

ដោយ z_i ជាឫសនៃ $g(x)$ នោះពួកវាក៏ជាឫសនៃ $f(x)$ គេបាន: $f(z_i)=0$

$\Rightarrow z_i^n+5z_i^{n-1}+3=0 \Leftrightarrow z_i^{n-1}(z_i+5)=-3$

$$\Rightarrow |g(-5)|=\left|\prod_{i=0}^{r}(-3)\right|=3^r\geq 3^2=9 \quad (*)$$

តែ $g(-5)\cdot h(-5)=f(-5)=3 \Rightarrow |g(-5)|\leq 3$ ផ្ទុយពី $(*)$ នេះបញ្ជាក់ថា: ការឧបមាខាងលើគឺខុស ។

ដូចនេះ: $f(x)$ មិនអាចសរសេរជាផលគុណនៃពីរពហុធាដែលមានមេគុណជាចំនួនគត់ហើយមាដឺក្រេយ៉ាងតិចបំផុត 1 នោះឡើយ ។

លំហាត់ទី៨៣

ចំពោះពីរចំនួនគត់វិជ្ជមាន a និង b ដែលជាចំនួនបឋមរវាងគ្នា , ចូររកគ្រប់តួចែករួមធំបំផុតដែលអាចនៃ $a+b$ និង $\frac{a^{2005}+b^{2005}}{a+b}$ ។

(Korean Mathematical Olympiad 2005)

ដំណោះស្រាយ

តាង $d=\gcd\left(a+b,\frac{a^{2005}+b^{2005}}{a+b}\right)$

$\Rightarrow a+b\equiv 0(\bmod d) \Leftrightarrow a\equiv -b(\bmod d)$

ហើយ $\frac{a^{2005}+b^{2005}}{a+b}\equiv 0(\bmod d)$

$\Leftrightarrow a^{2004}-a^{2003}b+a^{2002}b^2-\cdots+b^{2004}\equiv 0(\bmod d)$

$\Rightarrow b^{2004}+b^{2004}+\cdots+b^{2004}\equiv 0(\bmod d)$

$\Rightarrow 2005b^{2004}\equiv 0(\bmod d) \quad \Rightarrow 2005a^{2004}\equiv 0(\bmod d)$

$\Rightarrow d\,|\,2005a^{2004} \wedge d\,|\,2005b^{2004}$

$$\Rightarrow\ d \mid \gcd\left(2005a^{2004}, 2005b^{2004}\right) = 2005\gcd\left(a^{2004}, b^{2004}\right)$$

